00349157

E1/43.1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៣៩**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាត្តូ គ្រីស្ពារ *(Mr. Matteo Crippa)*

លោកស្រី សែ គុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

កញ្ញា អាលីណា ប្រៃអត *(Ms.Alina Briot)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក រ៉ូប៊ឺត ពើទីត *(Mr. Robert Petit)*

លោក តាន់ សេណារ៉ុង

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល *(Mr.Zachery LAMPEL)*

លោក ជា ផល្លា

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក យុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទួត ហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

# ឧបសម្ព័ន្ធ

## សាក្សី

### លោក លី ហ៊ី

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ............ ទំព័រ ៦
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៏ ផ្ដើមពី ............ ទំព័រ ៤០
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ............ ទំព័រ ៤២
សួរបន្តដោយ ប្រធានអង្គជំនុំ ផ្ដើមពី ............ ទំព័រ ៤៧
សួរដោយ លោក សេង ប៊ុនឃាង ផ្ដើមពី ............ ទំព័រ ៤៨
សួរដោយ លោក អាឡាំង វ៉ែនណឺ ផ្ដើមពី ............ ទំព័រ ៤៩
សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្ដើមពី ............ ទំព័រ ៥៥
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្ដើមពី ............ ទំព័រ ៥៨
សួរដោយ លោក ហុង គឹមសួន ផ្ដើមពី ............ ទំព័រ ៦០
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី ............ ទំព័រ ៦៧
សួរដោយ លោកស្រី ម៉ារីប៊ូល កានីហ្សារ ផ្ដើមពី ............ ទំព័រ ៦៩

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺន៍ | បារាំង |
| លោក លី ហ៊ | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក រូប៊ីត ពើទីត | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ-បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | បារាំង |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០២:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងអ្នកដែលអង្គជំនុំជម្រះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការដេញដោលនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ។ ភាគីដែលត្រូវចូលរួម នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ បុគ្គលដែលត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងព្រឹកនេះដែរក៏មានវត្តមានដែរ ។ ខ្ញុំបានត្រួតពិនិត្យអត្តសញ្ញាណ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោកចៅក្រម និងមេធាវី! ខ្ញុំមានចំណុចមួយជម្រាបអង្គជំនុំជម្រះមុនពេលដែលនឹងអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី ។ ដូចដែលលោកជ្រាបហើយថា ពីរបីសប្ដាហ៍មុននេះយើងបានជម្រាបអង្គជំនុំជម្រះអំពីដើមបណ្ដឹងរដ្ឋប្បវេណី ដែលមិនមែនជាអ្នករស់រានមានជីវិត ហើយដែលអាចនឹងកោះអញ្ជើញមកផ្ដល់សក្ខីកម្ម ។ ខ្ញុំខ្លួនឯងសូមជម្រាបថា យើងមាន ៣៧ម៉ោងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ។ នៅក្នុងចុងសប្ដាហ៍នេះ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលយើងនឹងអញ្ជើញមកធ្វើសក្ខីកម្មនោះ គឺយើងធ្វើការវាយតម្លៃសាជាថ្មី ដោយហេតុថាវាមានការវិវឌ្ឍន៍ថ្មីនោះ ។ ហើយជាអកុសលនោះ អកុសលមែនទែន គឺគាត់ៗមិនអាចមានលទ្ធភាពអញ្ជើញមកផ្ដល់សក្ខីកម្មបានទេ។ ដូច្នេះ យើងជម្រាបថា ការវាយតម្លៃឥឡូវនេះគាត់មានអារម្មណ៍ភ័យខ្លាចខ្លាំងណាស់ គាត់មិនអាចមកបានទេ E2/43 សាក្សីនោះ ។ ជាអកុសល អ៊ីចឹងហើយខ្ញុំសូមជម្រាបថា ដកដើមបណ្ដឹងរដ្ឋប្បវេណីនោះមកវិញ ។ អ៊ីចឹងហើយក្រុមរបស់ខ្ញុំនៅសល់តែប្រាំបួនម៉ោងទេ គឺថាសរុបទាំងអស់គឺថាយើងមាន

តែសាមសិបប្រាំម៉ោងទេ មិនមែនជាសាមសិបប្រាំពីរម៉ោង ។ ហើយខ្ញុំសុំអរគុណ បើសិនជាសុំឲ្យអង្គជំនុំជម្រះដកឈ្មោះគាត់នោះចេញពីបញ្ជី ។ សូមអរគុណ ។

[០៩:០៦:០១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានផ្តល់នូវព័ត៌មានអំពីស្ថានភាពនៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវនឹងត្រូវអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលអនាគតនោះ ។

អញ្ជើញ ។

**លោកស្រី ស៊ីលយ៉ីស្ទួត ហ្វ៊ីនស្គី៖**

សូមអរគុណ សូមគោរពលោកប្រធាន លោកចៅក្រម និងមេធាវី ។ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីស្នើនូវបញ្ហាដូចខាងក្រោមទាក់ទងនឹងសាក្សី E2/80 ដែលគាត់នឹងផ្តល់សក្ខីកម្មក្នុងសប្តាហ៍នេះ ហើយយើងបានដឹងថា រឿងរ៉ាវដែលគាត់អាចប្រាប់យើងដល់អង្គជំនុំជម្រះនោះ គឺវាមានច្រើនជាងអ្វីដែលយើងបានគ្រោងទុក ។ ដូច្នេះ គឺថាទម្រង់ផ្តល់ព័ត៌មានរបស់ជនរងគ្រោះនោះ យើងបានបញ្ចូលហើយ ។ ដូច្នេះ ខ្ញុំសុំស្នើដល់អង្គជំនុំជម្រះដើម្បីប្រើពេលបន្ថែមសម្រាប់គាត់ ដោយហេតុថា គាត់មានរឿងរ៉ាវច្រើនដើម្បីនិយាយជាងដែលយើងគ្រោងទុក ។ ដូច្នេះ ខ្ញុំសុំអនុញ្ញាតពីអង្គជំនុំជម្រះ និងជម្រាបជូនអង្គជំនុំជម្រះជាមុន ហើយនិងដើម្បីនឹងដាក់ជូននូវចំណុចមួយចំនួនថែមទៀតជាលាយលក្ខណ៍អក្សរនៅចំណុចព័ត៌មានដើម្បីអង្គជំនុំជម្រះអាចនឹងសួរ តាំងសំណួរទៅគាត់បន្ថែមទៀត ។

អ៊ីចឹងគឺថាអាចនឹងត្រូវការកន្លះថ្ងៃសម្រាប់គាត់បន្ថែមទៀត ។ អ៊ីចឹងដើម្បីគាត់ប្រាប់ព័ត៌មាន ឬក៏ភស្តុតាងថ្មីៗបន្ថែមទៀត ដែលព័ត៌មាននោះមិនទាន់លាតត្រដាងឲ្យដឹងពីមិននោះទេ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោកប្រធាន លោកចៅក្រម ។ អ៊ីចឹង គឺថាដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងមួយចំនួនព្រឹកនេះ គឺថាដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងកោះអញ្ជើញមកពីប្រទេសបារាំង ពួកគាត់ចង់មកចូលរួម និងផ្តល់សក្ខីកម្មតាមរយៈការឆ្លើយនឹងសំណួរ ។ ដូច្នេះ គឺថាមានបញ្ហាសំខាន់ៗមួយចំនួនដែលយើងមិនអាចដឹងច្បាស់ថាពេលណាដែលអញ្ជើញកោះសាក្សីហ្នឹងមកបាន ។ អ៊ីចឹង ហើយគឺថាយើងចង់ជម្រាបអង្គជំនុំជម្រះឲ្យបានជ្រាប ។

**ប្រធានអង្គជំនុំ៖**

ការលើកឡើងរបស់មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកត់សម្គាល់នូវបញ្ហាទាំងអស់នេះ ហើយនិងពិចារណាសម្រេចនៅពេលក្រោយ ។ ហើយដោយឡែកអ្នកដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវអញ្ជើញចូលរួមក្នុងសវនាការនោះ គឺយើងមានផែនការ ការកំណត់នូវកាលវិភាគសម្រាប់ធ្វើអញ្ជើញគាត់មកផ្តល់សក្ខីកម្ម ឬធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ។ ប៉ុន្តែវាមានបញ្ហាពីរ ទីមួយគឺអង្គជំនុំជម្រះនឹងពិនិត្យលទ្ធភាពក្នុងការសម្រេចថា តើសាក្សីណាខ្លះដែលត្រូវដកចេញពីបញ្ជីនៅក្នុងការកោះហៅមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ? ដោយសារហេតុនេះវាបើមិនច្បាស់លាស់ទេវានាំឲ្យមានឥទ្ធិពលដល់កាលបរិច្ឆេទនៃកំណត់កាលវិភាគសវនាការសម្រាប់ទៅមុខ ទាំងសប្តាហ៍នីមួយៗក៏ដូចជានៅក្នុងខែដែរ ។

[០៩:១០:២៦]

ដោយឡែកបញ្ហាទីពីរ គឺពាក់ព័ន្ធជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺអង្គជំនុំជម្រះបានរៀបចំផែនការជាក់លាក់នៅក្នុងការអញ្ជើញគាត់មកធ្វើសក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះក៏ដូចជាការធ្វើសក្ខីកម្មតាមរយៈពិចម្ងាយ *វីដេអូ ខនហ្វឺរិន* នោះដែលយើងបានគិតគូររួចហើយ នៅតែសម្រេចលើបញ្ហាសាក្សីដែលត្រូវដកចេញពីបញ្ជីឈ្មោះ ដែលត្រូវកោះហៅមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ ។ ហើយម្យ៉ាងទៀតការកិលនៃកាលវិភាគសម្រាប់ដំណើរការសវនាការនេះ ដោយសារក្នុងអំឡុងពេលកន្លងមក កាលបើអង្គជំនុំជម្រះកិលនូវកាលវិភាគសម្រាប់ធ្វើសវនាការប្រចាំសប្តាហ៍នីមួយៗ ឬក៏ប្រចាំខែមានរយៈពេលវែងនោះ នាំឲ្យការគណនាពេលវេលានោះមិនត្រូវទេ ។

ហេតុដូច្នេះហើយបានជាអង្គជំនុំជម្រះមានការដូរនូវរបៀប ឬក៏វិធីនៅក្នុងការកំណត់កាលបរិច្ឆេទនេះនៅក្នុងអំឡុងពេលខ្លី មិនវែងពេកទេ យ៉ាងច្រើនគឺប្រាំមួយសប្តាហ៍ប៉ុណ្ណោះ ដើម្បីកុំឲ្យមានការលម្អៀងពេលវេលាហ្នឹងខុសច្រើន ដូចអ្វីដែលយើងបានធ្វើពីមុនៗមកនោះ ។

ជាកិច្ចបន្តនេះ មុននឹងស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ឆ្នាំនេះសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះធ្វើសេចក្តីប្រកាសនូវសេចក្តីសម្រេចលើការដកសាក្សី KW-24 ចេញពីបញ្ជីឈ្មោះសាក្សីដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។

អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបដល់ភាគី និងសាធារណជនអំពីសេចក្តីសម្រេចរបស់ខ្លួនទាក់ទងទៅនឹងសាក្សី KW-24 ។

ប្រវត្តិនៃអង្គហេតុ នៅថ្ងៃច័ន្ទ ទី២៩ ខែកក្កដា-- ២៩ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនានា អំពីសេចក្ដីសម្រេចរបស់ខ្លួនលើការដកចេញនូវសាក្សីមួយចំនួនចេញពីបញ្ជីឈ្មោះសាក្សី ដែលនឹងត្រូវកោះហៅដើម្បីមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះបានស្នើសុំនូវមតិយោបល់ពីភាគីអំពីការដកចេញនូវសាក្សី KW-24 ចេញពីបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

[០៩:១៣:៣០]

សហព្រះរាជអាជ្ញាបានស្នើសុំលទ្ធភាពពិភាក្សាលើបញ្ហានេះនៅក្នុងសវនាការជាអសាធារណៈ ឬធ្វើការកត់សម្គាល់របស់ខ្លួនជាលាយលក្ខណ៍អក្សរ ។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ដែលនឹងត្រូវដាក់ជូនអង្គជំនុំជម្រះយ៉ាងយូរបំផុតត្រឹមថ្ងៃអង្គារ ទី៣០ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោងបួន និងសាមសិបនាទីល្ងាច ។

ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសេចក្ដីអត្ថាធិប្បាយលើបញ្ហាដែលបានលើកឡើងនេះទេ ចំណែកឯមេធាវីការពារក្ដីក៏មិនបានធ្វើការជំទាស់ទៅលើសំណើដកសាក្សីនេះដែរ ។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីសន្និដ្ឋានលាយលក្ខណ៍អក្សររបស់ខ្លួន ដែលឯកសារត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់ដើម្បីស្នើសុំទុកសាក្សី KW-24 ក្នុងបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។

សហព្រះរាជអាជ្ញាបានលើកឡើងថា សាក្សី KW-24 គឺជាសាក្សីតែម្នាក់គត់ដែលបានយល់ដឹងច្បាស់ និងមានបទពិសោធន៍យ៉ាងច្រើនទាក់ទងនឹងប្រតិបត្តិការនៅជើងឯក ។ សក្ខីកម្មរបស់សាក្សីរូបនេះ គឺពិតជាមានសារសំខាន់ក្នុងការផ្ដល់នូវការពិត អំពីឧក្រិដ្ឋកម្មទាំងឡាយដែលកើតមាននៅទីនោះ ហើយដែលសាក្សីផ្សេងទៀត ក្រៅពីសាក្សីរូបនេះ មិនអាចនឹងធ្វើបានដូច្នេះ ។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា អត្ថប្រយោជន៍ដែលនឹងបានពីការស្ដាប់សក្ខីកម្មរបស់សាក្សី KW-24 ដោយអង្គជំនុំជម្រះគឺជាទម្ងន់ និងតម្លៃលើសពីអ្វីដែលអង្គជំនុំជម្រះគិតថា ជាការខាតបង់ពេលវេលាបន្ថែមនោះ ។

សំអាងហេតុ៖

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សក្ខីកម្មរបស់សាក្សី KW-24 គឺមានជាប់ទាក់ទងនឹងអង្គហេតុដែលសាក្សីផ្សេងទៀតនឹងត្រូវមកផ្ដល់សក្ខីកម្មផងដែរ ។ អង្គជំនុំមិនយល់ឃើញថា សក្ខីកម្មរបស់សាក្សីរូបនេះ ហ្នឹងអាចផ្ដល់នូវព័ត៌មានដែលមិនអាចរកបានតាមរយៈមធ្យោបាយផ្សេងៗទៀតនោះ

ឡើយ ។ ដោយគិតពិចារណាទៅដល់ការជំនុំជម្រះមួយ ដែលប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័សនោះ អង្គជំនុំជម្រះយល់ថា វាមិនជាការចាប់បាច់ទេក្នុងការស្តាប់សក្ខីកម្មរូបនេះ ដោយផ្ទាល់នូវចំពោះមុខអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះកត់សម្គាល់ថា ចម្លើយរបស់សាក្សី KW-24 បានធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេត និងត្រូវដាក់នូវចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

ហេតុដូច្នេះ សម្រេចៈ អង្គជំនុំជម្រះសម្រេចដកសាក្សី KW-24 ចេញពីបញ្ជីឈ្មោះសាក្សី ដែលនឹងផ្តល់សក្ខីកម្មនូវចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

**លោកស្រី ស៊ីលយីស្វត ហ្សីនស្តុីៈ**

លោកប្រធានសូមអនុញ្ញាត គឺថាសូមកែតម្រូវ មិនមែន E2 សាក្សី គឺ E2/32 មិនមែន E2/80 ទេ ។ សូមអភ័យទោស ដែលយើងស្នើពីខាងដើមនោះ ។

**ប្រធានអង្គជំនុំៈ**

មន្ត្រីតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លី ហ៊ ចូលមកកាន់បន្ទប់សវនាការ ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលកាន់បន្ទប់សវនាការ)*

[០៩:១៩:៣៥]

**លោកស្រី ម៉ារីប៉ូល កានីហ្សារៈ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតរំឭកថា នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៩ មេធាវីការពារបានរក្សាសិទ្ធិ ដើម្បីលើកឡើងនូវបញ្ហាមួយចំនួនទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹង ស-២១ ។ ដូច្នេះ ដល់ពេលមួយដែលខ្ញុំគិតថា មានប្រយោជន៍ហើយ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ជូនអង្គជំនុំជម្រះ ថាកូនក្តីរបស់ខ្ញុំមានការសង្ស័យពាក់ព័ន្ធទៅនឹងការឃុំខ្លួននូវសាក្សីរូបនេះនៅស-២១ ។

**ប្រធានអង្គជំនុំៈ**

មេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់ជាងនេះបន្តិចមើលថា ចង់និយាយនេះ ចង់បង្ហាញអង្គជំនុំជម្រះថាម៉េច អំពីការកត់សម្គាល់ដែលលើកឡើងអំម្បាញ់មិញនេះ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារៈ**

លោកប្រធាន! ខ្ញុំគិតថា វាមានសារប្រយោជន៍មុនពេលនឹងយើងសួរទៅដើមបណ្តឹងរដ្ឋប្បវេណីថា ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា កូនក្តីរបស់ខ្ញុំមានការសង្ស័យមួយចំនួនទាក់ទងទៅនឹងអង្គហេតុដែល

ថា លោក លី ហ៊ា នេះ ថាជាអ្នកដែលធ្លាប់ជាប់ឃុំនៅស-២១ ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាត ដើម្បីឲ្យមានការបំភ្លឺ ដើម្បីឲ្យអង្គជំនុំជម្រះអាចសួរសំណួរ ដែលអាចសួរទៅតាមរបៀបមួយដែលខុសពីការធម្មតាទាក់ទងទៅអង្គហេតុដែលកូនក្តីរបស់ខ្ញុំ គាត់មានមន្ទិលសង្ស័យអំពីបញ្ហាអង្គហេតុនោះ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថាការស្តាប់នូវសក្ខីកម្មសាក្សីនីមួយៗ ក៏ដូចជាស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ គឺវាមានលក្ខណៈខុសគ្នា អាស្រ័យលើទំនាក់ទំនងលើការអះអាងរបស់ពួកគាត់ដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ ។ មិនមែនពុំគំរូណាមួយដើម្បីឲ្យគាត់ធ្វើសេចក្តីថ្លែងការណ៍ ឬក៏សួរទៅសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដូចៗគ្នានោះទេ ។

បញ្ហាទីពីរនៅក្នុងនីតិវិធីដែលយើងកំពុងតែអនុវត្តនេះ បានផ្តល់លទ្ធភាពទៅដល់ជនជាប់ចោទធ្វើការកត់សម្គាល់នូវការផ្តល់សក្ខីកម្ម ឬក៏ចម្លើយរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលនៃសួរដេញដោល ជាពិសេសក្រោយពេលស្តាប់ចម្លើយ ឬក៏សក្ខីកម្មសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនោះរួច មុននឹងជូនវេទិកាទៅឲ្យមេធាវីការពារក្តី ។ យើងគិតថា មានហេតុផលគ្រប់គ្រាន់សម្រាប់ឲ្យលទ្ធភាពដល់ជនជាប់ចោទនៅក្នុងការបញ្ជាក់លើការផ្តល់សក្ខីកម្ម ឬសេចក្តីថ្លែងការណ៍នោះ ថាវាយ៉ាងម៉េច? ដើម្បីអង្គជំនុំជម្រះមានការយកមកត្រិះរិះពិចារណាបានហើយ ។

[០៩:២៤:០៥]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ឈ្មោះអីទៅលោក? លោកមានឈ្មោះអ្វីដែរ?

**ឆ៖** ខ្ញុំបាទឈ្មោះ លី ហ៊ា ។

**ស៖** លោកមានឈ្មោះហៅក្រៅពីឈ្មោះ ហ៊ា ដែរឬទេ?

**ឆ៖** ឆ្នាំ៧៩-- ៧៥ យើងខ្ញុំដាក់ឈ្មោះ អ៊ា ហ៊ា ក្រោយពី៧៩ មកយើងខ្ញុំដាក់ឈ្មោះ លី ហ៊ាវិញ ។

**ស៖** នៅចន្លោះឆ្នាំ៧៥-៧៩ លោកប្រើឈ្មោះអ្វីទៅ?

**ឆ៖** មុនឆ្នាំ៧៩ ពី៧៥ ទៅដល់ ៧៩ ដាក់ឈ្មោះ អ៊ា ហ៊ា ។

**ស៖** ឆ្នាំនេះលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** មានអាយុ ៥៧ឆ្នាំ ។

**ស៖** សព្វថ្ងៃនេះលោកនៅទីណា? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំរស់នៅខេត្តបន្ទាយមានជ័យ ។ មុខរបររកស៊ី លក់ដូរ ។

**ស៖** មុនឆ្នាំ១៩៧៥ លោកនៅឯណា? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** មុនឆ្នាំ៧៥ យើងខ្ញុំរស់នៅនៅក្នុងបន្ទុកគ្រួសារជាមួយនឹងឪពុកម្តាយ ។ រួចហើយក៏គេកែនឲ្យធ្វើទាហាននៅជំនាន់ឆ្នាំ៧២, ៧៣, ៧៤, ៧៥ នេះ មកទល់ត្រឹម៧៥ បានយើងខ្ញុំគេចាប់ខ្លួន ។

**ស៖** មុនពេលគេចាប់ខ្លួនលោកហ្នឹង លោកនៅឯណា? ធ្វើកងទ័ពហ្នឹងៗនៅឯណាទៅ?

**ឆ៖** មុននឹងគេចាប់ខ្លួនយើងខ្ញុំ ខ្ញុំរស់នៅស្រុកកោះធំ តំបន់២៥ ។ នៅតំបន់២៥ រួចហើយក៏គេកែនធ្វើទាហាននៅវរៈ១១៩ ។

**ស៖** លោកធ្វើទាហាននៅវរៈ១១៩ហ្នឹង ឋានៈលោក-- មានឋានៈអ្វីដែរ?

**ឆ៖** ជាយុទ្ធជន ។

**ស៖** អំម្បាញ់មិញនេះលោកនិយាយដល់ពាក្យថា គេចាប់ខ្លួនលោក ។ សំណួរសួរថា តើខាងណាដែល-- កម្លាំងខាងណាចាប់ខ្លួនលោក? ហើយចាប់នៅទីណា? យកទៅដាក់នៅកន្លែងណា? ពីពេលណា? មូលហេតុអី?

[០៩:២៨:១៥]

**ឆ៖** គេចាប់ខ្លួនខ្ញុំនៅតំបន់២៥ យកដាក់នៅពោធិ៍ទន្លេ១ រួចហើយបានគេបញ្ជូនខ្ញុំមកឡើងនៅគុកពេទ្យឆ្កួតតៅខ្មៅយើងនេះ ។ បានបន្តបន្ទាប់មកទៀតបញ្ជូនមកនឹងគុកទួលស្លែង ចេញពីគុកទួលស្លែងបានចេញទៅព្រៃស ។ ទៅព្រៃស ខ្ញុំសម្រេចរត់រួចរហូតបានត្រឡប់ទៅដល់ផ្ទះវិញ ។

**ស៖** លោកនិយាយថា គេចាប់ខ្លួនលោកនៅតំបន់២៥ ហើយយកទៅដាក់នៅពោធិ៍ទន្លេ ។ ដាក់ពោធិ៍ទន្លេហ្នឹង ដាក់កន្លែងអីទៅកន្លែងពោធិ៍ទន្លេហ្នឹង?

**ឆ៖** ពោធិ៍ទន្លេនេះ គេទើប-- ឈ្មោះដែលកាលគេចាប់ខ្លួន គេដាក់តំបន់-- គេដាក់មន្ទីរ១៥១ ។

**ស៖** មន្ទីរ១៥ហ្នឹង ជាកន្លែងអីទៅ?

**ឆ៖** ជាកន្លែង តំបន់ ។

**ស៖** ជាមន្ទីរតំបន់ អ៊ីចឹងអ្ហេ? ឬក៏មន្ទីរសន្តិសុខ ឬក៏មន្ទីរតំបន់? ព្រោះប្រើពាក្យចាប់ ចាប់យកទៅដាក់នៅពោធិទន្លេ១គឺមន្ទីរ១៥ ។ អ៊ីចឹងមន្ទីរ១៥ហ្នឹងជាមន្ទីរតំបន់ បានន័យថា ជាមន្ទីរនៃខាងអាជ្ញាធររដ្ឋអំណាចថ្នាក់តំបន់២៥ ធ្វើការ ឬក៏ជាកន្លែងមន្ទីរសន្តិសុខសម្រាប់ដាក់គុកមនុស្សរបស់តំបន់២៥?

**ឆ៖** លោកតុលាការ អាកន្លែងហ្នឹង ក៏ខ្ញុំដឹងដោយគោលៗច្បាស់ដែរថា កន្លែងហ្នឹងជាតំបន់២៥ ដាក់ឈ្មោះមន្ទីរ១៥ គុកហ្នឹង ។

**ស៖** អ៊ីចឹងមន្ទីរ១៥ហ្នឹង គឺជាគុកនៃតំបន់២៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** លោកត្រូវគេចាប់កងកម្លាំងចាប់លោកបញ្ជូនលោកទៅដាក់នៅក្នុងមន្ទីរ១៥ហ្នឹង លោកចាំទេ នៅថ្ងៃខែឆ្នាំណា? ហើយមូលហេតុបានជាគេចាប់ខ្លួនលោកទៅដាក់ក្នុងមន្ទីរ១៥?

**ឆ៖** ខ្ញុំ ថ្ងៃខែឆ្នាំ ខ្ញុំចាំតែឆ្នាំ ថ្ងៃខែខ្ញុំអត់បានចាំ នៅក្នុងឆ្នាំ១៩៧៦ ។ មូលហេតុដែលខ្ញុំ គេចាប់ហ្នឹង ដោយសារអត់ឃ្លានខ្លាំងពេក គេប្រើឱ្យមកធ្វើការ រួចហើយនាំគ្នាទៅរកហូប ក៏គេចាប់ខ្លួនបាន ។

**ស៖** អ៊ីចឹងមូលហេតុដែលចាប់ទៅហ្នឹង គឺលោកទៅលួចរបស់ របស់ម្ហូបអាហារ ដើម្បីហូបចុក ព្រោះមូលហេតុឃ្លាន ។ នេះជាមូលហេតុចម្បងដែលគេចាប់លោក យកទៅដាក់មន្ទីរ១៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** លោកទៅលួចអីទៅ? ហើយទៅលួចនៅកន្លែងណា?

**ឆ៖** នាំគ្នា-- គ្នាខ្ញុំមានបីនាក់ ខ្ញុំប្រើឈ្មោះ ឆាង គឹម ឆាង មួយ ហ្នឹង ជឺ គាង មួយ ឱ្យមកលួចអីវ៉ែវអីវ៉ាន់ នៅផ្ទះៗយកទៅហូប រួចហើយមកដល់ពាក់កណ្តាលផ្លូវ ក៏គេចាប់ខ្ញុំចូល ចាប់ឈ្មោះ ជឺ គាង និង គឹម ឆាង ហ្នឹងចូលនៅមន្ទីរ១៥មុន ។ ក៏ខ្ញុំបាត់ពីរហ្នឹង ក៏ខ្ញុំមកតាម ចាប់ទាំងខ្ញុំទៀត ។

[០៩:៣៣:០២]

**ស៖** គេចាប់លោកដាក់មន្ទីរ១៥ហ្នឹង រយៈពេលប៉ុន្មានថ្ងៃដែរ ប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ?

**ឆ៖** ដាក់នៅក្នុងមន្ទីរ១៥ហ្នឹង ខ្ញុំមិនចាំជាខែ ប៉ុន្មានខែ ប៉ុន្តែជាកំណត់ហ្នឹង គឺយូរដែរ គេបានវ៉ៃដំនៅកន្លែងហ្នឹង ។ យូរខែដែរ បានបញ្ជូនឡើងមកពេទ្យឆ្លូតនេះ ។

**ស៖** តើលោកនៅមន្ទីរ១៥ហ្នឹង គេឃុំឃាំងលោកទេ គេដាក់គុកលោក បានន័យគេដាក់ខ្នោះដៃ ឬក៏ខ្នោះជើង ឬក៏ដាក់នៅក្នុងទ្រុងដែលមានការចាក់សោរ ឬក៏ឃាមកាម តឹងតែងអ៊ីចឹងទីមួយ ។ ទីពីរ តើគេឱ្យលោកធ្វើការងារអ្វីខ្លះទៅនៅក្នុងមន្ទីរ១៥ នៅក្នុងអំឡុងពេលដែលលោកនៅទីនោះ?

**ឆ៖** នៅក្នុងមន្ទីរ១៥ហ្នឹង គេអត់មានដាក់ទ្រុងទេ គេដាក់ខ្នោះ នៅមានផ្ទះមួយសម្រាប់ដាក់អ្នកទោសទាំងអស់ អត់មានប្រើឱ្យធ្វើការងារអីទេ ដាក់តែខ្នោះទាំងយប់ ទាំងថ្ងៃ ហើយនិងវ៉ៃដំ សួរ

ចម្លើយ ។

**សៈ** លោកចាំទេ ថាគេបញ្ជូនលោកមន្ទីរ១៥មកកាន់មន្ទីរពេទ្យឆ្កួត គុកតាខ្មៅ ដែលមានទីតាំងនៅមន្ទីរឆ្កួតហ្នឹង នៅថ្ងៃខែឆ្នាំណា? ចាំទេ?

**ឆៈ** ខ្ញុំអត់បានចាំ ។ ចាំតែនៅក្នុងឆ្នាំ ១៩៧៦ ចុង ១៩៧៦ហ្នឹង ។

**សៈ** លោកនៅទីនោះប៉ុន្មានថ្ងៃ ប៉ុន្មានខែ ហើយគេប្រព្រឹត្តចំពោះលោកនៅក្នុងមន្ទីរសន្តិសុខពេទ្យឆ្កួតហ្នឹងយ៉ាងម៉េចដែរ?

**ឆៈ** នៅក្នុងមន្ទីរឆ្កួត គេបានសួរចម្លើយខ្ញុំបីដឹង គឺវ៉ៃដំខ្ញុំទាំងបីដង ។ ទើបសួរចម្លើយខ្ញុំចប់សព្វគ្រប់ហើយ បានបញ្ជូនខ្ញុំមកគុកទួលស្លែង ។

**សៈ** លោកនៅក្នុងមន្ទីរពេទ្យឆ្កួតហ្នឹង អស់រយៈពេលប៉ុន្មាន?

**ឆៈ** នៅចំនួន តាមប្រហែលជាមួយខែប៉ុណ្ណឹងឯង ។

**សៈ** ក្រៅពីសួរចម្លើយ តើបុគ្គលិកនៃមន្ទីរសន្តិសុខ ដែលនៅពេទ្យឆ្កួត នៅតាខ្មៅនុ៎ង គេបានប្រព្រឹត្តយ៉ាងដូចម្ដេចខ្លះចំពោះរូបលោក?

**ឆៈ** ពួកសន្តិសុខ ដែលនៅក្នុងពេទ្យឆ្កួតហ្នឹង វាអត់មានបានធ្វើអ្វីខ្ញុំទេ ប៉ុន្តែគ្រាន់តែហៅមកសួរចម្លើយ បានវ៉ៃដំខ្ញុំប៉ុណ្ណឹង ចំពោះតែសន្តិសុខ គឺអត់មានបានធ្វើអីខ្ញុំទេ ។

**សៈ** គេបានឃុំឃាំងលោកទេ? ក៏ដូចជាការដាក់ខ្នោះដៃ ខ្នោះជើងដែរទេ ឬក៏ដោះលែងឲ្យលោកដើរនៅក្នុងបរិវេណនៃមន្ទីរពេទ្យឆ្កួតនោះ ដោយមិនមានការដាក់ខ្នោះ ឬក៏ឃុំឃាំងទេ?

**ឆៈ** នៅក្នុងមន្ទីរពេទ្យឆ្កួតនោះ គេអត់មានបានលែងឲ្យយើងធ្វើការទេ គេដាក់ខ្នោះយើងទាំងយប់ ទាំងថ្ងៃ ។

[០៩:៣៩:០៤]

**សៈ** មធ្យោបាយដែលបញ្ជូនលោកពីមន្ទីរសន្តិសុខ១៥ នៅតំបន់២៥មកកាន់មន្ទីរសន្តិសុខ នៅពេទ្យឆ្កួតតាខ្មៅហ្នឹង គេបញ្ជូនលោកតាមមធ្យោបាយអ្វីទៅ? ឲ្យដើរមក ឬក៏ដឹកជញ្ជូនតាមមធ្យោបាយអីហើយមក មានក្រៅពីលោក មានអ្នកផ្សេងទៀតដែរឬទេ?

**ឆៈ** គេបញ្ជូនខ្ញុំពីមន្ទីរ១៥មកពេទ្យឆ្កួតនេះ មានគ្នាចំនួនប្រហែលជាបួន ដប់នាក់ រួចហើយគេដឹកដោយឆ្លងទន្លេហ្នឹង ។ ឆ្លងមុនដំបូង ឆ្លងទូក ចេញពីទូកមក បានគេជិះ ឲ្យដាក់ឡាន ។

**ស៖** លោកអម្បាញ់មិញអះអាងថា លោកនៅក្នុងគុកតាខ្មៅ ពេទ្យឆ្កួតតាខ្មៅហ្នឹងអស់រយៈពេលមួយខែ ដែលលោក ចុងឆ្នាំ១៩៧៦ គេបញ្ជូនលោកពីមន្ទីរ១៥មកតាខ្មៅ ហើយនៅទីនោះអស់រយៈពេលប្រហែលជាមួយខែ ក្រោយពេលគេសួរចម្លើយចំនួនបីដង ដោយបានប្រើហិង្សា វាយដំលោកផងនោះ រួចបន្ទាប់មកគេបានបញ្ជូនលោកមកកាន់មន្ទីរសន្តិសុខស-២១ ។ សួរថា ទីមួយ លោក គេត្រូវបានបញ្ជូនមកកាន់មន្ទីរសន្តិសុខស-២១ ដោយមធ្យោបាយអ្វី ហើយនៅថ្ងៃខែឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** គេដឹកខ្ញុំចេញពីមន្ទីរពេទ្យឆ្កួតមកហ្នឹង ស-២១ ហ្នឹង ដោយឡាន ។ ខែឆ្នាំ ខែថ្ងៃ ខ្ញុំមិនចាំទេ ។ នៅឆ្នាំ ក៏ខ្ញុំមិនបានចាំដែរ ។

**ស៖** ការបញ្ជូននោះ បញ្ជូនមកតែម្នាក់ឯង ឬក៏មានបញ្ជូនមកមនុស្សផ្សេងទៀត មកជាមួយលោកដែរ ពីមន្ទីរសន្តិសុខ មន្ទីរពេទ្យឆ្កួតតាខ្មៅ មកកាន់មន្ទីរសន្តិសុខស-២១?

**ឆ៖** ខ្ញុំមកតែឯង ។

**ស៖** លោកម៉េច បានជាលោកអះអាងថា ការបញ្ជូនលោកពីមន្ទីរសន្តិសុខពេទ្យឆ្កួតតាខ្មៅ មកកាន់មន្ទីរ ស-២១ ហេតុផលម៉េចបានជាលោកបញ្ជាក់ថា ការបញ្ជូនលោកនោះ គឺមកកាន់មន្ទីរសន្តិសុខស-២១? លោកស្គាល់មន្ទីរសន្តិសុខស-២១ ច្បាស់ទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ក៏ប៉ុន្តែអ្នកយាមដែលនៅកន្លែងស-២១ហ្នឹង គេប្រាប់កន្លែងហ្នឹង គុកស-២១ ។

**ស៖** គេបញ្ជូនលោកពីមន្ទីរសន្តិសុខ ដែលមានទីតាំងនៅពេទ្យឆ្កួតតាខ្មៅ មកកាន់មន្ទីរសន្តិសុខស-២១ ហ្នឹង បញ្ជូននៅពេលយប់ ឬក៏ពេលថ្ងៃ តើនៅក្នុងអំឡុងពេល ដែលគេបញ្ជូនមកហ្នឹង គេប្រព្រឹត្តចំពោះលោកយ៉ាងដូចម្តេចខ្លះ?

[០៩:៤៣:០៩]

**ឆ៖** គេបញ្ជូនខ្ញុំពេលល្ងាច ចងមុខដាក់ឡាន បានមកដល់ស-២១ បានស្រាយមុខចេញ ។

**ស៖** ពេលមកដល់ ជូនមកដល់ ស-២១ ហ្នឹង នៅវេលាម៉ោងប្រហែលជាប៉ុន្មានដែរ ហើយបែបបទ ពេលដែលមកដល់ហ្នឹង ដំបូងៗហ្នឹង តើគេធ្វើយ៉ាងម៉េច ចំពោះលោក ពួកបុគ្គលិកមន្ទីរស-២១ នេះ គេចាត់ចែងយ៉ាងម៉េចចំពោះលោក?

**ឆ៖** ពេលដែលមកដល់ស-២១នេះ អ្នកយាមគុកក៏គេអត់មានធ្វើអីយើងដែរ មកដល់ពេលល្ងាច ប្រហែលជាម៉ោងប្រាំពីរ ប្រាំបីយប់ គេអត់មានធ្វើអីយើងទេ គេដាក់ខ្នោះយើង ។

**ស៖** លោកនៅក្នុងមន្ទីរសន្តិសុខ ដែលលោកអះអាងអំមិញថា លោកបានគេបញ្ជូនពីតាខ្មៅ មកដាក់នៅក្នុងមន្ទីរសន្តិសុខស-២១ ហើយមន្ទីរសន្តិសុខស-២១ហ្នឹងគឺលោកមិនស្គាល់ទេ គឺបានឮអ្នកយាមគេអះអាង គឺគេនិយាយថា ទីនេះ គឺជាមន្ទីរសន្តិសុខស-២១ ។ លោកអាចបង្ហាញបានទេ មន្ទីរសន្តិសុខស-២១ហ្នឹង នៅកន្លែងណា? ស្គាល់ទីតាំងនៃមន្ទីរសន្តិសុខស-២១ ទេ?

[០៩:៤៥:១០]

**ឆ៖** កន្លែងស-២១ នេះខ្ញុំមិនៗបានចាំច្បាស់ទេ ក៏ប៉ុន្តែគ្រាន់តែថា ដូចខ្ញុំជម្រាបលោកតុលាការអ៊ីចឹងថា ដែលខ្ញុំទៅជាប់នៅកន្លែងហ្នឹង ពួកអ្នកយាមគេបានប្រាប់ខ្ញុំថា កន្លែងហើយជាស-២១ ។ ដល់ពេលដែលចេញហ្នឹង ខ្ញុំ ដល់ពេលដែលបញ្ជាក់ដែលៗខ្ញុំអះអាងថា ស-២១ នេះ ខ្ញុំចេញពីស-២១ នេះដែលឲ្យមកៗវិញ មកនៅព្រៃសនេះ ក៏អ្នកយាមដែលស្គាល់គ្នា ។ គេយាមៗនៅយាមគុកហ្នឹង គេប្រាប់ថាឯងកុំរត់ទៀត បើកាលរត់ទៀត ប្រយ័ត្នជាប់នៅកន្លែងនោះស្លាប់ ។ បានខ្ញុំអះអាងថា កន្លែងនេះដែលខ្ញុំជាប់ចុងក្រោយនេះជាកន្លែងស-២១ ។

**ស៖** លោកអាចនិយាយរៀបរាប់បានទេ អំពីទិដ្ឋភាពនៃទីតាំងដែលលោកបានទៅជាប់ បានន័យអះអាងលោកថាទៅជាប់នៅក្នុងមន្ទីរស-២១ ហ្នឹង ពីទិដ្ឋភាពយ៉ាងម៉េច ដែលបញ្ជាក់ ដែលលោកបានឃើញនៅៗទីនោះ? ដែលលោកនៅចងចាំនោះ ទីតាំងនៃមន្ទីរស-២១ ដែលលោកចងចាំ លោកអាចរៀបរាប់ប្រាប់ដល់អង្គសវនាការបានទេ?

**ឆ៖** គឺខ្ញុំមិនសូវបានច្បាស់ទេ ខ្ញុំមិនសូវបានច្បាស់ទីតាំង ព្រោះថាអាកន្លែងគេដាក់ហ្នឹង វាមិនសូវបានឲ្យយើងដើរហើរទៅកន្លែងណា ក៏ខ្ញុំមិនសូវបានចាំដែរ វាយូរពេលមកហើយ ។ គ្រាន់តែខ្ញុំបានគ្រាន់តែ គោលៗខ្លះដែលខ្ញុំចាំកន្លែងគេដាក់ខ្ញុំដាក់នៅរោងបាយហ្នឹង នៅជាប់នឹងអគារមួយខ្នង ។

**ស៖** លោករៀបរាប់ និយាយរៀបរាប់អំពីបទពិសោធន៍របស់លោក ចាប់តាំងពីពេលបញ្ជូនពីតាខ្មៅមកដល់មន្ទីរស-២១ ហើយនៅក្នុងអំឡុងពេលដែលលោករស់នៅក្នុងមន្ទីរស-២១ រហូតដល់ពេលត្រូវគេបញ្ជូនលោកចេញពីមន្ទីរស-២១ ទៅកាន់ព្រៃស តើលោកមានបទពិសោធន៍ ឬក៏ជួបប្រទះនូវទិដ្ឋភាពបែបណានៅក្នុងអំឡុងពេលនោះ? លោកអាចរៀបរាប់ដូច្នេះបានទេ?

**ឆ៖** សូមឲ្យលោកតុលាការមានប្រសាសន៍ម្តងទៀត ដើម្បីឲ្យខ្ញុំបានយល់ ។

**ស៖** ឥឡូវនេះ លោកនិយាយរឿងរ៉ាវដែលលោកត្រូវគេចាប់បញ្ជូនពីតាខ្មៅមកដល់មន្ទីរស-២១ ដែលលោកអះអាងអំមិញ ចាប់តាំងពីលោកមកដល់មន្ទីរ ចូលមកដល់មន្ទីរស-២១ នៅក្នុងអំឡុងពេល

ដែលលោករស់នៅហ្នឹង តើលោកមានរឿងរ៉ាវជួបប្រទះយ៉ាងទិដ្ឋភាពអ្វីខ្លះ ដែលលោកបានជួបប្រទះរហូតដល់ពេលគេបញ្ជូនលោកចេញពីមន្ទីរស-២១ ទៅមន្ទីរ ទៅព្រៃស តើលោកអាចនិយាយរឿងរ៉ាវដែលលោកបានមកនៅទីនោះជូនអង្គជំនុំជម្រះ ជូនអង្គសវនាការទាំងមូលបានស្ដាប់ បានដែរឬទេ?

**ឆ៖** តើឲ្យខ្ញុំមានយោបល់ជា ដូចជាឃើញការលំបាកវេទនាដែលរស់នៅ ឬមួយក៏គេធ្វើទារុណកម្មខ្ញុំនៅកន្លែង ស-២១ នោះ សូមលោកតុលាការ?

**ស៖** មន្ទីរបុគ្គលិកនៃមន្ទីរសន្តិសុខស-២១ បានប្រព្រឹត្តអ្វីខ្លះមកលើលោកនៅក្នុងអំឡុងពេលដែលលោកបានទៅដល់រហូតដល់ពេលគេបញ្ជូនចេញ? ទីមួយ ។ ទីពីរ គឺលោកអាចបញ្ជាក់អំពីទិដ្ឋភាពផ្សេងទៀតដែលលោកបានឃើញចំពោះទិដ្ឋភាពផ្សេងទៀត បានន័យថា ការប្រព្រឹត្តិរបស់មន្ទីររបស់បុគ្គលិកនៃមន្ទីរស-២១ ចំពោះអ្នកផ្សេងទៀតដែលលោកបានឃើញ?

**ឆ៖** ខ្ញុំសូមជម្រាបដែលទិដ្ឋភាពដែលរស់នៅស-២១នោះ គេបានធ្វើទារុណកម្មខ្ញុំ ដូចជា កំពប់ទឹកនោម ក៏គេវៃ និងជើងខ្ញុំដែលជាប់ខ្នោះដំបៅ សុំថ្នាំគេលាប ក៏គេមិនឲ្យលាប វាគ្មានថ្នាំ និងទីបីទៀតទិដ្ឋភាពដែលរស់នៅក្នុងស-២១ នោះ គឺនៅពេលដែលល្ងាចប្រហែលម៉ោងប្រាំពីរ ប្រាំបីល្ងាចអីចឹង ខ្ញុំឮសូរតែមាត់ដើរ ឮសូរតែសំឡេងស្រែកៗ ។

**ស៖** ពេលលោកមកដល់ភ្លាម ចុះពីលើឡាន តើមានការប្រគល់ទទួលរវាងកម្លាំងដែលដឹកលោកមកដល់ប្រគល់ទៅឲ្យកម្លាំងផ្សេងទៀតទេ ឬក៏កម្លាំងដែលដឹកហ្នឹងឯងបញ្ជូនលោកចូលទៅក្នុងកន្លែងរហូតដល់កន្លែងឃុំឃាំងតែម្ដង?

**ឆ៖** ពេលដែលគេដឹកខ្ញុំចុះមក គឺគេប្រគល់ឲ្យអ្នកផ្សេងទៀត ។

**ស៖** មកប្រគល់នៅកន្លែងណា? លោកចាំទេ?

**ឆ៖** នៅនឹងកន្លែងដែលខ្ញុំជាប់ហ្នឹង ។

**ស៖** ពេលដែលគេប្រគល់លោកទៅឲ្យកម្លាំងផ្សេងទៀតហ្នឹង តើមុននឹងនាំលោកទៅឃុំ ដាក់ឃុំឃាំងហ្នឹង តើគេបុគ្គលិកនៃកន្លែងនោះប្រព្រឹត្តយ៉ាងម៉េចចំពោះលោក? ធ្វើអ្វីខ្លះចំពោះលោក?

**ឆ៖** មុនដំបូងគេប្រគល់ខ្ញុំទៅឲ្យសន្តិសុខដែលនៅរស់នៅកន្លែងនោះ គឺគេអត់មានបានធ្វើស្អីខ្ញុំទេ ក៏គេបញ្ចូលយើងដាក់ខ្នោះបណ្ដោយ ។

**ស៖** ចូលដាក់ខ្នោះម៉េចទៅ បានន័យថាបញ្ចូលដាក់ខ្នោះម៉េច? បានន័យថាបញ្ចូលលោកទៅក្នុងកន្លែងអគារ ឬក៏បន្ទប់ៗ ជាប់ៗបន្ទប់ដែលថានៅក្បែររោងបាយអំមិញហ្នឹង នៅឯរោងបាយ ហើយបាន

គេដាក់ខ្នោះលោកតែម្តង អ៊ីចឹងមែនទេ?

[០៩:៥២:២៧]

**ឆ៖** គេបញ្ជូនខ្ញុំមកដល់កន្លែងរោងបាយហ្នឹងហើយ បានគេដាក់ខ្នោះយើងបណ្តោយ បានគេដាក់ខ្នោះយើងបណ្តោយ ។

**ស៖** លោកគិតមើលអាកន្លែង ដែលរោងបាយ ដែលគេដាក់ខ្នោះលោកហ្នឹង ពីកន្លែងដែលច្រកចូលទៅចម្ងាយប្រហែលប៉ុន្មានដែរ? ហើយមានការឆ្លងកាត់អ្វីផ្សេងទៀតទេ ដូចជាអគារ ឬក៏ឆ្លងកាត់នូវរបាំង ឬក៏រោងផ្សេងៗទេ មុនទៅដល់រោងបាយដែលជាកន្លែង ដែលគេឃុំឃាំងលោកនោះ?

**ស៖** ខ្ញុំមិនបានចាំច្បាស់ទេ នៅកន្លែងដែលៗគេដាក់ខ្ញុំហ្នឹង ខ្ញុំគ្រាន់បានចាំច្បាស់នៅកន្លែងហ្នឹងគេសម្រាប់យកបាយ យកមកចែកអ្នកទោសនៅកន្លែងហ្នឹង ដាក់ខ្ញុំនៅកន្លែងហ្នឹង ដែលកន្លែងខ្ញុំនៅដែលនេះហ្នឹង គឺជាប់នឹងអគារ ។ អគារហ្នឹង ។

**ស៖** ចុះសម្លៀកបំពាក់របស់លោក ពេលដែលគេបញ្ជូនមកដល់ហ្នឹង គេធ្វើយ៉ាងម៉េចចំពោះសម្លៀកបំពាក់របស់លោក ឬក៏គេយកជូនលោកទៅឃុំឃាំងតែម្តង?

**ឆ៖** ចំពោះដែលសម្លៀកបំពាក់របស់ខ្ញុំ គឺគេមិនបានប្តូរផ្លាស់ឲ្យខ្ញុំទេ គេបញ្ជូនខ្ញុំចូលទៅទាំងអ៊ីចឹង ។

**ស៖** កាលនោះលោកស្លៀកពាក់ខោអាវ យ៉ាងម៉េចដែរ?

**ឆ៖** ខោអាវខ្មៅ ។

**ស៖** កាលនោះ គេបញ្ជូនលោកមកហ្នឹង មានក្រមាជាប់មកជាមួយទេ? មានលោកមានប្រើក្រមាទេ ក្រមាសម្រាប់បង់កន្ទែ?

**ឆ៖** គឺអត់មានទេ ។

**ស៖** លោកជាប់នៅកន្លែងរោង បន្ទប់មួយដែលជិតរោងបាយ កន្លែងដែលគេចែកចាយ បែងចែកបាយទៅឲ្យដល់អ្នកទោសនុ៎ង លោកនៅទីនោះប៉ុន្មាននាក់ ឬក៏នៅតែម្នាក់ឯងទេ គេឃុំឃាំងលោកនៅទីនោះ?

**ឆ៖** នៅកន្លែងនោះ គឺគេដាក់ចំពោះដែលអ្នកទោសណាដែលឈឺធ្ងន់ ដំបៅច្រើន គេដាក់នៅកន្លែង រោងបាយហ្នឹង ។

**ស៖** អ៊ីចឹងមានន័យថា កន្លែងនោះគេដាក់អ្នកទោសហ្នឹងច្រើននាក់ មិនមែនតែលោកម្នាក់ទេ ។ ពេលដែលលោកទៅដល់ហ្នឹង តើលោកគិតមើល រកនឹកឡើងវិញមើលថា មានប្រហែលប៉ុន្មាននាក់ដែរទៅ? ដប់នាក់ ម្ភៃនាក់ ហាសិបនាក់ ប្រហែលបានហើយ ។ ប្រហែលជាប៉ុន្មាននាក់?

**ឆ៖** នៅកន្លែងដែលដាក់ខ្ញុំហ្នឹង គឺមានចំនួនប្រហែលជាដប់នាក់ជាងអីប៉ុណ្ណឹងឯង ហ្នឹងអ្នកទោស ដែលដើរលែងរួច ដាក់ខ្នោះដើរលែងរួច និងដំបៅច្រើន ឈឺ ។

**ស៖** នៅអំឡុងពេលដែលលោកនៅទីនោះ លោកត្រូវបានគេសួរចម្លើយលោកដែរឬទេ?

**ឆ៖** គេនៅទីកន្លែងនោះ គេបានហៅខ្ញុំសួរចម្លើយតែម្តងទេ ។

**ស៖** គេសួរចម្លើយលោកនៅកន្លែងណា?

**ឆ៖** ខ្ញុំមិនស្គាល់បានចាំដែរ ប៉ុន្តែ ខ្ញុំគ្រាន់តែឃើញចេញពីកន្លែងខ្ញុំទៅ ក៏ចូលនៅ នៅអគារមួយ អគារទីមួយ ហៅខ្ញុំសួរចម្លើយ ។

**ស៖** អំឡុងពេលសួរចម្លើយលោកម្តងហ្នឹង គេចំណាយពេលវេលាប្រហែលប៉ុន្មានទៅ ហើយគេសួរអំពីអ្វីខ្លះទៅ នៅក្នុងការសួរចម្លើយនោះ? ហើយអ្នកសួរចម្លើយលោកមានប៉ុន្មាននាក់?

**ឆ៖** ពេលដែលគេសួរចម្លើយខ្ញុំមានចំនួនប្រហែលជាមួយម៉ោង ទៅពីរម៉ោងប៉ុណ្ណឹង ប្រហែលជាពីរម៉ោងចុះ ។ ហើយមានអ្នកសួរចម្លើយ គឺតែម្នាក់ទេ ហើយសួរពីខ្ញុំ តើពីណាជាមេរបស់ឯង?

**ស៖** ក្នុងអំឡុងពេលគេសួរចម្លើយលោកហ្នឹង គេបានប្រព្រឹត្ត គេធ្វើយ៉ាងម៉េចចំពោះលោក?

**ឆ៖** នៅពេលដែលគេសួរចម្លើយខ្ញុំ គេសួរថា ឯងមាត់រឹងទេ-- ថាអ្អែងមាត់រឹងណាស់ អ្អែងខ្លាចទេ ក្តគោនិងខ្សែភ្លើង? ខ្ញុំក៏ឆ្លើយតទៅគេវិញ ថាខ្ញុំខ្លាច ក៏ប៉ុន្តែ ជីវិតរបស់ខ្ញុំជូនទៅលើបងឯង បងឯងអ្នករកយុត្តិធម៌ឲ្យខ្ញុំ បើបងឯងចង់សម្លាប់ខ្ញុំក៏សម្លាប់ទៅ ជីវិតខ្ញុំជូនទៅលើបងឯងហើយក៏គេឆ្លើយមកវិញ គេថា អានេះមាត់រឹងណាស់ អត់ខ្លាចក្តគោ និងខ្សែភ្លើងទេ ឯគេសួរចម្លើយខ្ញុំ ក៏គេគប់កន្ទុយបារីទៅ លើខ្ញុំមួយ និងឲ្យទឹកដោះគោដែល ទឹកដោះគោម្សៅ ដែលសល់ជាកាករឹងៗឲ្យ គប់ឲ្យខ្ញុំស៊ី ហើយគេឲ្យ ខ្ញុំស៊ីហើយ ក៏ឲ្យខ្ញុំចេញមកវិញ ។

**ស៖** ពេលគេនាំលោកទៅសួរចម្លើយហ្នឹង ពីកន្លែងឃុំឃាំងទៅសួរចម្លើយហ្នឹង គេប្រព្រឹត្តយ៉ាងម៉េចខ្លះលើលោក គេដាក់ខ្នោះដែរឬទេ? ហើយគេមានរុំមុខ ចងរុំមុខលោកដែរឬទេ? ពេលដែលបណ្តើរចេញទៅសួរចម្លើយ?

**ឆ៖** ពេលដែលគេសួរចម្លើយខ្ញុំ ដែលបណ្ដើរខ្ញុំទៅ គ្រាន់តែដាក់ខ្នោះដៃ អត់មានចងមុខ ចងអីទេ ដាក់ខ្នោះដៃខ្ញុំទៅប៉ុណ្ណឹង ។

[០៩:៥៩:៣២]

**ស៖** ចងខ្នោះដៃ ដាក់ដៃទាំងពីរទៅមុខ ឬក៏ដាក់ដៃទាំងពីរក្រពាត់ទៅខាងក្រោយ?

**ឆ៖** ដាក់មកខាងក្រោយ ។

**ស៖** ចុះពេលទៅដល់កន្លែងសួរចម្លើយមុននឹងចាប់ផ្ដើមសួរចម្លើយ គេប្រព្រឹត្តយ៉ាងម៉េចចំពោះលោក?

**ឆ៖** មកដល់កន្លែងសួរចម្លើយ គេសម្ដុតខ្ញុំថា "អ្នកណាជាអ្នកនាំឯងរត់? ពីណាជាមេរបស់ឯង?"

**ស៖** យើងមិនសួរដូច្នេះទេ ។ នុំងលោកបាននិយាយរួចហើយអម្បាញ់មិញ ។ ការប្រព្រឹត្តិហ្នឹងបានន័យថា មុននឹងគេសួរចម្លើយនាំលោកទៅដល់កន្លែងសួរចម្លើយ គេធ្វើយ៉ាងម៉េចចំពោះលោក មុនពេលគេចាប់ផ្ដើមសួរចម្លើយ ដែលលោកបាននិយាយអម្បាញ់មិញនេះ? ឬមួយក៏គេនាំទៅគ្រាន់តែអង្គុយទល់មុខគ្នាអីចឹង? លោកអង្គុយម្ខាងតុ ហើយអ្នកដែលសួរចម្លើយម្ខាងតុទល់មុខគ្នា ហើយចាប់ផ្ដើមធ្វើការសួរតែម្ដង? ឬក៏គេប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះលោក មុនពេលអ្នកសួរចម្លើយនេះចាប់ផ្ដើមសួរចម្លើយលោកនោះ?

**ឆ៖** គេអត់មានបានធ្វើអីខ្ញុំទេ គ្រាន់តែគេឲ្យខ្ញុំអង្គុយទល់មុខគ្នាហ្នឹង សួរចម្លើយខ្ញុំតែម្ដង អត់មានធ្វើអីខ្ញុំទេ ។

**ស៖** គេដោះខ្នោះដៃលោកចេញទេ?

**ឆ៖** អត់ដោះទេ ។

**ស៖** គេមានដាក់ខ្នោះជើងលោកថែមទៀតទេ?

**ឆ៖** អត់ទេ ។ ដាក់តែខ្នោះដៃប៉ុណ្ណឹង ។

**ស៖** លោកនិយាយអំមិញថា គេ-- ពេលដែលអំឡុងពេលសួរចម្លើយហ្នឹង គឺបំណងនៃការសួរហ្នឹងគឺរកបក្សពួក រកមេកើយរបស់លោក ហើយនិយាយថា លោកមាត់រឹង ។ តើគេបានប្រព្រឹត្តអំពើហិង្សាវ៉ៃតប់លើរាងកាយរបស់លោកដែរទេ ក្នុងអំឡុងពេលដែលគេសួរចម្លើយនោះ?

**ឆ៖** គេអត់មានបានវ៉ៃខ្ញុំទេ គ្រាន់តែគេសម្លុតខ្ញុំថា "ឯងខ្លាចទេក្តគោ និងខ្សែភ្លើងនេះ?" ក៏ខ្ញុំបានឆ្លើយទៅវិញថា "ខ្ញុំខ្លាចក្តគោ ខ្សែភ្លើង ប៉ុន្តែជីវិតរបស់ខ្ញុំជូនទៅលើបងឯង ។ បងឯងអ្នករកយុត្តិធម៌ឲ្យខ្ញុំ បើបងឯងចង់សម្លាប់ខ្ញុំ ក៏សម្លាប់ទៅ" ។

[១០:០២:៣៤]

**ស៖** ពេលគេនិយាយដូច្នេះហ្នឹង តើលោកបានឃើញដំបងក្តគោហ្នឹងដែរឬទេ? គេបានបង្ហាញដំបងក្តគោហ្នឹងចំពោះលោកដែរឬទេ?

**ឆ៖** ខ្ញុំបានឃើញដាក់នៅលើតុ និងបានលើកឡើងកម្លាខ្ញុំទៀតផង ។

**ស៖** ភិនភាគយ៉ាងម៉េចទៅដំបងក្តគោហ្នឹង? លោកអាចពន្យល់អង្គសវនាការហ្នឹងបានដែរទេ? លោកអះអាងថាដំបងក្តគោហ្នឹងទំហំប៉ុនណា? ពណ៌យ៉ាងម៉េច? ហើយធ្វើអំពីអ្វីទៅ?

**ឆ៖** ខ្ញុំមិនបានចាំច្បាស់ ឬមួយក៏ជាមើលច្បាស់ ប៉ុន្តែគ្រាន់តែគេអ្នកសួរចម្លើយគេប្រាប់ថាក្តគោ និងខ្សែភ្លើង ប៉ុន្តែមើលឲ្យចំទៅវាគ្រាន់តែដូចជាខ្សែតី-- ដូចជារំពាត់ដែលយើងវេញៗធ្វើដូចជាព្រ័ត្រ វេញអង្កាញ់ៗអង្គួញៗ អាហ្នឹងអ៊ីចឹង ។

**ស៖** ពេលគេសួរចម្លើយ តើអ្នកសួរចម្លើយលោកនុំងក្មេងឬក៏ចាស់ ហើយពេលដែលសួរចម្លើយហ្នឹងគេមានការកត់ត្រាទេ ហើយរបៀបកត់ត្រាគេយ៉ាងម៉េច? កត់ដោយដៃ ឬក៏កត់ដោយម៉ាស៊ីន?

**ឆ៖** អ្នកសួរមច្លើយខ្ញុំ អាយុតាមដែលខ្ញុំប៉ាន់ស្មាន ប្រហែលជាសាមសិប-- ជាងសាមសិបប៉ុណ្ណឹង ហើយនិងកត់ត្រានោះ អត់មានម៉ាស៊ីនទេ កត់ដៃ ។

**ស៖** ពេលដែលគេអ្នកសួរចម្លើយហ្នឹងនាំខ្លួនលោកត្រឡប់ទៅវិញ យកទៅដាក់កន្លែងដដែលឬក៏ដាក់កន្លែងផ្សេង?

**ឆ៖** គេសួរចម្លើយខ្ញុំហើយ យកទៅដាក់នៅកន្លែងដដែលវិញ ។

**ស៖** លោកអាចនិយាយរៀបរាប់ជូនដល់អង្គសវនាការបានទេ អំពីទីកន្លែងដែលគេដាក់ឃុំឃាំងលោកនោះ វាធ្វើអំពីអ្វីទៅ? ធ្វើអំពីថ្មបេតុង ប្រក់ស៊ីម៉ងត៍ ឬក៏ជាន់ផ្ទាល់ដីអ៊ីចឹង ឬក៏ធ្វើអំពីឈើ ហើយមានជញ្ជាំង មានបង្អួចអីដែរទេ?

**ឆ៖** កន្លែងដែលខ្ញុំជាប់នោះ គឺព័ទ្ធ-- ចាក់ជាឥដ្ឋស៊ីម៉ង់ត៍ព័ទ្ធជុំវិញ ហើយនិងដាក់បន្ទាល្ងួស និងពីលើហ៊ុមជាបន្ទាល្ងួសដែរ ។ និងចាក់-- នៅខាងក្រោមចាក់ស៊ីម៉ងត៍ ។

**ស៖** អ៊ីចឹងជារោងមួយដែលសង់ផ្ទាល់ដី ហើយគ្រាន់តែជញ្ជាំងហ្នឹងធ្វើអំពីឥដ្ឋស៊ីម៉ងត៍ ហើយខាងបាតក្រោមក៏ឥដ្ឋស៊ីម៉ងត៍ដែរ គេហៅថាចាក់បេតុង ហើយដំបូលលើប្រក់អីគេដំបូល?

**ឆ៖** ស័ង្កសី និងបន្ទាល្អស ។

[១០:០៦:៣៥]

**ស៖** រោងនោះទំហំប្រហែលប៉ុនណាទៅ រោងនុ៎ង?

**ឆ៖** រោងហ្នឹងធំដែរ ប្រហែលជាបួនដប់ម៉ែត្រអី តាមខ្ញុំស្មាន មិននេះដែរ គ្រាន់តែពាក្យថាស្មាន ប្រហែលជាបួនដប់ម៉ែត្របួនជ្រុងដែរហ្នឹង ។

**ស៖** បួនដប់ម៉ែត្របួនជ្រុងហ្នឹងថាម៉េចទៅបួនដប់ម៉ែត្របួនជ្រុង? ប្រហែលដប់ម៉ែត្របួនជ្រុងៗ ឬក៏ដប់បួនម៉ែត្របួនជ្រុង?

**ឆ៖** ប្រហែលជាដប់ម៉ែត្របួនជ្រុង ។

**ស៖** ពេលកម្លាំងសួរចម្លើយនាំលោកចេញមកសួរចម្លើយ ហើយលោកនាំចូលទៅវិញសួរចម្លើយហ្នឹង តើលោកដើរ គេបញ្ជូនដើរលោកមកតាមផ្លូ តាមវាលផ្លូអ៊ីចឹង ឬក៏មានច្រក ជាច្រកទ្វារអីតូច ឬក៏អត់មានទ្វារទេ ពីកន្លែងដែលឃុំឃាំងលោកមកកន្លែងសួរចម្លើយអត់មានទ្វារអត់មានអីទេ? ព្រោះលោកអំមិញបានបញ្ជាក់ច្បាស់ហើយថា ពេលគេនាំលោកមកសួរចម្លើយហ្នឹងមិនបានចងមុខទេ គ្រាន់តែចងដៃប៉ុណ្ណោះ ។ អ៊ីចឹងលោកអាចមើលឃើញទិដ្ឋភាពជុំវិញខ្លួនលោកនៅទីនោះ ។ លោកអាចបញ្ជាក់ចំណុចនេះបានទេ?

**ឆ៖** វាមានចន្លោះមួយនៅអែបនឹងអគារហ្នឹង នាំខ្ញុំចេញក្បែរអគារហ្នឹង ។

**ស៖** លោកនៅទីនោះមានឃើញអគារអីផ្សេងទៀតទេ ឬក៏មានតែអគារទាបមួយហ្នឹង ឬក៏មានអគារផ្សេងទៀត? ហើយបើមានអគារផ្សេងទៀត តើមានច្រើនទេនៅទីនោះ?

**ឆ៖** នៅកន្លែងនោះក៏ខ្ញុំមិនបានចាំច្បាស់ដែរ ព្រោះថាចេញ-- បញ្ចេញទៅយប់ ណាមួយខ្ញុំខ្លាចមិនបានមើលវែងឆ្ងាយដែរ ។

**ស៖** ចុះលោកអះអាងអំមិញថា គេនាំលោកទៅសួរចម្លើយនៅអគារមួយ តើអគារនុ៎ងមានកម្ពស់ប៉ុនណាទៅ? ហើយអគារនោះធ្វើអំពីឈើ ឬក៏ធ្វើអំពីថ្ម?

**ឆ៖** អគារនោះធ្វើអំពីថ្ម ខ្ញុំបានឡើងទៅមួយជាន់ ឡើង-- ព្រោះចុះ ឡើងពីដីហ្នឹងទៅ ឡើងបានមួយថ្នាក់ទៀត ខ្ញុំអាចប៉ាន់ស្មានថាមួយជាន់ ។

**ស៖** ចុះរោងបាយវិញ នៅខាងណានៃកន្លែងដែលលោកគេចាប់-- បន្ទប់ដែលៗគេចាប់យកលោកទៅឃុំឃាំង ដែលលោកអះអាងអំមិញថា ឃុំឃាំងលោកហ្នឹង តើកន្លែងរោងបាយនៅកន្លែងទិសខាងណា ហើយចម្ងាយប៉ុន្មានពីកន្លែងដែលឃុំឃាំងលោក?

[១០:១០:២៥]

**ឆ៖** ទិសខាងលិច ខាងកើត ក៏ខ្ញុំមិនបានចាំ ប៉ុន្តែគ្រាន់តែថា អគារដែលខ្ញុំជាប់ និងអគារហ្នឹងកន្លែងរោងបាយហ្នឹងគឺជាប់គ្នា ។

**ស៖** លោកជាប់នៅទីនោះប្រហែលជាប៉ុន្មានដែរ? រយៈពេលប៉ុន្មានទៅ?

**ឆ៖** ប្រហែលជាជាងមួយខែ ។

**ស៖** ចុះរបបហូបចុកវិញយ៉ាងម៉េចដែរ លោកបានទទួលរបបហូបចុកយ៉ាងម៉េចដែរ?

**ឆ៖** របបហូបនោះគឺគេមានកំណត់ឲ្យយើងមួយចាន មួយកូនចានៗ ។

**ស៖** បាយ ឬក៏បបរ? បបររាវ ឬក៏បបរខាប់?

**ឆ៖** បាយ ។

**ស៖** របបហូបចុកហ្នឹងមួយថ្ងៃប៉ុន្មានពេល? ហើយមានសម្លដែរទេ?

**ឆ៖** មួយថ្ងៃពីរពេល ។ សម្លនេះជួនកាលមានត្រកួនទៅ គល់ចេកខ្លះទៅ អត់មានសាច់មានអីទេ មានតែដូចជាត្រកួនអីហ្នឹងស្ងោរហូប ។

**ស៖** ចុះបើលោក អំឡុងពេលដែលលោកបានជាប់ឃុំឃាំងនៅទីនោះ គេមានដែលបានដោះលែងលោកឲ្យមានការហាត់ប្រាណអីដែរទេ?

**ឆ៖** អត់ទេ ។

**ស៖** ជាប់នៅទីនោះគេដាក់ខ្នោះយ៉ាងម៉េច? គេដាក់ច្រវាក់ ឬក៏ដាក់ខ្នោះឈើ ឬក៏ខ្នោះប្រភេទយ៉ាងម៉េច? ហើយគេដាក់ដៃ ឬក៏ដាក់ជើង?

**ឆ៖** ដាក់ខ្នោះកងជើង ។ អាខ្នោះរនុករង្វង់មូល គេហៅរនុក ស៊កដែកអ៊ីចេះ ។

**ស៖** លោកត្រូវបានគេដាក់ខ្នោះដោយឡែកម្នាក់ឯង ឬក៏ដាក់ខ្នោះរួមជាមួយនឹងអ្នកដទៃ ជាប់គ្នាជាមួយនឹងអ្នកដទៃ? ហើយបើដាក់ជាមួយនឹងអ្នកដទៃ មួយស្ទួហ្នឹងមានប៉ុន្មាននាក់ដែរ?

**ឆ៖** ដាក់ជាមួយគ្នាមានចំនួនប្រហែលបួនដប់នាក់ប៉ុណ្ណឹង ។

**ស៖** ដាក់ខ្សែជួរអ៊ីចឹង ?

**ឆ៖** បាទ, រន្ទុករុក ។

**ស៖** អ៊ីចឹង ។ ក្នុងមួយស្នួហ្នឹងមានប្រហែលដប់នាក់ ។ ចុះដែលនិយាយពីរឿងងូតទឹកនៅអំឡុងពេលលោកជាប់ឃុំឃាំងហ្នឹង លោកបានទទួលការអនុញ្ញាតឲ្យទៅងូតទឹកដែរទេ ចេញទៅងូតទឹកដែរទេ? ហើយទៅងូតទឹកនៅកន្លែងណា? ប៉ុន្មានថ្ងៃងូតទឹកម្តង ឬក៏ងូតរាល់ថ្ងៃ?

[១០:១៤:២៧]

**ឆ៖** បីថ្ងៃគេឲ្យងូតទឹកម្តង ។

**ស៖** គេឲ្យងូតទឹកនៅកន្លែងណាទៅលោក? គេនាំចេញក្រៅ ឬក៏ក្នុងហ្នឹងមានបន្ទប់ទឹក?

**ឆ៖** គេនាំចេញក្រៅ ។

**ស៖** ពេលលោកទៅងូតទឹកដែលនាំចេញទៅក្រៅហ្នឹង គឺមានចម្ងាយប៉ុន្មានពីកន្លែងដែលបន្ទប់ឃុំឃាំងលោកហ្នឹង? ហើយគេដោះខ្នោះចេញដែរទេ ពេលដែលលោកអនុញ្ញាតឲ្យទៅងូតទឹកនោះ?

**ឆ៖** នៅជិតកន្លែងហ្នឹងដែរ ហើយគេដាក់ខ្នោះដៃ គេដាក់ខ្នោះបណ្តើរទៅ ។

**ស៖** ពេលងូតទឹកគេដាក់ខ្នោះដែរ ឬក៏យ៉ាងម៉េចដាក់ខ្នោះដៃដែរ?

**ឆ៖** ពេលដែលបណ្តើរយើងទៅ រួចដល់ពេលដែលយើងមុជទឹកគេដោះខ្នោះចេញ ។

**ស៖** ចុះពេលទៅជុះនោមអី ជុះនោមយ៉ាងម៉េចទៅ?

**ឆ៖** ពេលដែលជុះនោមនោះ មិនបានទៅជុះឯណាឆ្ងាយពីកន្លែងដេកហ្នឹងទេ នៅកន្លែងដេកយើងមួយហ្នឹង គឺមានដាក់ឡាំងកែសគ្រាប់ឲ្យយើងបត់ដៃ បត់ជើងតូច បត់ជើងធំ និងហូបបាយដេករស់នៅកន្លែងហ្នឹង ជាមួយគ្នា ដល់រយៈដែលពេញទៅបានគេឲ្យយកចោល ។

**ស៖** អ្នកណាជាអ្នកយកលាមក ឬក៏កែសទឹកនោមហ្នឹង កែសលាមក កែសទឹកនោមហ្នឹងចាក់ចោល?

**ឆ៖** អ្នកយាមគុកហ្នឹង បញ្ជាឲ្យពួកអ្នកជាប់គុកហ្នឹង ប្តូរផ្លាស់វេនគ្នាបញ្ជូនយកចាក់ចោលម្តងម្នាក់ ។

**ស៖** ក្រៅពីនេះ លោកមានឃើញកត់សម្គាល់ទិដ្ឋភាពអ្នកផ្សេងទៀត ដែលជាប់ឃុំឃាំងជាមួយលោកហ្នឹង មានចំនួនប្រហែលជាប៉ុន្មានទៅ? ជាប់នៅទីនោះប្រហែលជាប៉ុន្មាននាក់ សរុបដែលអំឡុងពេលដែលលោកទៅដល់ទីនោះ? ហើយលោកមានឃើញទិដ្ឋភាពអ្នកផ្សេងទៀតហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ដែលនៅកន្លែងនោះ ក៏ខ្ញុំឃើញទិដ្ឋភាពដែលអ្នករស់នៅកន្លែងនោះ គឺមានសភាពលំបាកវេទនា ដល់ឈឺ ហើយនិងដំបៅ អ្នកខ្លះក៏ជាប់ខ្នោះដើរលែងរួច អ្នកខ្លះក៏ស្គម អ្នកខ្លះទៅក៏ស្លាប់នៅហ្នឹងកន្លែងហ្នឹង ។

**ស៖** លោកបានឃើញផ្ទាល់អ្នកដែលស្លាប់នៅទីនោះ ក្នុងអំឡុងពេលដែលលោកបានទៅជាប់ឃុំឃាំងនៅនៅទីនោះ ប្រហែលជាអ្នកស្លាប់ប៉ុន្មាននាក់ទៅ? ហើយស្លាប់ដោយសារហេតុអី?

**ឆ៖** អ្នកស្លាប់នៅកន្លែងនោះ គឺខ្ញុំបានឃើញតែម្នាក់ទេ ស្លាប់ដោយឈឺ ។

**ស៖** ចុះលោកឃើញការចាត់ចែងរបស់បុគ្គលិកមន្ទីរស-២១ ចំពោះអ្នកស្លាប់ហ្នឹងយ៉ាងដូចម្ដេច?

[១០:១៨:២៨]

**ឆ៖** ខ្ញុំអត់យល់ សូមលោកតុលាការជម្រាប ។

**ស៖** ក្រោយពេលមានមនុស្សស្លាប់ សួរថាបុគ្គលិកហ្នឹងគេចាត់ចែងមនុស្សយ៉ាងម៉េច? មនុស្សស្លាប់ហ្នឹង អាខ្មោចដែលស្លាប់ហ្នឹងណា?

**ឆ៖** ចំពោះបុគ្គលិកដែលនៅកន្លែងស-២១ ចំពោះដែលមនុស្សស្លាប់ហ្នឹ គឺឃើញគេបញ្ជូនយកចេញ ។

**ស៖** ស្លាប់ហ្នឹង ស្លាប់ភ្លាមគេយកចេញភ្លាម ឬក៏ស្លាប់ហ្នឹងអំឡុងពេលយូរច្រើនម៉ោង ឬក៏មួយពេល មួយព្រឹក ឬមួយថ្ងៃអីចឹងបានគេយកចេញ ឬក៏មួយយប់ទល់ភ្លឺអីចឹងបានគេយកចេញ ឬក៏ពេលស្លាប់ភ្លាមគេយកចេញភ្លាម?

**ឆ៖** ស្លាប់ភ្លាមគេយកចេញភ្លាម ។

**ស៖** ចុះទិដ្ឋភាពផ្សេងទៀត ក្រៅពីមានអ្នកទោសស្លាប់ហ្នឹង តើលោកមានឃើញទិដ្ឋភាពផ្សេងទៀតទេ ក្រៅពីអ្នកទោសស្លាប់ហ្នឹង ដូចជាការប្រព្រឹត្តនូវអំពើផ្សេងៗរបស់បុគ្គលិកនៅទីនោះចំពោះអ្នកដែលទោសផ្សេងទៀត ដែលលោកបានឃើញ? មានទេ មានបានឃើញទិដ្ឋភាពផ្សេងទៀតទេ?

**ឆ៖** គឺខ្ញុំបានឃើញ ទិដ្ឋភាពផ្សេងទៀតដូចជា ឡាំង កែសគ្រាប់ ដែលគេដាក់ឲ្យបន្ទោបង់ហ្នឹង គឺបានកំពប់គេវ៉ៃ ឬមួយក៏ហូបហ្នឹង ឬមួយក៏និយាយស្ដីគ្នាឮៗក៏គេមិនឲ្យយើងនិយាយដែរ គេឡើងមកវ៉ៃយើង ។

**ស៖** និយាយត្រលប់ក្រោយបន្តិចអំមិញ ដូចជាប៉ងថានឹងសួរពេលក្រោយ ប៉ុន្តែឥឡូវដោយសួរលម្អិតហើយ សួរក្រោយបន្តិច ។ សំណួរសួរ ពេលដែលលោកនៅតាខ្មៅហ្នឹង លោកចូលទៅដល់តាខ្មៅ

ហ្នឹងមានមនុស្សអ្នកទោសច្រើននាក់ដែរឬទេនៅទីនោះ? ឬក៏ទៅតែប៉ុន្មាននាក់ដែលបញ្ជូនមកជាមួយលោកប្អូនដប់នាក់នោះទេ? ឬក៏មកដល់មានមនុស្សនៅទីនោះច្រើននាក់?

**ផ៖** ដែលមន្ទីរពេទ្យឆ្កួតតាខ្មៅនោះ គឺមានជាច្រើន មនុស្សច្រើន មនុស្សច្រើននាក់ ។

**ស៖** សុទ្ធតែត្រូវជាប់ឃុំឃាំង ជាប់ខ្នោះនៅក្នុងអគារ ឬក៏គេដោះលែង?

**ផ៖** ជាប់នឹងអគារ ។

**ស៖** អំមិញលោកបាននិយាយដល់ចំណុច នៃការដែលលោករស់នៅនៅក្នុងមន្ទីរស-២១ ដែលលោកអះអាង ហើយទិដ្ឋភាពនានា ក្រៅពីការប្រព្រឹត្តរបស់បុគ្គលិកស-២១ ចំពោះលោកគឺ លោកបានឃើញទិដ្ឋភាពផ្សេងទៀត ចំពោះបុគ្គលិកនៅទីនោះបានប្រព្រឹត្តចំពោះអ្នកទោសផ្សេងទៀត ។ សំណួរបន្តសួរថា តើលោកចាកចេញពីមន្ទីរស-២១ហ្នឹងនៅថ្ងៃខែឆ្នាំណា? បានចាំទេ? ហើយចេញនៅពេលព្រឹកឬក៏ពេលល្ងាច? ហើយមូលហេតុអ្វីបានជាលោកបានចាកចេញពីទីនោះ?

[១០:២២:00]

**ផ៖** ថ្ងៃខែឆ្នាំ ក៏ខ្ញុំមិនបានចាំ ។ ប៉ុន្តែ បានដោះលែងដោយគេសួរចម្លើយខ្ញុំ រួចហើយហ្នឹងក៏ខ្ញុំបានចេញពីហ្នឹង ។ ចេញពីមន្ទីរហ្នឹងមកនៅព្រៃស គេបញ្ជូនមកព្រៃសនេះវិញ ។

**ស៖** លោកត្រូវគេបញ្ជូនចេញពីទីនោះ មកព្រៃសហ្នឹង បញ្ជូនតែម្នាក់ឯង ឬក៏ច្រើននាក់? ហើយបញ្ជូនពេលយប់ ឬក៏ពេលថ្ងៃ? ដោយមធ្យោបាយអ្វីទៅ?

**ផ៖** គេបញ្ជូនមកពេលល្ងាច ហើយនិងដាក់ឡានមកវិញ តែម្នាក់ឯង ។

**ស៖** លោកចាំទេ ពេលដែលគេបញ្ជូនលោកចូលហ្នឹង ចូលទៅមន្ទីរស-២១ ចូលតាមច្រកខាងណា? ពីទិសខាងណា? ហើយដល់ពេលលោកចេញវិញ គេបញ្ជូនលោកចេញពីមន្ទីរសន្តិសុខស-២១នេះគេបញ្ជូនចេញតាមច្រកណា? ច្រកដដែលដែលលោកចូល ឬក៏ច្រកផ្សេង?

**ផ៖** ចេញហើយនិងចូល គឺខ្ញុំមិនបានចាំ ព្រោះគេចងមុខ ។ ចូលក៏ចងមុខ ចេញក៏ចងមុខ ។

**ស៖** លោកទៅនៅមន្ទីរ-- នៅព្រៃសហ្នឹងលោកនៅចំណុចណា លោកចាំទេ?

**ផ៖** នៅព្រៃសនោះ ខ្ញុំមិនបានចាំនៅចំណុចណាទេ ក៏ប៉ុន្តែដឹងថានៅកន្លែងហ្នឹងព្រៃស គេឲ្យទៅជីកប្រឡាយ យប់ឡើងគេបញ្ជូនមកដាក់ខ្នោះវិញ ។

**ស៖** ដាក់ខ្នោះនៅឯព្រៃសនុ៎ង ឬក៏បញ្ជូនមកខ្នោះនៅឯស-២១?

**ផ៖** ដាក់នៅព្រៃស ។

**ស៖** ក្រៅពីជីប្រឡាយ គេឲ្យធ្វើ-- លោកធ្វើអ្វីផ្សេងទៀតទេ?

**ឆ៖** គេអត់ឲ្យមានធ្វើអីទេ ឲ្យជីកតែប្រឡាយរហូតតាំងពីធ្វើរហូត ដល់ពេលដាក់ខ្នោះវិញ ។

**ស៖** លោកចេញធ្វើជីកប្រឡាយហ្នឹង ជីកពីម៉ោងប៉ុន្មាន រហូតដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** ពីម៉ោងបួន ទៅរហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់ ។ ពេលម៉ោងមួយទៅរហូតដល់ម៉ោងប្រាំបានហូបបាយ ។ ពីម៉ោងប្រាំ ទៅដល់ម៉ោងប្រាំយប់ ម៉ោងដប់យប់ ។

[១០:២៥:៥៣]

**ស៖** ហើយក្រោយពីធ្វើការ ហើយត្រលប់មកវិញត្រូវគេដាក់ខ្នោះ នៅពេលយប់នេះតែលោកម្នាក់ទេ ឬក៏មនុស្សទាំងអស់នៅ-- ដែលត្រូវធ្វើការ ឬក៏ប្រើពាក្យថា អ្នកទោសនៅព្រៃសនោះ សុទ្ធតែបានខាងបុគ្គលិកនៅកន្លែងព្រៃសហ្នឹង ប្រព្រឹត្តដូចៗគ្នាគឺដាក់ខ្នោះនៅពេលយប់ទាំងអស់គ្នា?

**ឆ៖** ដាក់ខ្នោះទាំងអស់គ្នា ។

**ស៖** ចុះមនុស្សស្រី ឬនិងកុមារ គេដាក់ខ្នោះដែរឬទេ?

**ឆ៖** មនុស្សស្រីក៏គេដាក់ ។ ដាក់ដូចគ្នាហ្នឹង ។

**ស៖** ចុះកុមារគេដាក់ទេ? លោកមានឃើញកុមារទេនៅព្រៃស?

**ឆ៖** អត់បានឃើញទេ ។ ឃើញតែមនុស្សស្រី ។

**ស៖** ខ្នោះដែលគេដាក់ហ្នឹង គេដាក់យ៉ាងម៉េច? គេដាក់ខ្នោះជើង ដូចដែលលោកជាប់នៅមន្ទីរ-- លោកអះអាងថា ជាប់នៅមន្ទីរស-២១ ឬក៏ដាក់ខ្នោះមានលក្ខណៈដោយឡែកពីមន្ទីរស-២១? គេដាក់ខ្នោះជើង ឬក៏គេដាក់នៅក្នុងអគារ ហើយគេចាក់សោពីក្រៅ?

**ឆ៖** អាហ្នឹងគេដាក់ក្នុងជើងក្នុងអគារ ហើយគេដាក់ខ្នោះថែមទៀត ។

**ស៖** អ៊ីចឹង បានន័យថា ដាក់ទៅក្នុងអគារហ្នឹង គេដាក់ខ្នោះជើង ដាក់ជើងតម្រៀបគ្នាដូចនៅស-២១ ។ ហើយចំណែកឯ អគារហ្នឹងគេធ្វើរបង-- គេធ្វើជញ្ជាំងបិទជិតព័ទ្ធជុំវិញ ហើយទ្វារចេញចូលហ្នឹងក៏គេចាក់សោពីក្រៅដែរ? អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** លោកនៅទីនោះអស់រយៈពេលប្រហែលជាប៉ុន្មានទៅ?

**ឆ៖** ខ្ញុំនៅព្រៃសបានប្រហែលជាមួយខែ ជាងមួយខែប៉ុណ្ណឹង ។

**ស៖** ចុះលោកចាកចេញពីព្រៃស តាមដោយរបៀបណា?

**ឆ៖** ពេលដែលខ្ញុំចេញពីព្រៃសនោះ ពេលល្ងាចដែលមកគេវ៉ៃអាគាំងហូបបាយពេលល្ងាចនោះ ជិតយប់ហ្នឹង ។ ក៏ខ្ញុំសម្រេចចិត្តថា ខ្ញុំរត់ បើកាលណាខ្ញុំនៅក៏ស្លាប់ ។ បើខ្ញុំរត់ក្រែងលោរួចខ្លួន ក៏ខ្ញុំដាច់ចិត្តរត់បបួលមួយដែលនៅជាមួយនោះ ថាអ្នែងរត់ទេ? មួយហ្នឹងគេថា គេអត់ប៊ានរត់ ខ្លាចជាប់ម្តងទៀត ក៏ខ្ញុំថា បើឯងមិនប៊ានរត់ ទុកអញអ្នករត់ ប៉ុន្តែបើពីណាសួរអញ ឆ្លើយថា អញឈឺអាចម៍ ។ ខ្ញុំក៏បាន ខ្ញុំក៏រត់ចេញ យកខ្សែគោមួយកន្ទុយ ដងរែកមួយ ក៏សម្រេចចិត្តរត់ឆ្លងព្រែកហូរ ហែលឆ្លងស្ទឹងព្រែករួចទៅ ក៏ឮស្នូរសំឡេងស្រែក ព័ទ្ធៗអ៊ីចឹងទៅ ខ្ញុំក៏បានចន្លោះពេលហ្នឹងយប់ ពេលព្រលប់ហើយយប់ទៅក៏ខ្ញុំបានគេចខ្លួនរួច ។

[១០:២៩:៥៥]

**ស៖** លោកហែលឆ្លងរត់គេច ហែលឆ្លងព្រែកហូរ លោកធ្វើដំណើរទៅកាន់ទីណាទៅ?

**ឆ៖** ខ្ញុំដើរតម្រង់កាត់ទៅខាងត្បូងអ៊ីចឹង ខ្ញុំស្គាល់ភ្នំជីសូរ ។ ខ្ញុំដើរតម្រង់ភ្នំ ដើរតែពេលយប់ទេ ពេលថ្ងៃអត់ប៊ានដើរដេក ។ យប់ហ្នឹងក៏ដើរបានទៅឃើញខែភ្លឺ ឃើញដើមព្រីង ក៏បេះព្រីងដាក់ខ្ទុះហូប អ៊ីចឹងរហូតទៅ ដើរបីយប់ ពេលថ្ងៃខ្ញុំដេក ពួនក្នុងព្រៃ ។

**ស៖** ហើយលោកទៅដល់គោលដៅណា?

**ឆ៖** ទៅដល់គោលដៅភ្នំជីសូរ ក៏ខ្ញុំដើរតម្រង់ស្គាល់ភូមិសាស្ត្រជាប់ហ្នឹង គឺចំផ្ទះខ្ញុំ ។ ព្រោះខ្ញុំដើរតម្រង់មកខាងកើត មកកោះធំនេះវិញ ។

**ស៖** អ៊ីចឹង បានសេចក្តីថា ក្រោយពេលបាន-- លោកបានរត់គេចខ្លួនចេញពីព្រៃស លោកធ្វើដំណើរឆ្ពោះទៅផ្ទះរបស់លោក ដែលមានទីតាំងនៅស្រុកកោះធំ ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** លោកទៅរស់នៅនៅក្នុងស្រុក-- លំនៅដ្ឋានរបស់លោកនៅស្រុកកោះធំហ្នឹង ឬក៏លោកចាកចេញពីហ្នឹងទៅរស់នៅកន្លែងណាទៀត?

**ឆ៖** ខ្ញុំរស់នៅនឹងកោះធំហ្នឹងបណ្តោយ អត់មានចាកចេញទៅកន្លែងណាទេ ។

**ស៖** លោករកនឹកទៅមើល លោកទៅដល់សហករណ៍ ទៅដល់កន្លែងលំនៅដ្ឋានរបស់លោកនៅប្រហែលជាថ្ងៃខែ ឬក៏ឆ្នាំណាជាក់លាក់ទេ ប្រហែលជាឆ្នាំណាទៅដល់ទីនោះ?

**ឆ៖** ខ្ញុំមិនបានចាំឆ្នាំទេ ប៉ុន្តែខ្ញុំនៅអត់បានចាំឆ្នាំ ខ្ញុំក៏អត់មានចាកចេញពីស្រុកកំណើតរបស់ខ្ញុំទេ ខ្ញុំនៅហ្នឹងរហូត ។

**ស៖** អ៊ីចឹងលោកនៅទីនោះ រហូតដល់ថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ មែនទេ?

**ឆ៖** បាទ ។

**ស៖** ចុះពេលដែលលោកទៅចូលនៅក្នុងភូមិ លំនៅដ្ឋានរបស់លោកវិញហ្នឹងតើខាងសហករណ៍មូលដ្ឋានហ្នឹង គេមានចាត់វិធានការយ៉ាងម៉េចចំពោះលោកដែរទេ?

**ឆ៖** ពេលដែលខ្ញុំរត់ទៅដល់មូលដ្ឋានវិញ ខ្ញុំនៅពួននៅលើផ្ទះអស់រយៈប្រហែលជាមួយខែ ។ ឈឺផងអីផង ហើម ហើយនិងរស់នៅលំបាក ឪពុករបស់ខ្ញុំគាត់ខ្លាចគេរកឃើញ ក៏គាត់បានទៅជម្រាបគណៈឃុំ ។ គណៈឃុំហ្នឹងកាលពីដើម គាត់រស់នៅជាមួយឪពុកខ្ញុំ តាំងពីតូចមក ។ ដល់ពេលអាពតហ្នឹង ក៏គាត់បានធ្វើឃុំ ។ ដល់បានធ្វើឃុំក៏ខ្មោចឪពុកខ្ញុំហ្នឹង ក៏គាត់បានទៅជម្រាបពួកឃុំហ្នឹងថា ឥឡូវវារត់មកដល់ផ្ទះហើយ អ្វែងគិតធ្វើម៉េច? ក៏គណៈឃុំហ្នឹង ក៏បានប្រាប់ទៅវិញថា "បងឯទៅភ័យអី ឲ្យវានៅទៅពីណាមកសួររក ខ្ញុំឆ្លើយថាមិនដឹងទៅ វាចប់ហើយ ។ បើអត់អង្ករស៊ីចាំខ្ញុំឲ្យសេដ្ឋកិច្ចយកអង្ករឲ្យស៊ី" ។ បានខ្ញុំបាទបានខ្ញុំបាទរួចខ្លួន ។

[១០:៣៣:៥៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ហើយបន្តដំណើរការសវនាការ ។ មន្ត្រីតុលាការ សម្របសម្រួលរកកន្លែងសមរម្យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបានសម្រាក ។ ហើយឲ្យអញ្ជើញគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងដប់មួយខ្វះដប់នាទី ។

*[សវនាការសម្រាកពីម៉ោង ១០:៣៥នាទី ដល់ម៉ោង ១១:០១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក លី ហ៊ា ឥឡូវនេះអង្គជំនុំជម្រះសួរបញ្ជាក់ អំពីសាវតាររបស់លោកឲ្យបានច្បាស់

លាស់ឡើងវិញ ។ ដូចជាមានចំណុចជាច្រើនមានបញ្ហាដែលត្រូវសួរបញ្ជាក់ ។ លោក ឈ្មោះ លី ហ៊អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** ថ្ងៃខែឆ្នាំកំណើតរបស់លោក លោកកើតថ្ងៃខែឆ្នាំណា? ចាំទេ?

**ឆ៖** ខ្ញុំអត់បានចាំ ។

**ស៖** ហើយឆ្នាំនេះលោកអាយុប៉ុន្មាន?

**ឆ៖** ៥៧ឆ្នាំ ។

**ស៖** កាលពីឆ្នាំ១៩៧៥ ហ្នឹងលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំអត់បានចាំ ។

**ស៖** ឪពុករបស់លោកឈ្មោះអ្វី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ អ៊ា ចុងលី ។

**ស៖** ឈ្មោះអ្វី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ អ៊ា ចុងលី ។

**ស៖** ចុះម្តាយរបស់លោកឈ្មោះអ្វី?

**ឆ៖** ម្តាយខ្ញុំបាទឈ្មោះ សៀន ម៉ៅ ។

**ស៖** ឪពុកម្តាយរបស់លោកទទួលមរណភាពហើយ ឬក៏នៅរស់-- នៅមានជីវិតរស់នៅសព្វថ្ងៃ?

**ឆ៖** ឪពុកម្តាយខ្ញុំបាទស្លាប់អស់ហើយ ។

**ស៖** ប្រពន្ធរបស់លោកឈ្មោះអ្វី?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាទឈ្មោះ ឡៅ គឹមស្រ៊ី ។

**ស៖** សព្វថ្ងៃគាត់នៅឯណា? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** សព្វថ្ងៃរស់នៅបន្ទុកគ្រួសារជាមួយនឹងខ្ញុំនៅខេត្តបន្ទាយមានជ័យ មុខរបររកស៊ី លក់ដូរ ។

**ស៖** លោកនិងប្រពន្ធរបស់លោកហ្នឹងមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូនប្រាំនាក់ ។

**ស៖** ទីកន្លែងកំណើតរបស់លោក តើលោកកើតនៅទីកន្លែងណា? នៅភូមិអី? ឃុំអី? ស្រុកអី?

**ឆ៖** ភូមិកំណើតកើតរបស់ខ្ញុំបាទ នៅស្រុកកោះធំ ខេត្តកណ្តាល ឃុំព្រែកស្តី ភូមិព្រែកស្តី ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ សូមបញ្ចាំងនូវឯកសារដែលមានលេខ ERN 00280015 ជាភាសាខ្មែរនៅលើកញ្ចក់ទូរទស្សន៍ ។

មន្ត្រីតុលាការសម្របសម្រួលបញ្ហាសោតទស្សន៍ ខ្ញុំអត់មើលឃើញ-- ចៅក្រមទាំងអស់អត់មានឃើញទេ ។

[១១:០៧:៣៧]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក លី ហ៊ា នៅលើឯកសារនេះ លោកជាអ្នកសរសេរដោយខ្លួនលោក ឬក៏លោកពឹងអ្នកណាឲ្យសរសេរនៅឯកសារដែលនៅពីមុខលោកនេះ?

**ឆ៖** អ្នកសួរចម្លើយខ្ញុំ សរសេរ ។

**ស៖** អ្នកសួរចម្លើយលោកពីអង្កាល់សរសេរនេះ?

**ឆ៖** ខ្ញុំចាំបានពេលដែលគេសួរចម្លើយខ្ញុំ គឺសរសេរ ។

**ស៖** គេសួរចម្លើយលោកនៅកន្លែងណា?

**ឆ៖** ខ្ញុំសូមទោសលោកតុលាការ ។ ខ្ញុំមិនបានទាន់នេះ-- ពិនិត្យមើលអក្សរនេះច្បាស់ ។ អក្សរនេះ គឺខ្ញុំមិនបានសរសេរខ្លួនឯងទេ ប៉ុន្តែដែលខ្ញុំបានមើលក្នុងអក្សរនេះគឺដូច អក្សរដែលសួរចម្លើយខ្ញុំអម្បាញ់មិញ ។

**ស៖** អក្សរនេះលោកសរសេរដោយខ្លួនលោក ឬក៏លោករកគេឲ្យជួយសរសេរ?

**ឆ៖** ខ្ញុំមិនបានសរសេរខ្លួនឯងទេ ។

**ស៖** លោករកអ្នកណាឲ្យជួយសរសេរ? ហើយការសរសេរនឹងនៅកន្លែងណា? សរសេរពីពេលណាមក?

**ឆ៖** ខ្ញុំចាំមិនបាន ។

**ស៖** នៅក្នុងការផ្ដល់ព័ត៌មានទាក់ទងនឹងបទឧក្រិដ្ឋកម្មដែលលោកបានមើលនៅក្នុងកញ្ចក់ទូរ-ទស្សន៍នេះ តើការសរសេរនឹង វាសម្ដែងពីការពិតដែលរឿងរ៉ាវរបស់លោក ដែលលោកបានឆ្លងកាត់នៅក្នុងរបប ប៉ុល ពត ពិតមែនដែរទេ?

**ឆ៖** គឺពិតមែន ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាននៅព័ត៌មាន ទាក់ទងនឹងឧក្រិដ្ឋកម្មនៅកញ្ចក់ទូរទស្សន៍នេះ ។ តែពីរទំព័រទេ ទំព័រការពារខ្លួនហ្នឹង ពីរទំព័រ ។ ទំព័រទីមួយ និងទីពីរ ។

[១១:១០:៥២]

**លោកស្រី សែ កុលវុឌ្ឍី៖**

ព័ត៌មានទាក់ទងឧក្រិដ្ឋកម្ម៖ ដើមឆ្នាំ១៩៧៦ ខ្ញុំ លី ហ៊ា ត្រូវបានចាប់បញ្ជូនទៅទួលស្លែង ។ ការបញ្ជូននេះគឺ បញ្ជូនពីមន្ទីរ១៥ មកដាក់នៅតាខ្មៅ ។ បន្ទាប់មកបញ្ជូនបន្តមកទួលស្លែងដោយដាក់តាមឡានឃ្លុបនៅពេលព្រលប់ ។ ខ្ទង់ម៉ោងប្រហែលប្រាំពីរយប់ ពេលមកដល់ទួលស្លែងដាក់ឃុំឃាំង ដោយដាក់ខ្នោះជើងនៅក្នុងបន្ទប់ដែលហ៊ុមព័ទ្ធដោយរនាំងដែក ។ ជាប់ឃុំនៅក្នុងបន្ទប់មួយយប់មួយរហូតដល់ពេលយប់វិញទើបអ្នកធ្វើការនៅគុក បានមកយកចេញទៅសួរចម្លើយនៅក្នុងបន្ទប់សួរចម្លើយ ។ ក្នុងពេលសួរចម្លើយ អ្នកសួរចម្លើយបានសម្លុតឲ្យខ្ញុំឆ្លើយដល់ហើយ យើងមិនឆ្លើយ អ្នកចម្លើយយកដំបងក្តគោរាងក្រម៉ៅក្បាលប្រវែង ប្រហែលកន្លះម៉ែត្រ ទំហំធំជាងមេជើងបន្តិចមកវ៉ៃលើខ្នង ដើមទ្រូង និងដើមដៃខាងឆ្វេង ។ សព្វថ្ងៃនេះដៃខាងឆ្វេងប្រើការធ្ងន់អត់បានទេ ។ រាល់លើកនៅពេលដែលអ្នកសួរចម្លើយយកទៅសួរចម្លើយត្រូវវ៉ៃរាល់លើក រយៈពេលជាប់នៅក្នុងគុកទួលស្លែងត្រូវបានអ្នកសួរចម្លើយសួរចំនួនបីលើក នឹងត្រូវវ៉ៃនឹងក្តគោទាំងបីលើក ។ ពេលមិនសួរចម្លើយគឺ អ្នកយាមគុកដាក់ខ្នោះជើងរហូតទោះពេលយប់ដេក ក៏ដាក់ខ្នោះជើងជាខ្សែៗជាមួយអ្នកផ្សេងទៀតពីដប់ទៅដប់ប្រាំនាក់ ក្នុងមួយខ្សែៗ ។ ខ្នោះនោះគឺជាប់នឹងជើងរហូតទាំងម្ភៃបួនម៉ោង ។ នៅពេលទៅមុជទឹក គឺដាក់ខ្នោះដៃ ក្នុងរយៈពេលបីថ្ងៃអ្នកយាមបណ្តើរឲ្យទៅមុជទឹកម្តង ។ ពេលហូបចុកបន្ទោរបង់តូចធំ គឺនៅក្នុងបន្ទប់ឃុំឃាំងនោះតែម្តងហើយជាប់ខ្នោះរហូត ។

ខ្ញុំបានជាប់នៅក្នុងគុកទួលស្លែងរយៈពេលជាងមួយខែ ។ ពេលជាប់ខ្នោះជើងនៅក្នុងបន្ទប់ឃុំឃាំងតាំងពីពេលដេក អង្គុយហូបចុក បន្ទោបង់តូចធំ គឺអ្នកយាមគុកមិនអនុញ្ញាតឲ្យនិយាយគ្នាទៅវិញទៅមកមិនឲ្យឮសូរសំឡេងដែកខ្នោះឡើយ ។ បើសិនជាឮសំឡេងអ្នកយាមមកវ៉ៃនឹងដំបូងក្តគោរហូតអស់ចិត្តអ្នកយាម ។

[១១:១៤:១២]

ក្នុងរយៈពេលឃុំឃាំងនៅគុកទួលស្លែង នៅក្នុងបន្ទប់ឃុំឃាំងមានក្លិនស្អុយ ផ្អេះផ្អាប ដោយ

លាមកទឹកនោម គឺអ្នកយាមទុកក្នុងបន្ទប់រហូតរយៈពេលបីថ្ងៃ ទើបគេយកទៅចាក់ចោលម្តង ។ ពេលហូបបាយទឹក គឺនៅជាមួយនឹងលាមក ទឹកនោមពេញបន្ទប់ ។ រយៈពេលជាប់ខ្នោះនោះ គឺដំបៅរលួយនៅកន្លែងកជើងជាប់ខ្នោះ និងដំបៅនៅពេញខ្លួន ដោយសារចៃសាច់ខាំ-- សត្វខាំរមាស់ពេញខ្លួនរហូតដល់ដំបៅពេញខ្លួន ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្តាប់បានហើយព្រោះបញ្ហាយើងបានសួរសំណួររួចហើយ ហើយលោកបានឆ្លើយនូវសំណួរមួយចំនួនដែលមានបញ្ហា ។ អម្បាញ់មិញនេះគឺសំណួរត្រង់ថា បញ្ហាដែលសួរលោកគឺសំណួរដែលអ្នកនាំទៅសួរលោកបានតែម្តងគត់ ហើយសួរប្រហែលជាយ៉ាងច្រើនពីរម៉ោងប៉ុណ្ណោះ ។ លោកនិយាយដំបូងថា មួយម៉ោង ហើយក្រោយមកអះអាងថា ពីរម៉ោង យ៉ាងយូរគឺត្រឹមពីរម៉ោងទេ។ ទីពីរមិនមានការប្រើអំហិង្សាមកលើលោកទេ ដោយសារគ្រាន់តែប្រើពាក្យសម្តីគំរាមកំហែង ដោយចង្អុលទៅដំបងក្តគោ ឬក៏ខ្សែគោប៉ុណ្ណោះ ។ ប៉ុន្តែ នៅក្នុងសំណេររបស់លោកព័ត៌មានស្តីពីបទឧក្រិដ្ឋនេះលោកបានសរសេរយ៉ាងច្បាស់លាស់អំពីការដែលអ្នកចម្លើយបាន នៅក្នុងអំឡុងពេលសួរចម្លើយហ្នឹងគឺសួររហូតដល់ដប់បីដង ដប់បីលើក ។ ហើយមួយលើកៗសុទ្ធតែប្រើវាយដំ លើលោកដោយដំបងក្តគោរាងត្រម៉ោងក្បាល ប្រវែងប្រហែលកន្លះម៉ែត ទំហំធំជាងមេជើងបន្តិច ។ ហើយវាយលើខ្នង ដើមទ្រូង និងដៃខាងឆ្វេង ហើយរហូតដល់សព្វថ្ងៃនេះលោកអះអាងថា ដៃខាងឆ្វេងប្រើការធ្ងន់មិនបានទេ ។ សំណួរសួរថា បញ្ហាសំណេរដែលលោកបានសរសេរដាក់របាយការណ៍ពីបទឧក្រិដ្ឋនេះមកនៅក្នុងសំណុំរឿងហើយលោកអះអាងអំមិញថាជាការត្រឹមត្រូវ ហើយនិងចម្លើយដែលលោកឆ្លើយនឹងសំណួររបស់ខ្ញុំពាក់ព័ន្ធជាមួយនឹងបញ្ហានៃការប្រើទារុណកម្មក្នុងអំឡុងពេលសួរចម្លើយដែលលោកអះអាងថា គេមិនបានប្រើហ្នឹង តើរឿងមួយណាដែលជាការត្រឹមត្រូវ?

**ឆ៖** តាមការដែលខ្ញុំបាទឆ្លើយមើលក្នុងអក្សរនេះដែលវាយចោទ វាយខ្ញុំបីដងហ្នឹងក្តគោនេះ គឺឆ្លើយបែបគាត់ហ្នឹងនៅក្នុងតាខ្មៅ ម្លោះហើយភ័ន្តច្រឡំកន្លែងហ្នឹង។

**ស៖** ហើយសំណួរមួយទៀត យើងកត់សម្គាល់ឃើញថា ទឹកនោម លាមក គឺអ្នកយាមទុកក្នុងបន្ទប់រហូតរយៈបីថ្ងៃទើបគេយកទៅចាក់ចោល អ៊ីចឹងវាខុសពីចម្លើយរបស់លោកគឺអ្នកយាមនុំងឯង គេមិនយកទៅចាក់ចោលខ្លួនឯងទេ គឺចាត់ចែងឲ្យអ្នកទោសដាក់វេនគ្នាដើម្បីយកទៅចាក់ចោល ។ ចំណុច

នេះលោកអះអាងថាម៉េចទៅ ច្បាស់លាស់មួយណាដែលច្បាស់លាស់ ព្រោះចម្លើយលោកខុសគ្នារវាងសំណេរជាលាយលក្ខណ៍អក្សរ ហើយនិងចម្លើយដែលអះអាងផ្ទាល់មាត់នាពេលសវនាការនេះ?

**ឆ៖** គឺពិតមែន បីថ្ងៃនេះ បីថ្ងៃដល់ទៅពេញ ប៉ុន្តែខ្ញុំឆ្លើយមិនបានច្បាស់លាស់ចំពោះអ្នកដែលកត់កំណត់ហេតុនេះគឺថា មួយពេញបានយកទៅចាក់ចោល ឬមួយនិងខ្ញុំឆ្លើយថា និងអ្នកយាមគេដាក់វេនអ្នកទោសឲ្យយកទៅចាក់ចោល គឺមិនច្បាស់លាស់នៅកន្លែងហ្នឹង គឺហើយនិងអានេះពិប្រាកដ ។

[១១:១៩:០៨]

**ស៖** អ្នកណាយកចាក់ចោល? អ្នកយាមយកចាក់ចោល ឬក៏អ្នកយាមចាត់ចែងឲ្យអ្នកទោសយកទៅចាក់ចោលដោយដាក់វេន ចែកវេនគ្នា ឬឲ្យអ្នកទោសយកទៅចាក់ចោលដោយខ្លួនឯង?

**ឆ៖** គឺអ្នកយាមបញ្ជាឲ្យអ្នកទោសយកទៅចាក់ចោល ។

**ស៖** (មន្ត្រីខាងសោតទស្សន៍សូមបញ្ចាំងនូវឯកសារដែលមានលេខERN ជាភាសាខ្មែរ 00279916 លើកញ្ចក់អេក្រង់ទូរទស្សន៍ )។ អំមិញបកទៅលិខិតអំមិញគឺនៅ-- លោកបានបញ្ជាក់ច្បាស់លាស់ថានៅដើមឆ្នាំ១៩៧៦ ខ្ញុំត្រូវបានចាប់ខ្លួនបញ្ជូនទៅទួលស្លែង ។ យើងសួរព្រឹកមិញគឺលោកបានឆ្លើយច្បាស់លាស់គឺចុងឆ្នាំ១៩៧៦ ។ បញ្ជូនមកដាក់គុកនៅមន្ទីរពេទ្យឆ្លូតតាខ្មៅប្រហែលមួយខែក្រោយមកទើបបញ្ជូនបន្តទៅដាក់គុកទួលស្លែង ។ អ៊ីចឹងចំណុចនេះ គឺជាកាលប្បវត្តិមួយ ដែលនាំឲ្យមានអង្គហេតុ មានការប្រែប្រួលខុសគ្នា ។ សំណួរសួរថាការចាប់ គេចាប់លោកបញ្ជូនទៅទួលស្លែងតែម្តងនេះ បញ្ជូនទៅដល់ទួលស្លែងតែម្តងនៅដើមឆ្នាំ១៩៧៦ ឬក៏ចុងឆ្នាំ១៩៧៦ ឬក៏ពេលណាដែលច្បាស់លាស់ដែលលោកចាំ?

**ឆ៖** នៅក្នុងពេលហ្នឹង គឺខ្ញុំអត់បានចាំ តែគ្រាន់តែដឹងក្នុងរយៈពេលឆ្នាំហ្នឹង។

**ស៖** ចុះលិខិតឯកសារនៅពីមុខរបស់លោកនេះ គឺជាលិខិតដែលលោកភ្ជាប់ជាមួយពាក្យបណ្តឹងរបស់លោក លោកមើលពិនិត្យមើលពាក្យបណ្តឹងនេះមើល មើលពាក្យឯកសារនេះណា អ៊ាវ ហ៊ី អាយុ ២១ឆ្នាំ លីវ នេះ ។ (ខាងសោតទស្សន៍អាសារ៉េឲ្យវាឡើងទៅលើបន្តិចម្តងៗដើម្បីអាចមើលអក្សរខាងក្រោម បាន។ តទៅទៀត ។ រំកិលឡើងលើទៀត ។ ឆ្លងទៅទំព័រមួយទៀត )។ ឯកសារនេះ តើលោកបានពី ណាមក យកមកដាក់នៅក្នុងសំណុំរឿង លោក លី ហ៊ី?

**ឆ៖** ឯកសារនេះខ្ញុំបានមកពី ឯកសារនេះរឿងរ៉ាវរបស់ខ្ញុំនៅអង្គាល់ពីសម័យ ប៉ុល ពត នុំង ។

**ស៖** លោកបានឯកសារនេះពីទីណាមក យកមកភ្ជាប់ដាក់ជាមួយក្នុងសំណុំពាក្យបណ្តឹងរបស់លោកនេះ?

**ឆ៖** ខ្ញុំមិនបានដឹងដែរ ស្រាប់តែឃើញក្នុងសំណុំរឿងនេះ ។

[១១:២៤:៣២]

**ស៖** នៅក្នុងនេះគឺចំណុចខាងលើ (ទម្លាក់មកក្រោមវិញ ខាងមន្ត្រីសោតទស្សន៍ ទម្លាក់មកឆ្លងទំព័រទីមួយវិញ) ។ នៅនេះមានចំណារដាក់ថា ដោះលែងថ្ងៃទី៨ ខែ៣ ឆ្នាំ១៩៧៦ ។ តើមានការដោះលែងលោកដែរទេ? បើនៅចំណារនេះគេដាក់ដោះលែងច្បាស់លាស់ថា ដោះលែងនៅថ្ងៃទី៨ ខែ៣ ឆ្នាំ១៩៧៦។ ម៉េចបានជាលោកអះអាងថា គេចាប់ខ្លួនលោកបញ្ជូនមកគុកនៅពេទ្យឆ្កួតតាខ្មៅ ហើយបញ្ជូនមកមន្ទីរ ស-២១ បើនៅក្នុងឯកសារនេះដាក់ថា ដោះលែងនៅថ្ងៃទី៨ ខែ៣ ឆ្នាំ១៩៧៦?

**ឆ៖** ខ្ញុំមិនបានដឹងដែរ ។ រួចហើយទើបឃើញនៅសំណុំរឿងនេះគេដាក់ដោះលែងខ្ញុំនៅខែ៣ ឆ្នាំ១៩៧៦ នេះ ប៉ុន្តែ មិនបានឃើញដោះលែងអីផង ដោះលែងកាលខ្ញុំដោះលែងចេញពីទួលស្លែងនោះចេញទៅនៅគុកព្រៃសប៉ុណ្ណឹង។ ខ្ញុំអត់បានដឹងដែរ ទើបតែឃើញសំណុំរឿងនេះ។

**ស៖** គេចាប់លោកកាលពីលោកនៅឯតំបន់២៥ហ្នឹង គេចាប់លោកប៉ុន្មានដង? បញ្ជូនទៅមន្ទីរ១៥?

**ឆ៖** កាលខ្ញុំនៅតំបន់ ២៥ ចាប់ខ្ញុំចូលមន្ទីរ១៥ម្តង រួចហើយបានបញ្ជូនមករហូតមកនៅតាខ្មៅហ្នឹង។

**ស៖** លោកនិយាយអំពីមុខរបររបស់លោកពិតប្រាកដនៅក្នុងមុនឆ្នាំ១៩៧៥ លោកធ្វើអ្វីពិតប្រាកដមុខរបរ? មុខរបរលោកបានធ្វើអ្វីខ្លះ?

**ឆ៖** មុខរបររបស់ខ្ញុំបាទ នៅមុនឆ្នាំ១៩៧៥ គឺធ្វើស្រែចម្ការជាមួយឪពុកម្តាយ ។

[១១:២៧:២៨]

**ស៖** ចុះលោកមានបានចូលរួមនៅក្នុងចលនាបដិវត្តន៍ជំនាន់នោះដែរឬទេ? ហើយលោកចូលពីពេលណា ហើយចូលធ្វើអ្វីដែរ?

**ឆ៖** កាលឆ្នាំ-- កាលសម័យនុ៎ងគឺខ្ញុំបានចូលធ្វើជាយោធា ប៉ុល ពត ។ គ្រាន់តែឆ្នាំខែខ្ញុំអត់បានចាំ។

**ស៖** លោកចូលធ្វើនៅក្នុងកងវរសេនា-- វរៈ១១៩ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** វរៈ១១៩ ហ្នឹងនៅក្នុងកងពលណា? ចំណុះកងពលណា?

**ឆ៖** ខ្ញុំអត់បានចាំ ។

**ស៖** លោកបានចាកចេញពីកងទ័ពនៅថ្ងៃខែឆ្នាំណា? លោកចាំទេ ឬក៏លោកធ្វើការជាកងទ័ព-រហូតដល់ពេលចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១?

**ឆ៖** ចាំខែឆ្នាំ គឺខ្ញុំអត់បានចាំ ។ មុននឹងមកចាប់នៅចូលនៅមន្ទីរ-១៥ ហ្នឹងគឺខ្ញុំបានរត់ចេញមក មកនៅពួននៅផ្ទះ បាននៅក្នុងមន្ទីរចិញ្ចឹមសត្វ ។

**ស៖** អ៊ីចឹងលោកចូលកងទ័ពហ្នឹង មិនចូលរហូតដល់ពេលការចាប់ខ្លួនលោកបញ្ជូនទៅមន្ទីរ១៥ ទេ ។ បានន័យថាលោកបានរត់ចេញពីកង ពីអង្គភាពទៅនៅផ្ទះវិញ ហើយលោកទៅនៅអង្គភាពចិញ្ចឹម សត្វអ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

[១១:៣០:០០]

**ស៖** លោករកនឹកមើល៍ លោកចាកចេញពីកងទ័ព បានន័យថារត់ចេញពីអង្គភាពកងទ័ពហ្នឹងទៅ ភូមិទៅនៅភូមិវិញហ្នឹងក្នុងឆ្នាំណា?

**ឆ៖** ខ្ញុំចាំឆ្នាំ ចាំអត់បាន ប៉ុន្តែខ្ញុំចេញពីកងទ័ពមក រួចហើយមកដល់ផ្ទះ មកផ្ទះមកចេញនៅក្នុង មន្ទីរ ។ មន្ទីរហ្នឹងហើយចេញមកហើយបានគេចាប់ខ្លួនចេញមកនៅជាប់នៅមន្ទីរ១៥ ហ្នឹង ។

**ស៖** លោករកនឹងមើល៍ លោកមានមុខរបរអីផ្សេងទៀតទេ ក្រៅពីនៅមន្ទីរចិញ្ចឹមសត្វនៅនឹង ស្រុកកំណើតរបស់លោក តើលោកធ្វើអីទៀត ក្រោយពីលោកបានបោះបង់ចាកចេញពីអង្គភាពកងទ័ព របស់លោកនោះ?

**ឆ៖** ដូចគ្មានអីក្រៅពីហ្នឹងទេ សូមជម្រាបលោកតុលាការ អត់មានមុខរបបអីផ្សេងពីហ្នឹងទេ ។

**ស៖** លោកដែរធ្វើជាងឆ្នាំងទេ ជាងដែកខាងចាក់ឆ្នាំងស្ពាន់ឆ្នាំង ដែលធ្វើការងារហ្នឹងទេ?

**ឆ៖** ដែរ ដែលព្រោះថាមុខរបររកស៊ី ខ្ញុំអំមិញស្តាប់យោបល់របស់តុលាការមិនបានច្បាស់ គឺ មុខរបររកស៊ី មុខរបរចេញពីទ័ពមក មកនៅក្នុងមន្ទីរហ្នឹង មន្ទីរក៏គេប្រើជាឆ្នាំង ចាន អីហ្នឹង ។ ហ្នឹង បានធ្វើមែន មុខរបរហ្នឹងមាន ចេញពីមន្ទីរហ្នឹងបានមកចូលមន្ទីរ១៥ គេចាប់ចូលមន្ទីរ១៥ ។

**ស៖** អ៊ីចឹង បញ្ចាក់លោកឡើងវិញ គឺខាងមន្ទីរ១៥ ហ្នឹងចាប់លោកតែម្តងគត់ គឺចាប់ដាក់មន្ទីរ ១៥ ។ ហើយក្រោយមកក៏បានបញ្ជូនមកគុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅ ហើយបន្ទាប់មកទៀតបានលោកអះអាងថាបញ្ជូនមកលោកមកដាក់ឃុំឃាំងនៅទួលស្លែង ហើយក្រោយមកបានចេញពីគុកមន្ទីរស-២១ ហើយបន្ទាប់មកបានបញ្ជូនទៅព្រៃស អ៊ីចឹងមែនទេ?

**ឌ៖** បាទ ។

**ស៖** ខាងផ្នែកសោតទស្សន៍បញ្ចាំងនូវឯកសារដែលមានលេខERNជាភាសាខ្មែរ00279918 ។ ម៉ែចទៅៗ?

**លោក អាឡាំង វែនណឺ៖**

សូមអភ័យទោសដែលខ្ញុំកាត់ ។ ខ្ញុំសូមស្នើសុំថាមុនពេលដែលយើងចូលទៅដល់ឯកសារ 0027 9918 យើងអត់មានភាសាអង់គ្លេស និងភាសាបារាំងនោះទេ ទាក់ទងទៅនឹងឯកសារ 00279916 និង 17 ដែលលោកបង្ហាញមុននេះ ។ ហើយខ្ញុំស្នើសុំចំពោះឯកសារពីរទំព័រនេះ ថាសុំឲ្យធ្វើការបកប្រែ ឬក៏អានឯកសារពីរទំព័រនេះ គួរតែអានដើម្បីឲ្យមានកំណត់ហេតុកត់ចូលទៅក្នុងប្រតិចារឹក ។

សូមអរគុណ ។

[១១:៣៤:២៧]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាននូវឯកសារពីរទំព័រអម្បាញ់មិញនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

អ៊ា ហ៊ា ដោះលែងថ្ងៃ៨ ខែ៣ ឆ្នាំ១៩៧៦ ។ (ខាងស្តាំ) ស្នើ សុំស្នើដាក់គុក ។

១) អាយុ ២១, លីវ, ភូមិព្រៃកស្តី ឃុំព្រៃកស្តី ស្រុក១៨ តំបន់២៥ យុវជនមន្ទីរធ្វើឆ្នាំងសាខាមន្ទីរ២៥ ។ ២) ១៩៧០ សិស្សទី៩ ។ ២៨ ខែ៨ ឆ្នាំ១៩៧២ ចូលបដិវត្តន៍ ឈ្លបឃុំព្រៃកស្តី ។ ខែ១១ ឆ្នាំ១៩៧២ យោធាស្រុក១៨ ។ ខែ៤ ឆ្នាំ១៩៧៣ ចូលកង១១៩ ។ ឆ្នាំ១៩៧៤ ចូលទាំងកងទៅជារបស់ភាគនិរតី ។ រត់ទៅផ្ទះព្រោះ ឆយ ដឹកនាំ ។ ខែ១១ ឆ្នាំ១៩៧៤ ខៀវ យោធាវត្តដើមពោធិ៍ ។ ខែ៧ ឆ្នាំ១៩៧៥ ជាងឆ្នាំងនៅកោះខែល ។ ខែ៨ ឆ្នាំ១៩៧៥ ទំនាស់ពីរឿងដោះឡាននៅព្រៃកប្រា រួចនាំយុទ្ធជនពីរនាក់រត់ទៅផ្ទះ ។ មកដល់មន្ទីរ១៥ អង្គការចាប់ដាក់គុកនៅទីនោះទៅ ។ ខែ១១ ឆ្នាំ១៩៧៥ ពេលធ្វើការងារវាលួចរត់ពីម-១៥ ។

សន្និដ្ឋាន៖ ដោយឈ្មោះនេះ នៅមានអាកប្បកិរិយាក្រឡេចក្រឡុច មិនព្រមកែប្រែសកម្មភាពអាក្រក់របស់វា សុំស្នើអង្គការដាក់គុកសិន ។ ថ្ងៃ១៥ ខែ២ ឆ្នាំ១៩៧៦ ។

អ៊ា ហ៊ អំពី ឆយ រត់ចោលជួរពី១១៩ ។ រត់ចេញពីកងឆ្នាំង សាខា ម-២៥ ។

១) ប្រវត្តិរូប ២) តារាងចាត់តាំង ៣) បក្សពួក ៤) សកម្មភាពផ្ទាល់ខ្លួន ។ ថ្ងៃទី៧ ខែ១ ឆ្នាំ១៩៧៦ ។

ប្រវត្តិរូប ៖ ១) ផ្ទាល់ខ្លួន

**ប្រធានអង្គជំនុំ៖**

**ស៖** ឈប់សិន! លោក លី ហ៊ ចុះឯកសារនេះ ឯកសារដែលយើងបង្ហាញនេះ គឺជាប្រវត្តិរូបដែលលោកបានដាក់ភ្ជាប់មកជាមួយ និងពាក្យបណ្តឹងរបស់លោក តើឯកសារហ្នឹងលោកបានពីណាមក? ហើយលោកយកមកភ្ជាប់ជាមួយនឹងពាក្យបណ្តឹងរបស់លោកនេះ?

[១១:៣៩:២២]

**ឆ៖** ឯកសារនេះ គឺពិតជាត្រឹមត្រូវដែលរបស់ខ្ញុំពិតមែន ប៉ុន្តែក្នុងពេលហ្នឹងដែលខ្ញុំយូរទៅ ខ្ញុំមិនបានសូវចាំឆ្នាំ ចាំខែ ប្រវត្តិដែលសួគ្រអម្បាញ់មិញ គឺពិតប្រាកដរបស់ខ្ញុំមែន ។

**ស៖** ឯកសារនេះ ដាក់នៅមុខលោក ប្រវត្តិរូបនេះ លោកឃើញនៅដាក់នៅក្នុងសំណុំរឿង គឺភ្ជាប់ជាមួយពាក្យបណ្តឹងរបស់លោកតែម្តង ។ សំណួរសួរថា តើលោកបានឯកសារហ្នឹងពីណាមក?

**ឆ៖** ប្រវត្តិដែលនៅភ្ជាប់នឹងមុខខ្ញុំនេះ គឺខ្ញុំមិនដឹងដែរ ប៉ុន្តែ នេះគឺរបស់ខ្ញុំផ្ទាល់តែម្តង ។ ប៉ុន្តែ វាមិនដឹងបានពីណាមកយកមកដាក់នៅហ្នឹង ។

**ស៖** ដោយហេតុថា ឯកសារនេះគឺមិនមានការបកប្រែជាភាសាបរទេស ជាភាសាបារាំង និងភាសាអង់គ្លេសទេ អ៊ីចឹងអ្នកដែល ភាគីដែលចូលរួមនៅក្នុងកិច្ចដំណើរការនេះក៏ពិបាកយល់ដែរ ។ អ៊ីចឹងដើម្បីបានយល់អំពីបញ្ហាអស់នេះ សូមក្រឡាបញ្ជីអាននៅខ្លឹមសារនៃឯកសារនេះរហូតដល់ចប់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ប្រវត្តិរូប៖

១) ផ្ទាល់ខ្លួន ឈ្មោះដើម អ៊ា ហ៊ អាយុ២១ លីវ ។ យុទ្ធជនមន្ទីរធ្វើឆ្នាំងតំបន់២៥ ។

២) ផ្ទះកំណើត ព្រែកស្តី, ព្រែកស្តី, ១៨, ២៥ ។

៣) ប្រវត្តិ រៀនថ្នាក់ទី៩ ឆ្នាំ១៩៧០ សាលាព្រែកស្តី តាំងពីតូចមករហូតថ្ងៃ១៨ ខែ៣ ឆ្នាំ១៩៧០

រស់នៅក្នុងបន្ទុកគ្រួសារ ។ ថ្ងៃ២៨ ខែ៨ ឆ្នាំ១៩៧២ ចូលបដិវត្តន៍ ។ អ៊ំ សឿន ប្រធានភូមិនាំចូល បីខែ ។ យុទ្ធឈ្លបឃុំព្រៃកស្តី ។ ខែ១១ ឆ្នាំ១៩៧២ នៅយោធាស្រុក១៨ ។ ខែ១ ឆ្នាំ១៩៧៣ ចូលកងអនុសេនាតូច២២ អនុសេនាធំ៩២ វរសេនាតូច១១៩ តំបន់២៥ ។ នាទីអនុក្រុមស៊ើបការណ៍ ។ ឆ្នាំ១៩៧៤ ១១៩ នៅនិរតី ។ ឆ្នាំ១៩៧៤ រត់មកផ្ទះវិញ តំបន់២៥ និយាយត្រូវគ្នាជាមួយ ឆយ រត់មកផ្ទះ ។ ពេលវ៉ៃ នៅសមរភូមិបែកចាន នៅផ្ទះ៩ថ្ងៃ ។ ឆ្នាំ១៩៧៤ មកនៅសាលានយោបាយព្រៃកតាវ៉ា រហូតខែ១១ ឆ្នាំ ១៩៧៤ ។ ខែ១១ ឆ្នាំ១៩៧៤ ទៅរៀនយោធានៅដើមពោធិ៍ ។ ខែ៧ ១៩៧៥ មកធ្វើឆ្នាំងនៅកោះខែល ។ ខែ៨ ឆ្នាំ១៩៧៥ អង្គការចាត់តាំងឲ្យមកដោះឡាននៅព្រៃកប្រា រត់ទៅផ្ទះ ។ ទំនាស់ជាមួយ ក.ប ពីរឿង ដោះឡាន ។ នាំឈ្មោះ ១. គឹម ឆាំង, ២. ជី កាំង ឲ្យរត់ទៅជាមួយ ។ ខែ៨ ឆ្នាំ១៩៧៥ រត់អត់សំបុត្រ មន្ទីរ១៥ ចាប់ ជាប់គុករហូត ។ ថ្ងៃ២៣ ខែ១១ ឆ្នាំ១៩៧៥ មក៤៤ ។ ថ្ងៃ៥ ខែ១ ឆ្នាំ១៩៧៥ មក៤៣ ។ ឪពុក អ៊ា ថុងលី អាយុ៥៤ រស់, ម្តាយ ស៊ាន ម៉ៅ អាយុ៤៩ រស់ ។ ទីលំនៅព្រៃកស្តី, ព្រៃកស្តី, ១៨, ២៥ ។ មុខរបរធ្វើចំការ ។ បងប្អូនប្រាំបីនាក់ ស្រីបី ប្រុសប្រាំ ។

ធ្វើបដិវត្តន៍៖

១) អ៊ា ហ៊ា ជាប់គុក ។ ២) បងថ្លៃឈ្មោះ ស្រ៊ាង គ្រី នៅផ្នែកដឹកជញ្ជូនតំបន់២៥ ក្រៅពីនេះ ក្នុងបន្ទុកគ្រួសារ ។

តារាងចាត់តាំង៖

ឆយ យុទ្ធជន៩២, ១១៩ ផ្ទះ+ម៉ែឪមិនស្គាល់ ។

អ៊ា ហ៊ា, គឹម ឆាំង ព្រៃកតាឌួង, ព្រៃកថ្មី ១៨, ២៥ ។ យុទ្ធជនជាងឆ្នាំងមន្ទីរ២៥ ។ បច្ចុប្បន្នមក ពីផ្ទះវិញហើយ ។ ជី គាង ព្រៃកតាឌួង, ព្រៃកថ្មី ១៨, ២៥ យុទ្ធជនមន្ទីរ២៥ ជាងឆ្នាំង ។ បច្ចុប្បន្នមកពី ផ្ទះវិញហើយ ។

បក្សពួក៖ មេវា៖

១) ឆយ យុទ្ធជនកងអនុសេនាតូច៩២២ អនុសេនាធំ៩២ វរសេនាតូច១១៩ តំបន់២៥ ។ ផ្ទះ និងម៉ែឪមិនស្គាល់ ។ សព្វថ្ងៃមិនដឹង ។ បបួលរត់មកតំបន់២៥ ។ បំផុសពី ខ្វាំងខ្លាំងងាប់, ស៊ីចុក ។

សមាជិកក្រោម អ៊ា ហ៊ា៖

១) គឹម ឆាំង អាយុ២៥ លីវ ។ ពីមុននៅ១៣០ រត់ចោលជួរ ។ មកចូលមន្ទីរធ្វើឆ្នាំង សាខា មន្ទីរ២៥ ។ ផ្ទះនៅព្រៃកតាឌួង, ព្រៃកថ្មី, ១៨, ២៥ ។ ម៉ែឪមិនស្គាល់ ។ ខែ៨ ឆ្នាំ១៩៧៥ រត់ចេញពី

ព្រៃកប្រា កន្លែងធ្វើឡាន ។ បច្ចុប្បន្ននៅមន្ទីរធ្វើឆ្នាំង កោះខែល ជាប់មន្ទីរ១៥ ។ បច្ចុប្បន្នដោះលែងហើយ ។

២- ជឺ គាង អាយុ១៩ លីវ ។ ជាយុវជនទើបចូលបដិវត្តន៍ឆ្នាំ១៩៧៥ ។ ព្រៃកតាខ្នង ព្រៃកថ្មី ១៨, ២៥ ។ ឪពុក ឡុច ម្តាយមិនស្គាល់ ។

[១១:៤៨:៥៩]

ខែ៨ ឆ្នាំ១៩៧៥ រត់ចេញពីព្រៃកប្រាជាមួយគ្នាជាប់ ម-១៥ ។ បច្ចុប្បន្នដោះលែង ។ សព្វថ្ងៃនៅធ្វើឆ្នាំងមន្ទីរកោះខែល ។

សកម្មភាពកន្លងទៅ៖

ឆ្នាំ១៩៧៤ រត់ចោល១១៩ ហើយឈ្មោះ ឆយ ចលនា ។ ពួនទៅលើផ្ទះ៩ថ្ងៃ អង្គការបញ្ជូនមកសាលា ន.ប ។ ខែ៨ ឆ្នាំ១៩៧៥ រត់ចេញពីមន្ទីរជួសជុលឡាននៅព្រៃកប្រា ដោយចលនា គឹម ឆាំង + ជឺ គាងឲ្យរត់មកជាមួយ ។ ខែ៨ ឆ្នាំ១៩៧៥ ដោយអត់សំបុត្រ មន្ទីរ១៥ចាប់ដាក់គុកទាំងបីនាក់ ។ ខែ១១ ឆ្នាំ១៩៧៥ លួចរត់ចេញពីមន្ទីរ១៥ទៀត គេចាប់ជាប់ រួចបញ្ជូនមក៤៥ តែម្តង ។ ថ្ងៃទី៧ ខែ១ ឆ្នាំ១៩៧៥ ។

សូមគោរពសមមិត្ត តេង មន្ទីរ១១៥ ជាទីគោរពស្នេហា!

សូមជ្រាប ចំពោះមិត្ត អ៊ា ហ៊ ដែលបានរត់ចេញពី១ ស.ម នោះ ឥឡូវបានត្រឡប់មកកាន់កន្លែងស្ពនៅថ្ងៃទី០៦ ខែ១១ ឆ្នាំ១៩៧៥ វិញហើយ ។ ដូច្នេះ យើងខ្ញុំសូមនាំមិត្ត អ៊ា ហ៊ នេះមកជូនសមមិត្តវិញ ។ ហេតុនេះសូមស្នើសមមិត្តទទួលយកមិត្តនេះវិញចុះ ។ សូមអរគុណ ។ គោរពដោយរលឹកពីបដិវត្តន៍ ។ ថ្ងៃទី០៧ ខែ១១ ឆ្នាំ១៩៧៥ ។

ស្ពដែក ស្ទួង៖ ជននេះធ្វើជាមួយអា សា រ៉េត នាំគេរត់ចេញពីសាលាអប់រំ កាលពីក្នុងខែ៩ ឆ្នាំ១៩៧៥ ។ ចម្លើយបន្ថែម៖ ឆ្នាំ១៩៧៥ ខែវិច្ឆិកា ថ្ងៃទី១០ ម៉ោង៧ យប់ ឈ្មោះ អ៊ា ហ៊ បានឆ្លើយបន្ថែមឲ្យព័ត៌មានដូចខាងក្រោម៖

ខ្ញុំឈ្មោះ អ៊ា ហ៊ អាយុ២១ឆ្នាំ ជាតិខ្មែរ កំណើតនៅភូមិនឹង ឃុំព្រៃកស្តី ស្រុកកោះធំ ខេត្តកណ្តាល ។ លំនៅសព្វនៅភូមិឃុំដូចខាងលើក ។

[១១:៥៣:០៩]

ស.ឆ៖ កាលពីខែកញ្ញា ឆ្នាំ១៩៧៥ រយៈពេលដែលរូបខ្ញុំត្រូវអង្គការដាក់អប់រំនៅសាលាអប់រំនៃ

មន្ទីរ១៥ ឈ្មោះ ហោ សារ៉េត ប្រាកដជាបានចលនាបំផុសរូបខ្ញុំឲ្យរត់ចេញពីទីនោះពិតប្រាកដមែន ។ សារ៉េត និយាយប្រាប់ខ្ញុំថា "មិត្តឯងមើលខ្ញុំគ្មានទោសអីផង អង្គការយកមកដាក់គុកពីរបីខែហើយ អត់ដោះស្រាយទេ ។ មើលចុះយុទ្ធជនចាប់ឃុំឃាំងទីនេះ ពេលឈឺអត់ឲ្យដេកខាងក្នុងទេ យកទៅដាក់ខាងក្រៅថែមទាំងមិនឲ្យថ្នាំផឹកទៀតផង ។ ចំពោះយោធារួមនេះមិនមែនតិចឆ្នាំទេ ពីរបីឆ្នាំហើយនៅតែមិនដោះស្រាយ ។ ឯការងារឲ្យធ្វើទាំងយប់ ទាំងថ្ងៃ មិនថាយប់ ឬថ្ងៃទេ មិត្តឯងមើលមិត្តផង គាត់រត់ចេញពីកសិដ្ឋានមន្ទីរ១៥ ហ្នឹងដែរ ឥឡូវទៅបើកឡាននៅកងពល១២ ធ្វើព្រងើយ ។

ស.ឆ៖ ពេលឮគាត់បំផុសដូចខាងលើនេះ ខ្ញុំក៏ព្រមរួមគំនិតជាមួយគាត់ ក្រោយមកខ្ញុំ និងគាត់ សារ៉េត ទាំងពីរនាក់ ក៏បានទៅបំផុសឈ្មោះ គឹម ឆាំង និងឈ្មោះ ជី គាង បន្ថែមទៀត ដើម្បីបានគ្នាច្រើន ។ ឯអ្នកទាំងពីរ ឆាំង និង គាង ក៏ព្រមយល់ស្របតាមខ្ញុំ និង សារ៉េត ។

ស.ឆ៖ ក្រោយពីការបំផុសចំនួនពីរយប់ ពីរថ្ងៃក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដដែល វេលាម៉ោង៨យប់ ទាំងបួននាក់ក៏រត់ចេញទៅទិសខាងកើត ។ ដល់មាត់ស្រះកសិដ្ឋានមន្ទីរ១៥ ក៏បត់ទៅខាងត្បូង ដល់ខាងលើកំពង់ដរវត្តសំប៉ានបន្តិច ក៏យកដើមចេកដែលប្រជាជនកាប់ទុករួចជាស្រេច ហែលឆ្លងទៅត្រើយខាងលិច រួចដើរតាមផ្លូវជាតិចុះទៅក្រោមករហូតដល់ផ្ទះរៀង១ខ្លួន ។ ឯរូបខ្ញុំពេលទៅដល់ផ្ទះក៏ចូលតែម្តង ចំណែក សារ៉េត បន្តដំណើរទៅក្រោមទៀត ព្រោះផ្ទះគេនៅខាងក្រោមផ្ទះខ្ញុំ ។ ឥឡូវនេះ ពុំដឹងនៅទីណាទេ ។

ស.ឆ៖ ពេលអង្គការចាប់ខ្លួនខ្ញុំ មកដាក់ឃុំឃាំងមន្ទីរ១៥ ជាលើកទីពីរ វេលាម៉ោង១ ថ្ងៃទី១០ ពេលដែលអង្គការឲ្យខ្ញុំចេញបាចទឹក ខ្ញុំក៏បានរត់ចេញពីទីនេះទៀតពិតប្រាកដមែន ។

ចម្លើយចប់ម៉ោង៩យប់ ថ្ងៃខែឆ្នាំដដែល ។ បានសូត្រឲ្យ អ៊ា ហ៊ី ស្តាប់ រួចសមីខ្លួនបញ្ជាក់ថាពិតដូចចម្លើយខ្លួនមែន ។ កម្មាភិបាលស៊ើបអង្កេត ដៀម ។ ស្នាមមេដៃស្តាំ អ៊ា ហ៊ី ។

[១១:៥៦:៤០]

ចម្លើយលើកទីពីរ៖

ឆ្នាំ១៩៧៥ ខែវិច្ឆិកា ថ្ងៃទី២២ ម៉ោង១៩ ឈ្មោះ អ៊ាង ហ៊ី បានឆ្លើយឲ្យព័ត៌មានបន្ថែមដូចតទៅ៖

ស.ឆ៖ ខ្ញុំឈ្មោះ អ៊ា ហ៊ី អាយុ២១ ជាតិខ្មែរ កំណើតនៅភូមិគ ឃុំព្រែកស្តី ស្រុក១៨ តំបន់២៥ ។

ស.ឆ៖ ខ្ញុំចូលរួមក្នុងចលនាបដិវត្តន៍នូវថ្ងៃ២៨ ខែសីហា ឆ្នាំ១៩៧២ អ្នកនាំចូល អ៉ំ សឿន

ប្រធានភូមិគ ឃុំព្រែកស្តី ដោយអ៊ំ សឿន បញ្ជូនខ្ញុំទៅមន្ទីរព្រែកស្តី ។ នៅបានបួន ឬ ប្រាំថ្ងៃ អង្គការឃុំក៏បញ្ជូនខ្ញុំទៅកងជាមួយតា កាត ។ ខ្ញុំនៅជាមួយតា កាត បានប្រហែលមួយខែ អង្គការក៏ចាត់តាំងឲ្យមកនៅក្នុងកងវរៈ១១៩ ក្រោមការទទួលខុសត្រូវរបស់បង ឃឿន ស្នងការ ។ កងនេះប្រចាំការនៅទន្លេមេគង្គ ក្រោយមកទៀតក៏ប្រចាំការនៅទន្លេបាសាក់ ។ លុះដល់ខែសីហា ឆ្នាំ១៩៧៤ អង្គការក៏ចាត់តាំងកងវរៈ១១៩នេះទៅប្រចាំការនៅថ្នល់ជាតិលេខ៤ ។ ដល់ខែមករា ឆ្នាំ១៩៧៤ ខ្ញុំក៏លួចរត់ចេញពីកងមកស្នាក់នៅមន្ទីរសេនាធិការរបស់មន្ទីរ១៣ ។ ពេលដែលអង្គការ-- ខ្ញុំមកដល់មន្ទីរសេនាធិការ អង្គការចាត់តាំងឲ្យខ្ញុំធ្វើមីន ជាមួយបង ប្រាជ្ញ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៤ ។ បង ឃឿន ក៏សុំខ្ញុំឲ្យមកនៅមន្ទីរ១៣ ជាមួយគាត់ ។ លុះដល់ខែធ្នូ ឆ្នាំ១៩៧៤ បងឃឿន ត្រូវអង្គការចាត់តាំងឲ្យទៅបង្ហាត់បច្ចេកទេសយោធានៅវត្តដើមពោធិ៍ ។ ឯរូបខ្ញុំក៏បង ឃឿន ឲ្យទៅជាមួយដែរ ។

លុះដល់ខែមករា ឆ្នាំ១៩៧៥ អង្គការក៏ចាត់តាំង បងឃឿន ឲ្យទៅចងក្បូននៅទន្លេមេគង្គ ឯរូបខ្ញុំអង្គការចាត់តាំងឲ្យនៅថែរក្សាដំណាំរដូវនៅវត្តដើមពោធិ៍ និងនៅចិញ្ចឹមមាន់ ជ្រូក ថែរក្សាគោ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៥ អង្គការក៏ចាត់តាំងឲ្យខ្ញុំមកកន្លែងស្លដែកនៅកោះខែល ក្រោមការទទួលខុសត្រូវរបស់តា សួង ។

[១១:៥៩:៥៨]

នៅខែសីហា ឆ្នាំ១៩៧៥ តា សួង ក៏ចាត់តាំងខ្ញុំរូប ជី គាង និងមិត្ត គឹម ឆាំង ឲ្យទៅដោះឡាននៅព្រែកប្រា ។ ទៅដល់ព្រែកប្រាបានចំនួនប្រាំមួយ ឬប្រាំពីរថ្ងៃ ខ្ញុំក៏ប្រើ មិត្តគាង និង មិត្តឆាំង ឲ្យមករកពោតនៅព្រែកតាខ្លួងយកទៅស៊ី ។ លុះមិត្តទាំងពីរមកបាត់យូរពេក ខ្ញុំក៏មកតាម ដោយធ្វើដំណើររហូតមកដល់អង្គរ ឃុំ ពោធិបាន មិត្តយោធាយាមឃាត់ខ្ញុំទុក ដោយខ្ញុំអត់លិខិតធ្វើដំណើរ ។ អង្គការឃាត់នៅមន្ទីរ១៥ ដោយយកខ្ញុំទៅអប់រំ ពេលនោះ ក៏ជួបមិត្តគាង និងមិត្តឆាំង នៅសាលាអប់រំ មន្ទីរ១៥ជាមួយគ្នា ។ ខ្ញុំនៅសាលាអប់រំបានចំនួនបី ឬបួនថ្ងៃ ខ្ញុំក៏បានទទួលការបំផុសបំផុលពីឈ្មោះ ហោ សារ៉េត ជាយុទ្ធជនរបស់មន្ទីរ១៣ ដែលមកជាប់នៅមន្ទីរ១៥ ឲ្យខ្ញុំរត់ចេញពីសាលាអប់រំ ។ ឯខ្លឹមសារដែលហោ សារ៉េត ណែនាំបំផុសបំផុលនោះ គឺដូចមានក្នុងចម្លើយរបស់ខ្ញុំខាងដើមស្រាប់ ។ ទន្ទឹមនឹងនេះ ហោ សារ៉េត បានចាត់តាំងឲ្យខ្ញុំបំផុសបំផុល មិត្តគាង និង មិត្តឆាំង ឲ្យរត់ទៅជាមួយគ្នា ដោយសារ៉េត បញ្ជាក់ប្រាប់ខ្ញុំថា “យើងរត់ទៅពួននៅផ្ទះយើងរៀង១ខ្លួន” ។ ឯរួចខ្ញុំក៏បំផុសមិត្តទាំងពីរ តាមការចាត់តាំងរបស់ ហោ សារ៉េត មែន ។ លុះខ្ញុំបំផុសបានហើយ រំលងបានមួយថ្ងៃ ហោ សារ៉េត រូបខ្ញុំ

ជឺ គាង និង គឹម ឆាំង ក៏នាំគ្នារត់ចេញពីសាលាអប់រំមន្ទីរ១៥មែន នៅម៉ោង៨យប់ ។ នៅថ្ងៃ៧ ខែវិច្ឆិកា ឆ្នាំ១៩៧៥ អង្គការមន្ទីរ១៣ ក៏បញ្ជូនខ្ញុំមកមន្ទីរ១៥វិញ ។ ខ្ញុំនៅជាប់បានបួនថ្ងៃ គឺនៅថ្ងៃ១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ពេលដែលអង្គការចាត់តាំងឲ្យខ្ញុំធាក់រហាត់ទឹក ខ្ញុំក៏លួចចេញពីមន្ទីរ១៥ទៀត តែមិត្តឃោធាឃាមការពារចាប់ខ្ញុំបានមកវិញ ។

[១១:០២:៤៤]

កំណត់ហេតុ ស.ឆ ក្នុងការដែលខ្ញុំលួចរត់ចេញមន្ទីរ១៥ ម្តង ជាពីរដងយ៉ាងនេះ ព្រោះខ្ញុំបានទទួលការអប់រំ និងតាមបណ្តាំរបស់ តាព្រង កាលពីខែឧសភា ឆ្នាំ១៩៧៥ នៅវត្ត ដើមពោធិ ពេលដែលខ្ញុំ និងគាត់ (តាព្រង) នៅថែដំណាំរដ្ឋ និងចិញ្ចឹមសត្វ ដោយគាត់បានលើកឡើង ណែនាំថា ធ្វើបដិវត្តន៍មិត្តឯងចង់ទៅរត់ផ្ទះ ឬទៅណាមកណា ក៏អង្គការមិនខ្វល់ដែរ អង្គការមិនទៅតាមវិញទេ ។ សព្វថ្ងៃ តាព្រង នេះ នៅមន្ទីរស្លដែករបស់មន្ទីរ១៣ នៅកោះខែល ។

ស.ឆ ចាប់តាំងពីខែមករា ឆ្នាំ១៩៧៥ ខ្ញុំពិតជាបានទទួលការអប់រំពីឈ្មោះ តា ព្រង ឲ្យខ្ញុំខ្លាចសមរភូមិមុខ ឲ្យខ្ញុំស្តីកស្រពន់ស្មារតីដោយគាត់ណែនាំ និងបំផុសខ្ញុំថា ហ៊ ឯងចង់ទៅសមរភូមិមុខធ្វើអី? លំបាកវេទនាណាស់ ស៊ីអត់ ស៊ីឃ្លាន ដេកហាលមូស ហាលភ្លៀង ហាលសន្សើម! ហ៊ ឯងនៅជាមួយអញ សម្បូរស៊ី កុំចង់ទៅមុខធ្វើអី លំបាកណាស់ ដូចហ៊ ឯងដឹងស្រាប់ហើយ ។

[១២:០៤:២២]

ការណែនាំ និងបំផុសរបៀបនេះ មកលើខ្ញុំជាញឹកញាប់ណាស់ ចាប់ពីខែមករា រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ក្រោយចប់សង្គ្រាម ។ ការណែនាំរបស់គាត់នេះ ធ្វើឲ្យសតិអារម្មណ៍ និងគោលជំហររបស់ខ្ញុំ មិនចង់ទៅសមរភូមិមុខទាល់តែសោះ ព្រោះឃើញលំបាកវេទនាមែន ។ ក្រោយពីការណែនាំមក បើអង្គការចាត់តាំងឲ្យខ្ញុំទៅសមរភូមិមុខ ខ្ញុំប្រាកដជារត់មកខាងក្រោយវិញដាច់ខាត ។

ស.ឆ នៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៧៥ គឺរយៈពេលដែលមកនៅមន្ទីរស្លដែកកោះខែល តាព្រង ក៏បានបំផុសខ្ញុំ ដើម្បីឲ្យសុំអង្គការឈប់ធ្វើបដិវត្តន៍ ទៅនៅរកស៊ីឯផ្ទះវិញ ។ ដោយគាត់បានលើកឡើងថា “ហ៊ ឯងសុំអង្គការឈប់ទៅ ស៊ីអង្ករកំប៉ុងដូចតែគ្នា នៅផ្ទះក៏ស៊ីអង្ករកំប៉ុង ហើយភ្ជួរដីធ្វើស្រែដូចគ្នាអញ (តាព្រង) ក៏សុំអង្គការឈប់ដែរ អញអស់ស្មារតីធ្វើការទៀតហើយ! ហ៊ឯងឃើញទេអង្គការទម្លាក់នៅត្រឹមប្រធានក្រុម” ។

ស.ឆ ខ្ញុំបានដឹងច្បាស់ថា តា ព្រង លួចសម្បត្តិអង្គការ ដូចជាក្រណាត់មួយបារ សាំង២៥លីត្រ

ប្រេងកាត១០លីត្រ អង្ករជាងមួយតៅ លាក់ទុកក្បត់នឹងអង្គការ ដោយខ្ញុំបានដឹងច្បាស់ថា ក្រណាត់មួយប៉ាវនោះ ផ្ញើទុកនៅផ្ទះមិត្ត ចាន់ ស៊ី ។ ផ្ទះនៅខាងត្បូងផ្ទះ ស្វាយ តា មេឃុំ ឃុំកោះធំ ។

ស.ឆ ខ្ញុំបានដឹងច្បាស់ បងឃឿន និង តាព្រង មានការកៀកកិតគ្នាណាស់ តាំងពីការលួចសម្បត្តិអង្គការឡើងទៅ ពីរអ្នកនេះ ស៊ុមគ្រលុំជាមួយគ្នា កុំឲ្យរាយការណ៍ឲ្យអង្គការដឹងឲ្យសោះ ។ ចម្លើយចប់បណ្ដោះអាសន្ននៅម៉ោងម្ភៃពីរ និងដប់នាទី ដោយសូត្រឲ្យ អ៊ា ហ៊ី ស្ដាប់ រួចសាមីខ្លួនបានបញ្ជាក់ថា ត្រឹមត្រូវមែន ។

**ប្រធានអង្គជំនុំ៖**

បាន ហើយៗ! យ៉ាង ម៉េចទៅ អ៊ា ហ៊ី ។ មន្ត្រីសោតទស្សន៍បង្វែរទៅរូបភាពប្រក្រតីវិញ ។ ឯកសារដែលបានអានដោយក្រឡាបញ្ជីអម្បាញ់មិញនេះ ។

**ស៖** ទីមួយ អំពីជីវប្រវត្តិរបស់លោក តើឆ្លុះបញ្ចាំងនូវជីវប្រវត្តិពិតរបស់លោកដែរឬទេ?

**ឆ៖** គឺពិតមែន ។

**ស៖** ចុះកំណត់ហេតុអំមិញ ដែលចុងក្រោយ គឺជាកំណត់ហេតុដែលធ្វើនៅចំពោះមុខមន្ទីរ១៥នៃជីវប្រវត្តិ ដែលលោកបានមានការប្រឆាំង ឬក៏មានការមិនគោរពវិន័យនៃអង្គការចាត់តាំងនៅសម័យនោះ តើវាឆ្លុះបញ្ចាំងពីការពិតនៃជីវប្រវត្តិរបស់លោកមែនដែរទេ?

**ឆ៖** គឺពិតមែន ។

**ស៖** លោកស្គាល់មន្ទីរ៤៤ទេ មន្ទីរអីគេ មន្ទីរ៤៤?

**ឆ៖** មន្ទីរ៤៤ ខ្ញុំអត់បានស្គាល់ ។

**ស៖** ចុះ៤៣?

**ឆ៖** ៤៣ ក៏អត់ស្គាល់ ។

**ស៖** ចំណុចមួយសរសេរអញ្ចេះថា លួចរត់ចេញពីមន្ទីរ១៥ទៀត គេចាប់ជាប់ រួចបញ្ជូនមក៤៤តែម្ដង ។ ៤៤ហ្នឹងស្អីគេហ្នឹង ៤៤ហ្នឹង? មិនមែនមន្ទីរទេ បញ្ជូនមក៤៤តែម្ដង ។ តើលោកក្រៅពីចេញមន្ទីរ១៥ហ្នឹង គេចាប់បញ្ជូនទៅណា? លោករកនឹកមើល មានទៅណាផ្សេងក្រៅពីមក បញ្ជូនមកមន្ទីរពេទ្យឆ្កួត ដែលលោកអះអាងថា មន្ទីរសន្តិសុខនៅពេទ្យឆ្កួតតាខ្មៅដែរឬទេ?

**ឆ៖** ចេញពីមន្ទីរ១៥មក មានតែជាប់នៅពេទ្យឆ្កួតហ្នឹង អត់មាននៅកន្លែងណា ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសំរាកដើម្បីពិសាអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ បន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ។ មន្ត្រីតុលាការសម្របសម្រួលឲ្យលោក លី ហ៊ា ជាដើមបណ្តឹងរដ្ឋប្បវេណី បានទទួលកន្លែងសំរាកសមរម្យ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រងចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទីនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:១០នាទី ដល់ម៉ោង ១៣:៣១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លី ហ៊ា តទៅទៀត ។ កិច្ចបន្តនេះ សួរថាអស់លោក លោកស្រីចៅក្រម តើអស់លោកលោក ស្រីមានសំណួរអ្វី ដែលត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីនេះ រូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

អញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន ។ លោក លី ហ៊ា ខ្ញុំសូមថ្លែងអំណរគុណដែលលោកមកទីនេះ នៅថ្ងៃនេះដែលមកចូលរួមរៀបរាប់អំពីបទពិសោធន៍ដ៏អាក្រក់ដែលលោកជួបប្រទះកាលពីសាមសិបឆ្នាំមុន ។ ខ្ញុំដឹងថា វាមានការពិបាកណាស់សម្រាប់លោក ហើយលោកប្រហែលជាមានការភ័យខ្លាចណាស់ផងដែរ ដែលមកចូលរួមថ្ងៃនេះ ។ ខ្ញុំមានសំណួរបច្ចេកទេសមួយដើម្បីសួរលោក ។

**ស៖** តើលោកអាចជម្រាបខ្ញុំបានដែរឬទេ ថាលោកនិយាយជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកហ្នឹង នៅពេលណា? និយាយពីបទពិសោធន៍របស់លោកជាមួយនឹងពួកគាត់ហ្នឹង?

**ឆ៖** សូមមានយោបល់ឲ្យខ្ញុំបានច្បាស់ បានម្តងទៀត ។

**ស៖** ខ្ញុំសូមអភ័យទោស ដែលខ្ញុំមិននិយាយឲ្យបានច្បាស់ តើលោកធ្លាប់បាននិយាយជាមួយនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកនេះ តើលោកធ្លាប់និយាយជាមួយគាត់អំពីបទពិសោធន៍របស់លោកដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ ធ្លាប់បាននិយាយជាមួយនឹងមេធាវីរបស់ខ្ញុំ ពីថ្ងៃមុន ខែមុន ខ្ញុំមិនបានចាំខែ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណច្រើន ។ លោក វ៉ែនណឹ តើខ្ញុំសន្និដ្ឋានត្រឹមត្រូវដែរឬទេ លោកគឺជាមេធាវីម្នាក់ក្នុងចំណោមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់កូនក្ដីរូបនេះ?

**លោក អាឡាំង វ៉ែនណឹ៖**

គឺត្រឹមត្រូវ ។

[១៣:៣៤:៣៩]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើលោកអាចពន្យល់ខ្ញុំដែរឬទេ ហេតុអ្វីបានឯកសារទាំងអស់នេះ បានន័យថា លោកមិនបានដឹងឯកសារទាំងអស់នេះដែលឯកសារនេះត្រូវបានដាក់ ដើម្បីគាំទ្រទៅនឹងពាក្យសុំតាំងខ្លួនរបស់កូនក្ដីរបស់លោក?

**លោក អាឡាំង វ៉ែនណឹ៖**

លោកស្រីចៅក្រម! យើងមានភាគីផ្សេងទៀត ដែលបានស្នើសម្រាប់ការបកប្រែ ។ ដូច្នេះហើយការបកប្រែអត់បានធ្វើឡើង ។ ដូច្នេះហើយ គឺខ្ញុំមានការបកប្រែជា ក្រៅផ្លូវការសម្រាប់យល់ ដូចដែលខ្ញុំបានយល់នោះ គឺថាឯកសារបកប្រែមិនទាន់បានបកនៅឡើយនោះទេ ។ ហើយយើងខ្ញុំមួយចំនួនបានស្នើសុំឲ្យមានការបកប្រែ ខ្ញុំសូមអភ័យទោសដែលលោក លោកស្រីចៅក្រម បានលើកឡើងថា ខ្ញុំអត់បានដឹងទៅលើឯកសារទាំងអស់នេះ ។ ខ្ញុំតាមពិតទៅ ខ្ញុំធ្វើការតែលើឯកសារបកប្រែក្រៅផ្លូវការដែលបានផ្ដល់ជូនឲ្យខ្ញុំ ប៉ុន្តែខ្ញុំអត់មានឯកសារបកប្រែផ្លូវការ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំដឹងលោកធ្វើការងារលើឯកសារទាំងអស់នោះ ។ ប៉ុន្តែ លោកមានមេធាវីដែលមានសមត្ថភាពដែលជាមេធាវីជាតិខ្មែរ ហើយខ្ញុំដឹងថាលោកយល់ស្របជាមួយខ្ញុំ ហើយដើមបណ្ដឹងរដ្ឋប្បវេណីមួយនេះគឺគាត់មិនមានការរៀបចំឲ្យបានល្អចំពោះបទពិសោធន៍របស់គាត់ ក្នុងការមកចូលរួមរៀបរាប់ ។

**លោក អាឡាំង វ៉ែនណឺ៖**

សក្ខីកម្ម គឺដូចដែលគាត់បានជម្រាប ។ ប៉ុន្តែ យើងខ្ញុំអាចផ្តល់ការពន្យល់ទាំងអស់នេះ ជូនលោក លោកស្រីចៅក្រមបាន ។ យើងហៀបនឹងសួរសំណួរ ហើយខ្ញុំយល់ស្របថា យើងគួរតែធ្វើចំណុចទាំងអស់នេះតាំងពីមុន ។ ហើយយើងគួរតែស្នើសុំផ្នែកអន្តរការីឲ្យពន្យល់ថា ហេតុអ្វីបានជាយើងមានឯកសារទាំងអស់នេះ ហើយវាបានផ្តល់ជាពន្លឺយ៉ាងម៉េច ចំពោះលោក លោកស្រីចៅក្រម ។ ប៉ុន្តែ ខ្ញុំមិនយល់ស្របជាមួយនឹងលោកស្រីចៅក្រមដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមួយនេះមិនបានរៀបចំឲ្យបានត្រឹមត្រូវ ។

ខ្ញុំសូមជម្រាបថា ខ្ញុំបានជួបគាត់បីដងហើយយើងមានសក្ខីកម្ម ហើយគាត់ចង់មកថ្ងៃនេះដើម្បីរៀបរាប់អំពីបទពិសោធន៍របស់គាត់ ។ ដូច្នេះហើយ គឺយើងវាយតម្លៃថា គាត់នឹងអាចមកបាននៅថ្ងៃនេះ ។

[១៣:៣៧:១៨]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ខ្ញុំមិនមានការស្នើសុំឲ្យពន្យារ អំពីការរៀបរាប់អំពីបទពិសោធន៍របស់គាត់នៅក្នុងទីនេះទេ ។ ប៉ុន្តែវាគ្រាន់តែជាការបង្ហាញថា ខ្ញុំហើយនិងសហសេវិករបស់ខ្ញុំ ដែលជាចៅក្រមហ្នឹង យើងរំពឹងថា ធ្វើយ៉ាងណា ឲ្យមាន ឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ គាត់ឲ្យបានរៀបចំឲ្យបានត្រឹមត្រូវមុនពេលដែលមកផ្តល់សក្ខីកម្ម ។

សូមអរគុណ ។ អរគុណលោកប្រធាន ខ្ញុំអត់មានសំណួរផ្សេងទៀតសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រម ។ សូមអញ្ជើញលោក ចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សួស្តីលោក! ខ្ញុំសូមឲ្យធ្វើការឆ្លើយបំភ្លឺមួយចំនួន មិនមែនសម្រាប់តែអង្គចៅក្រមនោះទេ សម្រាប់ភាគីទូទៅផងដែរ ។

**ស៖** មុនពេលសវនាការនៅទីនេះ ថាតើលោកបានជួបជាមួយនឹងអ្នកស៊ើបអង្កេត ឬក៏នគរបាលដែរឬទេ ដែលលោកបានធ្វើការផ្តល់នូវចម្លើយរបស់លោកជូនទៅពួកគេនោះ?

**ឆ៖** ខ្ញុំបានជួបគាត់ពីថ្ងៃមុនម្ដងបាទ ។

**ស៖** ចាតើលោកបានជួបជាមួយនរណាគេ អ្នកស៊ើបអង្កេតមកពីតុលាការ អ.វ.ត.ក របស់យើង ឬក៏លោកជួបៗបុគ្គលផ្សេងមកពីអង្គការមួយដែលហៅថា មជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** ខ្ញុំជួបនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ស៖** ចាតើមជ្ឈមណ្ឌលឯកសារកម្ពុជា គឺគាត់បានប្រាប់លោកថា គាត់ជាអ្នកស៊ើបអង្កេតផ្លូវការ ឬក៏គាត់នោះប្រាប់ថា គាត់ជាអ្នកតំណាងតែប៉ុណ្ណោះមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** ខ្ញុំអត់បានចាំដែរ មិនដឹងគាត់មកពីណា ។

**ស៖** មុនពេលសវនាការនេះ តើលោកបានដឹងដែរឬទេថា យើងមានតុលាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ?

[១៣:៤០:២៤]

**ឆ៖** ខ្ញុំដឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអត់ដឹងថាតើខ្ញុំសួរសំណួរនេះទៅកាន់លោក ឬក៏សួរទៅមេធាវីរបស់លោកនោះទេ ខ្ញុំហាក់ដូចជាមិនសូវយល់ ថាតើអ្វីទៅជាមន្ទីរ៤៤ និងមន្ទីរ៤៣ នោះ? ខ្ញុំអត់ដឹងថា ឯកសារដែលយើងឃើញព្រឹកមិញទាំងអស់នោះ គឺបង្ហាញថា វាចេញមកពី ស-២១ ឬក៏វាបាន យើងគួរតែធ្វើការឲ្យបកស្រាយបំភ្លឺដែរឬទេ? ដូច្នេះហើយខ្ញុំសូមអញ្ជើញភាគី ឬក៏មេធាវីឲ្យធ្វើការផ្ដល់ព័ត៌មានបញ្ជាក់ទៅលើ ចំណុចនេះ ដោយសារតែវាមានការភ័ន្តច្រឡំណាស់ ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំមានភាពស្ទាក់ស្ទើរក្នុងការផ្ដល់ភស្តុតាងពីក្រុមរបស់យើង ប៉ុន្តែនៅក្នុងពេលនេះ គឺយើងអាចបញ្ជាក់បាន ដូចដែលខ្ញុំបានជម្រាបលោកស្រីចៅក្រម ខាតវ៉ាយថ៍ យើងបានស្នើសុំលិខិតបញ្ជាក់នៅក្នុងសំណុំរឿងនេះ គឺយើងនឹងធ្វើការស្នើសុំលិខិតបញ្ជាក់ គឺវាលិខិតនេះ គឺជាលិខិតមួយដែលបាន យើងបានអាននៅលើឯកសារដែលបានចេញមកពីទួលស្លែង ។ ដូច្នេះហើយ ការយល់របស់ខ្ញុំ គឺគេប្រាប់ខ្ញុំតាំងពីដំបូង ហើយយើងកំពុងតែធ្វើការទៅលើឯកសារ និងការស្មានទាំងអស់នេះ ហើយឃើញមានបញ្ហានេះទាក់ទងមិនបានបកប្រែឯកសារ ហើយចៅក្រម ខាតវ៉ាយថ៍ គាត់បាននិយាយហើយ យើងធ្វើ

ការក្នុងស្ថានភាពមួយលំបាក ។ ប៉ុន្តែខ្ញុំមិនមែនជាការលើកយកលេសនោះទេ ហើយឯកសារទាំងឡាយ មិនបានបកប្រែជាផ្លូវការ ដូច្នេះហើយយើងមិនបានយល់ច្បាស់ចំពោះយើងខ្ញុំទាំងអស់គ្នា ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសួរថា ថាឯកសារទាំងអស់នេះ វាបានបង្ហាញក្នុងលក្ខណៈណាក៏ដោយ តែឯកសារវាបាន បង្ហាញអំពីសេចក្ដីពិតដែរឬទេ ដែលថាដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបនេះត្រូវបានគេឃុំនៅស-២១ ?

**លោក អាឡាំង វែនណឺ៖**

ឯកសារនេះគឺយើងបានរកឃើញ ហើយយើងទទួលបានមកពីស-២១ ហើយខ្ញុំយល់ថា ឯកសារ ដើមនៅស-២១ នៅឡើយ ។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារថតចម្លង ហើយបានផ្ដល់ ជូនយើងខ្ញុំ នេះគឺជាអ្វីដែលខ្ញុំយល់ ។ ជាថ្មីម្ដងទៀត ខ្ញុំសូមលើកឡើងថា យើងនឹងទទួលលិខិតធានា និងបញ្ជាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលិខិតនោះនឹងបញ្ជាក់ថា ឯកសារហ្នឹងរកឃើញ ហើយផ្ដល់យើង មកតាមយើងខ្ញុំ ។ ឯកសារនេះ គឺឯកសារដែលរកឃើញនៅស-២១ ។

[១៣:៤៣:៣៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមនិយាយសំណួរខ្ញុំម្ដងទៀត ។ ខ្ញុំយល់អ្វីដែលលោកលើកឡើង ថាឯកសារនេះ គឺរកឃើញ នៅ ស-២១ ប៉ុន្តែមិនមែនខ្ញុំសួរសំណួរនេះទេ ។ សំណួររបស់ខ្ញុំនោះ គឺថា ថាតើឯកសារទាំងអស់នេះ ជាឯកសារនេះ បានបង្ហាញសេចក្ដីពិតថា ជនដើមបណ្ដឹងរដ្ឋប្បវេណីនេះ ត្រូវបានជាប់ឃុំនៅស-២១ ដែរឬទេ?

**លោក អាឡាំង វែនណឺ៖**

គឺវាអាចសក្ខីកម្មនៅក្រោយៗទៀត ដែលបានបង្ហាញអំពីចំណុចនេះ ហើយទៅតាមមើលច្បោលៗ ទៅលើឯកសារនេះ គឺឯកសារនេះចេញមកពីស-២១ ទោះបីមិនមានការបញ្ជាក់ថា ឯកសារនេះមក ចេញមកពីស-២១ ក៏ដោយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សំណួរខ្ញុំសួរបន្ទាប់ទៀត ។ តើលោកដឹងថា មន្ទីរ៤៤ មន្ទីរ៤៣ នេះមានន័យយ៉ាងម៉េច?

**លោក អាឡាំង វែនណឺ៖**

ហើយខ្ញុំមិនអាចលើកឡើងនិងផ្ដល់ព័ត៌មានបន្ថែមទេ ហើយខ្ញុំជឿថា ដើមបណ្ដឹងរដ្ឋប្បវេណីរូប

នេះ គាត់បានផ្តល់ចម្លើយកាលពីព្រឹកមិញហើយ ។

[១៣:៤៥:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំមិនមានសំណួរនោះទៀតទេ លើកលែងតែជនជាប់ចោទគាត់ចង់ជម្រាបយើងថាតើមន្ទីរ៤៤ហ្នឹង និង៤៣ហ្នឹង គឺជាមន្ទីរអ្វី? ឬក៏ខាងសហព្រះរាជអាជ្ញាអាចជម្រាប ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ខ្ញុំគិតថាភាគីណាមួយអាចបញ្ជាក់ និងបំភ្លឺទៅលើចំណុចមន្ទីរ៤៤ និង៤៣ នេះ ។

**ប្រធានអង្គជំនុំ៖**

មានទេ? ខាងសហព្រះរាជអាជ្ញាមានអីបញ្ជាក់អំពី៤៤ និង៤៣ នេះទេ កន្លែងអីគេទៅ? បញ្ជូនទៅ៤៤ បញ្ជូនទៅ៤៣ហ្នឹង? ឬក៏អត់ដឹងទេ?

**លោក រ៉ូបឺត ពើទីត៖**

សូមគោរពលោក លោកស្រីចៅក្រម ជាការអកុសលនៅដំណាក់កាលនេះគឺយើងខ្ញុំមិនដឹងទេ ។ ហើយព័ត៌មានយើងមិនទទួលបានអំពីមន្ទីរទាំងពីរនេះទេ ដែលក្នុងរយៈពេលខ្លីនៅពេលបាយថ្ងៃត្រង់ គឺយើងមានរយៈពេលខ្លីពេក ដូច្នេះ យើងមិនទទួលបានព័ត៌មាននោះទេ ។ ដូច្នេះ យើងនឹងធ្វើការព្យាយាមស្វែងរកព័ត៌មានបញ្ជាក់បន្ថែមទៅលើចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ តើលោកដែលបានទទួលព័ត៌មាន ឬក៏ឮថាមន្ទីរ៤៤ ឬក៏៤៣ នេះទេ? ព្រោះនៅមន្ទីរ៤៤, ៤៣ នេះមានការពាក់ព័ន្ធជាមួយនឹងតំបន់២៥ ហើយលោកធ្លាប់បាននិយាយច្រើនពាក់ព័ន្ធជាមួយនឹងតំបន់២៥ ហើយ-- ឬក៏ភូមិភាគនីរតីអ៊ីចឹង សួរថា៤៤ ឬក៏៤៣ ជាមន្ទីរអីគេទៅដែលមានការបញ្ជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទៅដល់មន្ទីរ៤៤ រួចមក ៤៣ នោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! មន្ទីរ៤៤ នេះ អង្គាល់ដែលខ្ញុំធ្វើការនៅស-២១ នៅឡើយ ខ្ញុំអត់ច្បាស់ទេ ក៏ប៉ុន្តែឯកសារនៅសល់មាន គឺឯកសារលេខ D57 Index 003 ដែល ណាត បញ្ជាឲ្យគេកម្ទេចមនុស្ស៤៩នាក់ ក្រោមរូបភាពដោះលែង ។ ចំណងជើងដាក់ថា អនុសេនាធំលេខ៤៤ វរសេនាតូច៩៦ កងពល៧០៣ ។ តាមឯកសារនេះ ខ្ញុំជឿថា ៤៤ គឺជាមន្ទីរនគរបាលកងពល៧០៣ ដែលកកើតឡើងតាំងពីក្រោយ ១៧ មេសា ហើយដែលណាត ផ្តៀតឱកាសគ្រប់គ្រង នេះ ៤៤ ។ ចំណែក

៤៣ ខ្ញុំមិនទាន់មានឯកសារអីយកមកបញ្ជាក់ទេ ។ ក៏ប៉ុន្តែ សូមសន្និដ្ឋានបណ្តោះអាសន្នជូនអង្គជំនុំជម្រះយើងពេលនេះថា ៤៣ គឺតាខ្មៅ ពេទ្យឆ្កួត ។ ដូច្នេះ ៤៣ នេះមិនទាន់ច្បាស់ទេ រង់ចាំក្រែងមានឯកសារផ្សេងទៀត នេះសូមបញ្ជាក់ជូនលោកប្រធាន និងអង្គសវនាការយើងទាំងមូល ។ សូមចប់ ។

[១៣:៤៨:២៦]

**ប្រធានអង្គជំនុំ៖**

លោកជនជាប់ចោទដឹងទេថា មន្ទីរ៤៤ហ្នឹងមានទីតាំងនៅឯណា?ទីតាំង៤៤ហ្នឹងនៅកន្លែងណា?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំអត់បានដឹងទេទីតាំង៤៤ វិភាគនេះ គឺវិភាគសន្និដ្ឋានតាមឯកសារដែលនៅសល់ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះតាមការយល់ពីអ្វីដែលជនជាប់ចោទបានលើកឡើង ជនជាប់ចោទបានលើកឡើងឯកសារ D57 ឧបសម្ព័ន្ធ លេខ៣ ឯកសារនេះគឺមានចំណងជើងមានជាភាសាបារាំង គឺទាក់ទងទៅនឹងសេចក្តីសង្ខេប ទាក់ទងទៅនឹងមន្ទីរសន្តិសុខ៤៤ ចំពោះការដោះលែង ប្រហែលជាវាជាបញ្ហាបកប្រែទៅលើចំណុចនេះ ថាតើវាមានន័យថាមន្ទីរ៤៤ យ៉ាងម៉េចតាមឯកសារនេះ? ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងករណីណាក៏ដោយ ឯកសារនេះបានបង្ហាញថា វាទាក់ទងទៅនឹងមេបញ្ជាការនៅវរសេនាតូច៩៦ គឺវរសេនាតូច៩៦ ហើយខ្ញុំអាចផ្តល់ERN ជាភាសាខ្មែរគឺលេខ 00068840 គឺដល់លេខ 000068843 ប្រហែលយើងអាចរកថា តើវាមានបង្ហាញអ្វីខ្លះនៅក្នុងឯកសារភាសាខ្មែរដើមនោះ ហើយយើងស្វែងរកថាតើមានមន្ទីរ៤៤ ដែលស្ថិតនៅក្រោមការក្តោបក្តាប់របស់កងពល៧០៣ ដែរឬទេ?

**លោក រ៉ូប៊ីត ពើទីត៖**

ដូច្នេះ ខ្ញុំសូមស្នើថា ឲ្យអង្គសវនាការបន្តដំណើរការក្តីរបស់យើង ហើយយើងអាចផ្ទៀងផ្ទាត់ព័ត៌មានទាំងអស់នេះនៅពេលក្រោយ បើសិនជាយើងអាចធ្វើទៅបាន ។

**លោកស្រី ស៊ីលឃីស្លួត ហ្សីនស្កី៖**

ខ្ញុំសូមជម្រាបអង្គសវនាការនិងភាគី ឯកសារដែលរៀបរាប់អំពីមន្ទីរ៤៤ ជាភាសាអង់គ្លេស គឺ

ថាវាជាផ្នែកមួយនៃស-២១ ហើយឯកសារនោះគឺមានលេខ ERN00142092 វាជាកំណត់ហេតុនៃការសម្ភាស ហើយឯកសារដែលបញ្ជាក់ចំណុចនេះ គឺមានបញ្ជាក់នៅក្នុងឯកសារលេខ 00142091 ហើយខ្ញុំសូមលើកឡើងថា លេខឯកសារគឺមានលេខ D2.3/3 ។

[១៣:៥២:៥២]

**សួរដោយប្រធានអង្គជំនុំ៖**

ខាងផ្នែកសោតទស្សន៍សូមបញ្ចាំងនូវឯកសារនេះសាជាថ្មីម្តងទៀត ដែលមានលេខ ERN0027 9927 ជាភាសាខ្មែរ ។

ផ្នែកខាងសោតទស្សន៍អាច-- (OK)

**ស៖** លោក លី ហ៊ា លោកបាននិយាយថា លោកបានជួបជាមួយនិងអ្នកស៊ើបអង្កេតខាងមជ្ឈមណ្ឌលឯកសារកម្ពុជា *ឌីស៊ីខេម* តើខាងមជ្ឈមណ្ឌលឯកសារហ្នឹង គេបានធ្វើកំណត់ហេតុសួរស្តាប់ចម្លើយរបស់លោកដែរឬទេ? ហើយបើគេធ្វើ គេធ្វើពីពេលណា? គេមានការកត់ត្រាជាអក្សរដែរទេ?

**ឆ៖** កាលពីខែមុន ថ្ងៃមុនគឺខ្ញុំបានជួបនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺគាត់បាននិយាយជាមួយខ្ញុំ ប៉ុន្តែត្រង់គាត់កត់ មិនកត់នោះ គឺខ្ញុំមិនបានដឹងទេ គឺខ្ញុំមិនបាទ-- គាត់បាននិយាយជាមួយខ្ញុំពិតមែន ។

**ស៖** លោកមានបានផ្តិតមេដៃលើឯកសារដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** ខ្ញុំមិនបានចាំដែរត្រង់ផ្តិតមេដៃហ្នឹង ប៉ុន្តែខ្ញុំបាននិយាយជាមួយគាត់ គឺបាននិយាយមែន ប៉ុន្តែ ផ្តិតមេដៃខ្ញុំមិនបានដឹងទេ ។

**ស៖** បានជាយើងសួរអ៊ីចេះ ពីព្រោះកំណត់ហេតុនេះយើងមើលនៅបន្ទាត់ពីរ-- ដើមពីរបន្ទាត់ដំបូង ឆ្នាំ១៩៧៥ ខែវិច្ឆិកា ថ្ងៃទី១០ ម៉ោង៧យប់ ឈ្មោះ អ៊ា ហ៊ា បានឆ្លើយបន្ថែមឲ្យព័ត៌មានដូចខាងក្រោម ។ នេះជាចំណុចកត់សម្គាល់ទីមួយ នូវរបៀបធ្វើកំណត់ហេតុនៃការចាប់ផ្តើមដោយសរសេរកាលប្រវត្តិនៃការធ្វើកំណត់ ដោយសរសេរលាយលក្ខណ៍អក្សរយ៉ាងច្បាស់លាស់ ជាភាសាជាអក្សរ លេខឆ្នាំខែអីហ្នឹង គឺជាអក្សរ នេះជាចំណុចមួយដែលមានការចាប់អារម្មណ៍ ។ ហើយខាងសោតទស្សន៍អាចរំកិលអត្ថបទនេះទៅលើ រហូតដល់មើលខាងជួរខាងក្រោម ។

[១៣:៥៦:១២]

នៅខាងក្រោមនេះ គឺបន្ទាត់ពីរបីបន្ទាត់ខាងក្រោមនេះសរសេរដូច្នេះ៖

“ចម្លើយចប់បណ្ដោះអាសន្ននៅម៉ោងម្ភៃពីរ និងដប់នាទី ដោយសូត្រឲ្យ អ៊ា ហ៊ា ស្ដាប់ រួចសាមីខ្លួនបានបញ្ជាក់ថាត្រឹមត្រូវមែន ។ កម្មាភិបាលស៊ើបអង្កេត ហត្ថលេខា ជាម ស្នាមមេដៃស្ដាំ អ៊ា ហ៊ា” ។ ឃើញថាទម្រង់នៃកំណត់ហេតុ ទាំងការផ្ដើម ទាំងការបញ្ចប់នេះ មានទម្រង់មួយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងទម្រង់ដែលអនុវត្តន៍ទូទៅនៅកំណត់ហេតុបច្ចុប្បន្ននេះ ដែលទម្រង់នេះកាលពីកំណត់ហេតុរបៀបធ្វើពេលមុន ជំនាន់នុ៎ង ដូចជាមានជួបនូវទម្រង់បែបនេះទេ ។ នេះគ្រាន់តែជាការកត់សម្គាល់ទេ ដែលមានលក្ខណៈនេះ ហើយ “អានសូត្រឲ្យ អ៊ា ហ៊ា ស្ដាប់រួចសាមីខ្លួនបានបញ្ជាក់ថាត្រឹមត្រូវមែន” នេះ ។ ផ្នែកខាងសោតទស្សន៍បង្វែរទៅរូបភាពធម្មតាឡើងវិញ ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិកានេះជូនទៅតំណាង-- ទៅសហព្រះរាជអាជ្ញាប្រសិនបើមានសំណួរអ្វីសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន ។

**ស៖** ជម្រាបសួរលោក លី ហ៊ លោកបាននិយាយថា លោកត្រូវបានគេចាប់ទៅគុកតាខ្មៅ ដែលហៅថាមន្ទីរពេទ្យឆ្កួតនោះ ។ តើលោកដឹងទេថា មន្ទីរពេទ្យឆ្កួតនោះជាកន្លែងអ្វីដែរ? ហើយហេតុអ្វីបានជាគេចាប់លោកទៅទីនោះ?

**ឆ៖** ខ្ញុំមិនបានដឹងអីដែរ គឺកន្លែងពេទ្យឆ្កួតហ្នឹង ខ្ញុំមិនបានដឹងទេ គ្រាន់ថាគេចាប់ទៅ ខ្ញុំដឹងតែថាពេទ្យឆ្កួតកន្លែងហ្នឹង ។

**ស៖** អរគុណ ។ នៅ-- លោកបានថា បានជម្រាបអង្គសវនាការថា លោកត្រូវបានគេបញ្ជូនមកទួលស្លែង ហើយលោកត្រូវបានគេសួរចម្លើយម្ដង ។ តើលោកចាំទេថា អ្នកសួរចម្លើយនោះឈ្មោះអ្វីដែរលោកដឹងទេ?

**ឆ៖** ខ្ញុំអត់បានចាំទេ ឈ្មោះអ្នកសួរចម្លើយនោះ ។

**ស៖** តើលោកអាចរៀបរាប់ពីភិនភាគបន្តិចបានទេ?

**ឆ៖** អ្នកសួរចម្លើយនោះភិនភាគរបស់គាត់រាងខ្មៅស្រអែមបន្តិច ប៉ុន្តែ រាងស្គមល្មម មិនខ្ពស់មិនទាប ។

[១៤:00:0៥]

**ស៖** តើលោកធ្លាប់ជួប ឌុច ទេនៅស-២១ នោះ?

**ឆ៖** អត់បានជួបទេ ។

**លោកសេង ប៊ុនឃាង៖**

លោកប្រធាន! ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនមានសំណួរទេ ប៉ុន្តែសុំអនុញ្ញាតថា អរគុណដល់សាក្សីដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់បានអញ្ជើញមកថ្ងៃនេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់វេទិកាមេធាវីតំណាងអ្នកដើមបណ្តឹងរដ្ឋប្បវេណី ។ សួរថាតើសុំចំណាយពេលយ៉ាងម៉េចទៅលោកមេធាវី? តើត្រូវចែកគ្នាដប់មីនុតម្នាក់ ឬក៏លោកប្រើប្រាស់នូវអំឡុងពេលដែលជាកូនក្តីរបស់លោកហ្នឹងលោកប្រើច្រើន ហើយសល់-- បើមានសល់ពេលបានទុកប្រគល់ឲ្យទៅមេធាវីក្រុមផ្សេងទៀត?

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន ដោយមានការយល់ព្រមពីសហសេវិករបស់ខ្ញុំ ខ្ញុំនឹងប្រើពេលច្រើនម្នាក់ឯងសិនដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**សួរដោយ លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។

**ស៖** ខ្ញុំសុំសួរសំណួរដំបូងទៅលោក លី ហ៊ា ពីព្រឹកមិញនេះ ខ្ញុំមិនទាន់ច្បាស់ ។ លោកបានពន្យល់តុលាការថា ថាលោកបានជួបអ្នកយាម ហើយគេប្រាប់លោកថា កន្លែងហ្នឹងឯង អ្នកយាមប្រាប់ថាជាស-២១ ។ ហើយក្រោយមក លោកបានបញ្ជាក់ថា នៅពេលបានចេញពីស-២១ លោកបានទៅ

ស-២៤ ជាព្រៃ-សនោះ ហើយគេក៏ប្រាប់លោកដែរថា លោកមកពីស-២១ ។

[១៤:០២:៥២]

អ៊ីចឹង ខ្ញុំសួរដូចខាងក្រោមនេះ តើគេប្រាប់លោកប៉ុន្មានដងអំពីថាកន្លែងនោះ ដែលកន្លែងឃុំខ្លួនលោកនោះជាស-២១? តើគេប្រាប់លោកម្តង ឬក៏ច្រើនជាងម្តង?

**ឆ៖** មកពីខ្ញុំបានដឹងថា ស-២១ នេះ ពួកអ្នកយាមដែលយាមអ្នកទោសហ្នឹង បានស្គាល់ជាមួយនឹងខ្ញុំហ្នឹងក៏គេប្រាប់ថា ឯងទើបហ្នឹងចេញពីស-២១នេះ ឯងលែងយ៉ាងម៉េចកុំរត់ទៀត បើរត់ថ្ងៃក្រោយច្បាស់ជាស្លាប់ បានខ្ញុំជឿជាក់ថា ខ្ញុំដឹងថា ខ្ញុំចេញពីស-២១ ។

**ស៖** អ៊ីចឹង សូមឲ្យលោកបំភ្លឺ ដើម្បីឲ្យខ្ញុំច្បាស់ ហើយលោក-- អ៊ីចឹងគឺថា ពេលដែលលោកទៅដល់ស-២១ គេមិនបានប្រាប់ទេ ទាល់តែលោកចេញពីស-២១ ទៅព្រៃស បានគេប្រាប់ តើអ៊ីចឹងឬ?

**ឆ៖** បាទ ។

**លោក អាឡាំង វ៉ែនណឺ៖**

ឥឡូវនេះ គឺថាដោយលោកចៅក្រម នៅមានការអនុញ្ញាតនោះ ខ្ញុំសូមពិនិត្យមើលឯកសារលេខ ERN 0027991 នៅលើអេក្រង់ ។

**ប្រធានអង្គជំនុំ៖**

ខាងផ្នែកសោតទស្សន៍ សូមដាក់បញ្ចាំងនូវឯកសារដែលតាមសំណើសុំរបស់មេធាវីរូបនេះ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** ដូច្នេះ ឯកសារនេះ ពីព្រឹកមិញនេះ បានអានដើម្បីកត់ត្រានោះ ខ្ញុំនឹងសួរដូចខាងក្រោមដោយសារយើងមិនច្បាស់ តើលោកអាចបញ្ជាក់ទេថា នៅលើ-- ការសរសេរដោយដៃនៅលើឯកសារនេះមិនមែនលោកសរសេរខ្លួនឯងទេ ឬយ៉ាងដូចម្តេច?

**ឆ៖** អក្សរនេះ គឺមិនមែនជាអក្សររបស់ខ្ញុំទេ ។

[១៤:០៥:៣៣]

**ស៖** តើលោកដឹងទេថា អ្នកណាជាអ្នកកត់ត្រា អ្នកសរសេរផ្ទាល់ដៃនេះ?

**ឆ៖** អក្សរនេះ គឺខ្ញុំក៏មិនបានដឹងដែរ មិនដឹងជាអក្សរអ្នកសួរចម្លើយខ្ញុំផ្ទាល់ ឬមួយក៏អក្សរពីណាខ្ញុំអត់បានដឹង ។

**ស៖** ដូច្នេះ ខ្ញុំសុំសួរសំណួរតទៅទៀតអំពីឯកសារនេះ នៅពេលដែលលោក គេយកទៅដល់ស-២១ តើលោកធ្លាប់បានឮឈ្មោះ អ្នកសួរចម្លើយឈ្មោះ ចាន់ ដែរឬទេនៅស-២១ នោះ?

**ឆ៖** អត់ឮទេ ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណ លោកប្រធាន លោកចៅក្រម ។ សូមបង្វែររូបភាពមកធម្មតាវិញ ។

**ប្រធានអង្គជំនុំ៖**

ខាងផ្នែកសោតទស្សន៍បង្វែររូបភាព ទៅជារូបភាពធម្មតាឡើងវិញ ។

**សួរដោយលោក អាឡាំង វែនណឺ៖**

**ស៖** ដូច្នេះ សួរតទៅទៀត ។ អ៊ីចឹងគឺថា យើងមានចម្លើយសារភាពពីរ ព្រឹកនេះដែលយើងបានអានឱ្យលោកស្ដាប់នោះ ជាខ្លឹមសារទាំងស្រុង ។ អ៊ីចឹងហើយខ្ញុំមានសំណួរខ្លះ ទាក់ទងទៅនឹងចម្លើយសារភាពនោះ ។ តើលោកនៅតែប្រកាន់ តើលោកគិតថា លោកមិនចាំទេថាការកត់ត្រាសេចក្ដីសារភាពហ្នឹងធ្វើឡើងនៅតាខ្មៅ ឬក៏នៅស-២១ ។ តើលោកនៅចាំទេ?

**ឆ៖** គឺខ្ញុំអត់បានចាំទេ ។ អក្សរនេះ មិនដឹងជាធ្វើនៅតាខ្មៅ ឬមួយនៅហ្នឹងគុកទួលស្លែង ។

**ស៖** ដូច្នេះ ដូចដែលយើងបានអានចេញពីកំណត់ត្រាឯកសារព្រឹកនេះ នៅក្នុងចម្លើយសារភាពពីរនេះ លោកបានបញ្ជាក់ថា នូវឈ្មោះមនុស្សមួយចំនួន លោកបាននិយាយអំពីឈ្មោះ សារ៉េត លោកនិយាយអំពី គៀម ជាង ហើយនិងឈ្មោះ ឆាំង ដែលយើងហៅឈ្មោះថា តាព្រង ហើយនិង ចាន់ ស៊ី ។ ដើម្បីឱ្យយើងមានការច្បាស់លាស់ អំពីទាក់ទងទៅថាតើនៅពេលសួរចម្លើយនោះ យ៉ាងដូចម្ដេចថាហេតុអ្វីបានជា លោកបានបញ្ជាក់ពីឈ្មោះទាំងអស់នេះនៅក្នុងចម្លើយសារភាពនេះ ហេតុអ្វីបានជាលោកបញ្ជាក់ឈ្មោះអ្នកទាំងអស់ហ្នឹង?

**ឆ៖** មូលហេតុដែលខ្ញុំបញ្ជាក់ឈ្មោះទាំងអស់ហ្នឹង គេសួរថា រកមេ ពីណាអ្នកដឹកនាំបក្សពួករបស់អ្នកឯងមានប៉ុន្មាននាក់ គឺឱ្យខ្ញុំប្រាប់ពួកគេ ។

[១៤:០៨:២២]

**ស៖** ប៉ុន្តែ ដើម្បីឱ្យយើងច្បាស់នោះ តើគេមានបង្ខិតបង្ខំលោក ដើម្បីឱ្យលោកបញ្ជាក់ប្រាប់ឈ្មោះ ទៅគេទេ ឈ្មោះទាំងអស់នេះដែលនិយាយខាងដើម?

**ឆ៖** គេបានសម្លុតខ្ញុំសួររកមេ និងបក្សពួករបស់ខ្ញុំហ្នឹង បានខ្ញុំឆ្លើយប្រាប់គេទាំងអស់ នុ៎ង ។

**ស៖** តើលោកបានដឹងទេ ថាតើមានរឿងអ្វីកើតឡើងចំពោះ សារ៉េត, គឹម ឆាំង, ជី គាង ហើយ និង តាព្រុង ក្រោយពីលោកឆ្លើយមក ថាតើអ្នកទាំងអស់នោះជួបហេតុការណ៍អីដែរ?

**ឆ៖** ក្រោយពីដែលខ្ញុំបានឆ្លើយសារភាព ដែលប្រាប់ឈ្មោះទាំងអស់នោះ គឺខ្ញុំអត់បានដឹង ព្រោះខ្ញុំ ជាប់រហូតមក ទៅដល់ផ្ទះវិញក៏អត់បានដឹងដែរ មិនដឹងជាទៅណា ព្រោះភូមិឆ្ងាយៗពីគ្នា ។

**ស៖** ឥឡូវនេះ ដើម្បីឲ្យលោកបញ្ជាក់អ្វីដែលលោកបាននិយាយព្រឹកមិញនេះ លោកបានពន្យល់ថា លោកគេមិនបានវាយដំលោកទេ នៅពេលដែលគេសួរចម្លើយ ។ ប៉ុន្តែលោកបានបញ្ជាក់ថា នៅពេលដែលថា នៅកន្លែងឃុំខ្លួនលោក នៅស-២១ នៅពេលដែល-- ធុងនុំងពេញដោយលាមក ឬក៏ទឹកនោម ហើយអ្នកណាកម្រើកហ្នឹង គឺថាគេធ្វើទារុណកម្ម គេវាយដំ តើលោកអាចបញ្ជាក់ដូចម្ដេចលើរឿងនេះ?

**ឆ៖** រឿងអស់នេះ គឺវាពិតមែន ក្នុងរយៈបីថ្ងៃអ៊ីចឹងទៅ បានគេអ្នកយាមហ្នឹង គេប្រើអ្នកទោសនុំងឲ្យយកទៅចាក់ចោលអ៊ីចឹង ហើយនិងកំពប់ទឹកនោម កំពប់អីហ្នឹង នេះហ្នឹង នៅកន្លែងហ្នឹង គេវ៉ៃយើង ហើយនិងស្រែកឡូឡា និយាយគ្នាឮៗហ្នឹង ក៏គេវ៉ៃយើងដែរ ។

**ស៖** អ៊ីចឹងនៅពេលដែលលោកជាប់ឃុំនៅកន្លែងនុំង តើគេវាយដំលោកប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំចង់សួរ ថាតើនៅអើយៗ គុកទួលស្លែង ឬមួយនៅតាខ្មៅ?

**ស៖** បាទ គឺសួរនៅស-២១ នៅពេលដែលលោកជាប់ឃុំមួយនោះ នៅកន្លែងឃុំខ្លួនមួយ គឺថាមានអ្នកទោសត្រូវបានគេវាយដំ នៅពេលដែលគេឡូឡា ឬក៏គេធ្វើឲ្យកំពប់ទឹកនោមអីនុំង ថាតើលោកបានឃើញហេតុការណ៍នុំងប៉ុន្មានដង ការវាយដំហ្នឹង?

**ឆ៖** ហេតុការណ៍ដែលកើតនៅស-២១ ដែលធ្វើឲ្យកំពប់ទឹកនោម និងស្រែកឡូឡា ដែលធ្វើទារុណកម្មមកលើអ្នកទោសហ្នឹង គឺវាមានច្រើនដង ។

**ស៖** ហើយនិងផ្ដោតអារម្មណ៍ទៅលើសំណួរ ថាតើលោករងការវាយដំដែរឬទេ នៅក្នុងកន្លែងឃុំខ្លួននៅក្នុងស-២១ នោះ?

[១៤:១២:៣៥]

**ឆ៖** ថ្ងៃមួយដែលខ្ញុំបានធ្វើកំពប់ទឹកនោមហ្នឹង គឺគេបានវាយខ្ញុំ ហើយបង្អត់បាយខ្ញុំមួយពេលទៀត ។

**ស៖** ពីព្រឹកមិញនេះ លោកបានបញ្ជាក់ ប៉ុន្តែយើងមិនទាន់ច្បាស់ទេនៅក្នុងការកត់ត្រា លោកបានឮសំឡេងស្រែកនៅពេលដែលគេឃុំខ្លួនលោកនៅស-២១ តើលោកនៅចងចាំទេ បានឮសំឡេងរបស់មនុស្សផ្សេងនៅកន្លែងនោះ?

**ឆ៖** ពេលល្ងាចម៉ោងប្រាំពីរ ម៉ោងប្រាំបី ម៉ោងប្រាំបួនយប់ គឺខ្ញុំឮសូរតែសំឡេងស្រែក “អូយៗ” តែអ៊ីចឹងសឹង រាល់ល្ងាច ។

**ស៖** នៅពេលដែលលោកនៅកន្លែងឃុំខ្លួននៅស-២១ នោះតើៗលោកធ្លាប់បានឃើញអ្នកទោសណាម្នាក់ដែលគេទើបតែយកត្រឡប់មកពីកន្លែងសួរចម្លើយដែរឬទេ?

**ឆ៖** ខ្ញុំមិនបានឃើញទេ ។

**ស៖** ខ្ញុំនឹងសួរសំណួរម្តងទៀត ។ នៅពេលដែលគេដាក់លោកនៅកន្លែងឃុំខ្លួន តើលោកបានឃើញអ្នកណាម្នាក់ជាអ្នកទោសដែលត្រឡប់មកវិញ មកចូលកន្លែងឃុំខ្លួនវិញ ដែលបន្ទាប់ពីគេសួរចម្លើយហើយ គេយកមកវិញនោះ ។

**ឆ៖** ចំពោះអ្នកទោសដែលគេយកចេញទៅ យកទៅសួរចម្លើយ គឺខ្ញុំអត់បានឃើញចូលមកវិញទេ ។

**ស៖** តើលោកបានឃើញ អ្នកទោស គេយកចេញពីសួរចម្លើយហ្នឹងច្រើនប៉ុន្មានដង ដែលថាមិនឃើញត្រឡប់មកវិញ ឃើញប៉ុន្មានដង ឬក៏ឃើញតែម្តងទេ?

[១៤:១៥:០៤]

**ឆ៖** អ្នកទោសដែលនៅជាប់ជាមួយខ្ញុំហ្នឹង ដែលឃើញយកចេញទៅនឹងៗវាឃើញយកតែទៅហើយគឺអត់មានឃើញយកចូលមកវិញ ។ វាមិនច្រើនប៉ុន្មានទេ កន្លែងខ្ញុំវាជាប់ជាងដប់នាក់ ។

**ស៖** ព្រឹកមិញនេះលោកបានពន្យល់ថា គេបានដាក់ខ្នោះដៃលោក ។ បន្ទាប់ពីឃុំខ្លួននៅស-២១ ថាតើទទួលរងនូវរបួសស្នាមឬក៏អ្វីនៅលើដៃ ឬនៅកន្លែងណាលើរាងកាយរបស់ខ្លួនលោកទេ ក្រោយពីឃុំខ្លួនមក?

**ឆ៖** គឺដែលស្លាកស្នាមពីដែលខ្ញុំជាប់នឹងគឺមានស្លាកស្នាមដំបៅកជើង ហើយនឹងខ្ទាំមួយចំហៀងខ្លួន ហើយនិងដៃដែលគេចងស្លាក់ឈឺរហូតដល់សព្វថ្ងៃនេះ ហើយនិងក្បាលមានស្លាកស្នាមនៅរហូត ។

**ស៖** ហើយបន្ទាប់ពីលោកត្រូវបានគេឃុំខ្លួននៅស-២១ តើក្រោយមកលោកអាចប្រើដៃដែលថានៅខាងស្តាំដៃហ្នឹងជាធម្មតាវិញដែរឬទេ?

**ឆ៖** ក្រោយពីមានស្លាកស្នាមមក ដៃហ្នឹង គឺអត់មានប្រើការធ្វើការអីធ្ងន់បានទេ ។ ដៃឆ្វេងមួយ ចំហៀងធ្វើការធ្ងន់មិនបាន ។

**ស៖** តើហេតុហ្នឹង គឺដោយសារតែការៗដាក់ខ្នោះ ឬក៏ដោយសារអំពើអ្វីផ្សេងដែលធ្វើឲ្យដៃ ហ្នឹងមិនអាចប្រើការងារធ្ងន់បាន?

**ឆ៖** តាមដែលខ្ញុំដឹងនេះមក គឺធ្វើដាក់ខ្នោះខ្ញុំ ហើយនិងវ៉ៃៗត្រូវ ។

**ស៖** ចាតើរយៈពេលប៉ុនណាដែរ ដែលថាលោកមិនអាចប្រើដៃហ្នឹងធ្វើការអីធ្ងន់នឹងយូរប៉ុនណា ដែរហើយ?

**ឆ៖** ទើបដែលខ្ញុំចាប់អារម្មណ៍បួន,ប្រាំ,ប្រាំមួយឆ្នាំមុននេះ គឺខ្ញុំមិនដឹង អត់ដឹងៗ តែវាធ្វើសកម្ម ភាពយើងដឹងថា មនុស្សយើងវិលសរសៃប្រសាទ ។ ខ្ញុំចេះតែមួម៉ៅក្នុងចិត្តរបស់ខ្ញុំ នឹងឃើញមនុស្សចេះ តែខ្លាច ហើយនិងដៃរបស់ខ្ញុំហ្នឹង គឺខ្ញុំលើកអត់រួច ។ ដល់អ៊ីចឹងទៅដល់ខ្ញុំពិបាកពេកខ្ញុំចេះដើរទៅដល់ថ្ងៃ ណាដែលខ្ញុំនឹកឃើញទៅកូនប្រពន្ធដែលខ្ញុំធ្វើបាបគាត់ខ្លាំងអ៊ីចឹងទៅខ្ញុំនឹកឃើញ ទៅអាណិតអាសូរគាត់ ដែលខ្ញុំស្វាង ។ រួចហើយបានមានប្អូនធម៌មួយនៅក្នុងស្រុកអង្គរបុរី គេប្រាប់ថា គាត់តែមានស្អីៗមក និយាយនិងខ្ញុំហ្នឹងមកនិយាយ ប្រាប់ខ្ញុំថា-- ខ្ញុំប្រាប់ថា ខ្ញុំកាលសម័យហ្នឹងខ្ញុំជាប់គុកនៅ-- សម័យរាជ អាពត គេបានវ៉ៃខ្ញុំបែកក្បាល ហើយនិងចង ធ្វើនេះធ្វើនោះ សព្វបែបសព្វយ៉ាងសម្បើមណាស់ ។ គេថា អ៎! គាត់សរសៃប្រសាទ បានគេបញ្ជូនខ្ញុំឲ្យទៅរកថ្នាំហូបក៏ហូបមិនត្រូវ ទើបមកត្រូវថ្នាំដែលគ្រូសារខ្ញុំ នឹងគាត់យកមកលក់ហ្នឹងទៅ នឹងហូបទៅវាត្រូវថ្នាំហ្នឹង ។ រហូតដល់សព្វថ្ងៃៗអ៊ីចឹងដែរ ខ្ញុំដាក់ថ្នាំមក សាគួរទុកហូបហ្នឹង បានថ្នាំហ្នឹង ។ ថ្ងៃណាធ្វើឲ្យខ្ញុំមានអារម្មណ៍ទៅល្អ ថ្ងៃណាមិនល្អទៅគឺអស់ល្អទេ មួម៉ៅច្រើន ។

**ស៖** ឥឡូវនេះ លោកបានពន្យល់ទៅតុលាការថា នៅស-២១ បន្ទាប់មកគេបញ្ជូនពីស-២១ ទៅ ព្រៃស ទៅស-២៤ ចាតើលោកដឹងកន្លែងដែលគេបញ្ជូនទៅព្រៃសនោះ តើហេតុអីបានជាលោកដឹង?

**ឆ៖** មូលហេតុដែលខ្ញុំបានដឹងថាកន្លែងហ្នឹងជាព្រៃសព្រោះអ្នកយាមគេហ្នឹងគេប្រាប់ខ្ញុំដែរ បាន ខ្ញុំជឿជាក់ថាកន្លែងហ្នឹងជាកន្លែងព្រៃស ។ គេថា គេបញ្ជូនអ្នែងមកហ្នឹងមកលត់ដំនៅព្រៃសនេះ បាន ខ្ញុំកំណត់ថាកន្លែងនោះជាកន្លែងព្រៃស ។

**ស៖** តើលោកបានដឹងហ្នឹងពេលទៅដល់ព្រៃសភ្លាមគេប្រាប់ឬយ៉ាងម៉េច?

**ឆ៖** នៅយូរដែរ ។

**ស៖** តើលោកអាចជម្រាបបន្ថែមទេ អំពីរបបអាហារនៅព្រៃស តើមានរបបអាហារគ្រប់គ្រាន់ទេ?

**ឆ៖** ចំពោះជីវភាពដែលរស់នៅព្រៃសនោះ គឺមិនគ្រប់គ្រាន់ទេ ។ ពេលធ្វើការហូបបាយហ្នឹងគេឱ្យយើងហូបមួយកូនចានចង្កឹះមានកំណត់ ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ លោក លី ហ៊ ហើយមេធាវីជាតិនឹងសួរលោកតទៅទៀត ។ តើលោកទាមទារសំណងអ្វីដើម្បីតុលាការ-- នៅពេលនេះឬក៏ទុកឱ្យមេធាវីជាអ្នកធ្វើការស្នើសុំជំនួសលោក?

**ឆ៖** ខ្ញុំគ្មានសុំសំណងអីក្រៅពីឱ្យមេធាវីគាត់សុំឱ្យទេ ។ ទុកឱ្យមេធាវី ។

**ស៖** សូមអរគុណលោកដែលបានឆ្លើយនូវសំណួររបស់ខ្ញុំ ហើយខ្ញុំជូនវេទិកានេះជូនទៅសហសេវិកមេធាវីរបស់ខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីជាតិក្រុមមួយ ។

**សួរដោយ កញ្ញា ទី ស្រ៊ីនណា៖**

ជាបឋមនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ។ នាងខ្ញុំសូមធ្វើការបញ្ជាក់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

**ស៖** ទីមួយនាងខ្ញុំគ្រាន់ចង់សួរថា តើនៅក្នុងអំឡុងបច្ចុប្បន្នលោកមានដែលធ្លាប់ទៅមន្ទីរស-២១ -- លោកមានដែលបានទៅមន្ទីរ ស-២១ នៅក្នុងពេលបច្ចុប្បន្នដែរ ឬទេ?

**ឆ៖** ខ្ញុំធ្លាប់បានទៅក្រោយដែលខ្ញុំចូលមក មានអង្គការយើងហៅមកធ្វើការហ្នឹងហើយៗខ្ញុំបានចូលទៅកន្លែងស-២១ ។

**ស៖** ពេលដែលលោកទៅដល់ទីនោះ តើលោកមានកត់សម្គាល់ឃើញថា តើចំណុចដូចជាអគារធំៗបីបួននៅទីនុ៎ង ឬក៏មានកំណត់សម្គាល់អីប្លែកដែលថា ជាតំបន់ដែលលោកធ្លាប់បានស្នាក់នៅកាលពីអំឡុងពេលដែលលោករស់នៅមន្ទីរស-២១? មានចំណុចកត់សម្គាល់ដែរឬទេ? លោកពូអាចជម្រាបជូនដល់អង្គសវនាការដើម្បីបញ្ជាក់ថាលោកពិតជាបានជាប់នៅមន្ទីរស-២១មែន?

[១៤:២៣:៥៦]

**ឆ៖** ខ្ញុំបានចូលទៅដើរពិនិត្យមើល គឺខ្ញុំបានប្រហាក់ប្រហែលខ្លះព្រោះថាកាលពីមុន ហើយនិង

មកដល់រហូតសព្វថ្ងៃនេះ គឺវាមានការភ័ន្តភាំងខ្លះក៏គ្រាន់តែខ្ញុំចាំបានខ្លះ ចាំបានកន្លែងខ្លះ ។

**ស៖** ចុះលោកមានចាំថា មានអាគារទទឹងថ្ងៃនៅម្តុំ នៅក្នុងមន្ទីរស-២១ ដែរ ឬមួយក៏អត់ទេ?

**ឆ៖** ខ្ញុំចាំមិនបានច្បាស់ទេ អគារទទឹងថ្ងៃហ្នឹង ។ ក៏ប៉ុន្តែ ខ្ញុំចាំបានតែអគារនៅចំហៀង ប្រសិនបើយើងចូលពីលិចទៅនៅពីត្បូងនឹងខ្ញុំចាំបានប្រហាក់ប្រហែលខ្លះ នៅមានចាំដើមដូងមួយដែលដើមដូងនុំងឥឡូវវាចាស់ច្រើនហើយអាកន្លែងដែលធ្វើនៅកន្លែងរោងបាយហ្នឹង កន្លែងខ្ញុំជាប់ហ្នឹង ។ ហើយខ្ញុំចាំប្រហាក់ប្រហែលបានខ្លះព្រោះមានការភ័ន្តភាំង ។

**ស៖** ខ្ញុំសូមបន្តទៅទៀត ខ្ញុំសូមឲ្យលោកបញ្ជាក់ទៅនឹងឯកសារមួយដែលមានលេខ 00279930 លោកប្រធានខ្ញុំស្នើសុំលោកប្រធានជួយបង្ហាញ-- ឲ្យខាងផ្នែកសោតទស្សន៍ដើម្បីគេជួយបង្ហាញទៅលើលិខិតនេះ នៅលើអេក្រង់ដើម្បីខ្ញុំសួរបញ្ជាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលមានលេខ ERN 00279930 ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បញ្ចាំងនូវឯកសារ ERN00279930 ជាភាសាខ្មែរ នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមឲ្យខាងសោតទស្សន៍ជួយខិតៗឯកសារហ្នឹងចុះទៅក្រោយដើម្បីឲ្យឃើញស្នាមមេដៃ ។ សូមអរគុណ ។

**ស៖** លោក លី ហ៊ សូមលោកជួយពិនិត្យមើលទៅលើស្នាមមេដៃដែលនៅលើអេក្រង់ហ្នឹង តើលោកពូអាចពិនិត្យ-- សូមពិនិត្យមើលកន្លែងហ្នឹងបន្តិចទៅ! តើលោកអាចមានចាំបានទេថា តើស្នាមមេដៃកន្លែងហ្នឹង លោកមានចាំបានទេ តើលោកផ្តិតនៅកន្លែងណា? លោកអាចរកមើលសិនទៅថាតើលោកផ្តិតមេដៃនេះលើខិលិតហ្នឹងគឺនៅកន្លែងណា? នៅមន្ទីរ? នៅតាខ្មៅ? ឬព្រៃស ឬក៏នៅ ឌីស៊ីខេម?

**ឆ៖** អក្សរនេះ ហើយស្លាកស្នាមមេដៃនេះគឺខ្ញុំចាំមិនបានទេ ។ ប៉ុន្តែ ពិតជាស្នាមមេដៃរបស់ខ្ញុំអក្សរនេះ ។ ប៉ុន្តែ ផ្តិតនៅកន្លែងណាៗគឺខ្ញុំមិនបានចាំច្បាស់ ។

**ស៖** ប្រសិនជាលោកមិនចាំទេ លោករកនឹកសាជាថ្មីនៅពេលក្រោយចាំឆ្លើយក៏បានដែរ ប្រសិនបើករណីដែលលោកមានឱកាសអាចឆ្លើយបំភ្លឺទៅលើករណីហ្នឹង ថាតើលោកបានផ្តិតនៅកន្លែងណា?

**កញ្ញា ទី ស្រ៊ីនណា៖**

លោកប្រធាននាងខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ប្រសិនជាលោកប្រធានៗនាងខ្ញុំគ្រាន់តែចង់ស្នើសុំទុករយៈពេលឲ្យគាត់ដើម្បីពិនិត្យទៅលើឯកសារមួយហ្នឹង ថាតើគាត់ធ្លាប់ផ្តិតមេដៃនៅកន្លែងណា? ពីព្រោះអីកូនក្តី-- គាត់អត់ដែលបានពិនិត្យទៅលើឯកសារហ្នឹងថា តើឯកសារហ្នឹងគាត់អត់ទាន់បានអាននៅឡើយទេ លោកប្រធាន ។ បើសិនជានេះ នាងខ្ញុំសូមស្នើសុំទុកឱកាសឲ្យគាត់ដើម្បីឲ្យគាត់មានរយៈពេលពិនិត្យទៅលើឯកសារហ្នឹង និងសូមឲ្យគាត់ពិនិត្យហើយនិងបំភ្លឺទៅលើចំណុចនេះ ថាតើគាត់ផ្តិតមេដៃនេះនៅកន្លែងណាឲ្យពិតប្រាកដ ។

[១៤:២៩:០៥]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបន្តទៀត ឬយ៉ាងម៉េច?

ក្រឡាបញ្ជីអាចប្រគល់ឯកសារជាលាយលក្ខណ៍អក្សរជូនទៅគាត់ ដើម្បីទាំងស្រុងនូវកំណត់ចម្លើយ ត្រង់ចម្លើយនេះ ដើម្បីឲ្យគាត់បានពិនិត្យមើល ហើយដល់ពេលណាគាត់ត្រូវបញ្ជាក់ពីបញ្ហាហ្នឹងឲ្យបានច្បាស់ ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាមានបញ្ហាអីទៅ?

**លោក រ៉ូប៊ឺត ពើទីត៖**

សហព្រះរាជអាជ្ញា សូមអរគុណលោកប្រធានខ្ញុំស្នើថា យើងសម្រាកដប់នាទីមុនម៉ោង ដើម្បីឲ្យគាត់អានសេចក្តីចម្លើយនេះ ។ ហើយដើម្បីឲ្យគាត់អាចនឹងៗឆ្លើយទាក់ទងទៅនឹង-- បានជាសំណើអ៊ីចឹង ដើម្បីឲ្យគាត់អាចនឹងបំភ្លឺបានអំពីចំណុចនេះ ហើយនិងមន្ទីរ៤៤ នោះផង ។

**ប្រធានអង្គជំនុំ៖**

អរគុណ ចំណាប់អារម្មណ៍របស់លោកសហព្រះរាជអាជ្ញា ។ អ៊ីចឹងយើងប្រកាសសម្រាកម្ភៃនាទី តែម្តងទៅរហូតដល់ម៉ោង បីខ្វះដប់នាទីសូមអញ្ជើញចូលវិញ ហើយនិងអំឡុងពេលនេះគឺខាងមេធាវីឲ្យគាត់ពិនិត្យឯកសារហ្នឹង ឲ្យបានច្បាស់លាស់ ហើយមកដល់គឺគាត់អាចឆ្លើយទៅនឹងសំណួរបាន ។

*[សវនាការសម្រាកពីម៉ោង ១៤:៣១នាទី ដល់ម៉ោង ១៤:៥២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោលតទៅទៀត ។ ហើយជាបន្តនេះសូមប្រគល់វេទិកាជូនទៅមេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ពេលវេលាដូចជានៅតិចដែរទេមេធាវី ។ សរុបនៅតែដប់មីនុតទេ សូមអញ្ជើញ ។

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានតែមួយសំណួរនេះដែលជាសំណួរចុងក្រោយហើយ លោកប្រធាន ។

**ស៖** សូមលោកជួយបញ្ជាក់មើល តើលិខិតដែលខ្ញុំបង្ហាញលោកមុនពេលសម្រាកអម្បាញ់មិញនេះ លិខិតហ្នឹងគឺលោកបានផ្តិតមេដៃហ្នឹងគឺនៅតាខ្មៅ ឬក៏នៅមន្ទីរស-២១? លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ក្រដាសដែលឲ្យខ្ញុំយកទៅពិនិត្យមើលអម្បាញ់មិញនេះ ខ្ញុំវាមិនបានច្បាស់មិនដឹងជានៅតាខ្មៅ ឬមួយជានៅក្នុងព្រៃស ។ ប៉ុន្តែ អក្សរនេះគឺពិតជានៅហ្នឹងតាខ្មៅ និងព្រៃសមែន។ ប៉ុន្តែ មិនកំណត់ណាមួយកន្លែងណា?

**ស៖** លោកចង់មានន័យថា លិខិតហ្នឹងគឺធ្វើនៅតាខ្មៅ ឬក៏នៅព្រៃស ក៏ប៉ុន្តែពុំមែននៅកន្លែងផ្សេងទេ គឺនៅតាខ្មៅ ឬក៏ព្រៃស តើមែនអត់?

**ឆ៖** ខ្ញុំពិតជាធ្វើនៅតាខ្មៅ ហើយនិងទួលស្លែង ។ អំមិញខ្ញុំច្រឡំអំមិញគឺនៅទួលស្លែងមិនមែននៅ ព្រៃសទេ នៅទួលស្លែងហើយនិងតាខ្មៅ ។ ប៉ុន្តែកំណត់ថា នៅតាខ្មៅ ឬក៏ទួលស្លែងក៏មិនដឹងដែរ ខ្ញុំចាំវា មិនបានច្បាស់ ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណ ។

**សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** លោកប្រធានប្រសិនបើខ្ញុំអាចសួរសំណួរមួយចំនួន លោក លី ហ៊ី ខ្ញុំដឹងថា វាពិតជាពិបាកណាស់ចំពោះលោក ហើយលោកបានទទួលរងបញ្ហាភ័យខ្លាចផ្នែកស្មារតី ប៉ុន្តែខ្ញុំសូមសួរសំណួរមួយចំនួន ។ នៅពេលដែលលោកចូលទៅដល់ ស-២១ តើគេបានថតរូបលោកដែរឬទេ?

**ឆ៖** ពេលដែលខ្ញុំចូលដល់ ស-២១ គឺខ្ញុំវាមិនបានចាំដែរមិនដឹងគេបានថត ឬមួយក៏មិនថត ។

[១៤:៥៥:២៦]

**ស៖** ថាតើគេមានដាក់លេខសម្គាល់ឲ្យលោកដែរឬទេ?

**ឆ៖** ខ្ញុំឆ្ងល់ សូមដាក់ចម្លើយមកម្តងទៀត?

**ស៖** ថាតើគេមានដាក់លេខសម្រាប់សម្គាល់លោកចំពោះឲ្យឈ្មោះលោកដែរឬទេ?

**ឆ៖** អត់ទេ ។

**ស៖** ថាតើអ្នកជាប់ឃុំទាំងអស់ ឬអ្នកទោសទាំងអស់ដែលនៅជាមួយលោកហ្នឹងតើគេស្លៀកពាក់យ៉ាងម៉េចដែរ?

**ឆ៖** គេអត់មានកំណត់ឲ្យយើងថា ស្លៀកពណ៌ស ឬពណ៌ខ្មៅអត់ទេ ស្រេចតែមានអ្នកណាមានអ្វីស្លៀកហ្នឹងទៅ។

**ស៖** លោកបានលើកឡើងថា អ្នកទោសនៅជាមួយលោកមានការឈឺហើយនិងអ្នកខ្លះមិនមានមិនអាចផ្លាស់ប្តូរទីកន្លែងបាននោះទេ ។ តើពួកគេនោះមានទទួលការព្យាបាលដែរឬទេ?

**ឆ៖** អត់មានទេ អត់មានការព្យាបាលពីអ្នកប្រធានមន្ទីរឃុំឃាំងហ្នឹងទេ អត់មានទេ ។

**ស៖** នៅពេលដែលគេនិយាយជាមួយលោក ថាតើអ្នកយាមទាំងអស់នោះ គេនិយាយជាមួយលោកតាមរបៀបណា ហើយគេបញ្ចេញអត្តចរិតយ៉ាងម៉េចនៅពេលគេនិយាយជាមួយលោក?

**ឆ៖** ពេលដែលអ្នកយាម គេនិយាយជាមួយខ្ញុំគេនិយាយដោយមានការភ័យខ្លាច និយាយដោយស្ងាត់ ។ គេប្រាប់ខ្ញុំថា ឯងចាំម៉ោងដប់មួយ, ដប់ពីរយប់ ដល់មនុស្សស្ងាត់សឹមអញបោះថ្នាំពេទ្យឲ្យឯង ហើយឯងកុំប្រាប់ថា អញនឹងឯងស្គាល់គ្នា ។ គ្នាមានការភ័យខ្លាចជាខ្លាំងចំពោះដែលឲ្យព័ត៌មានមកខ្ញុំ ។

**ស៖** លោកក៏បាននិយាយផងដែរថា ពេលខ្លះគេមិនចងមុខ ឬរុំមុខលោកនោះទេ ។ តើលោកអាចមើលឃើញបុគ្គលដែលសួរចម្លើយលោកដែរឬទេ?

**ឆ៖** ពេលដែលសួរចម្លើយមិនបានចងមុខទេ ។ ក៏ប៉ុន្តែ គ្រាន់តែខ្ញុំថា ខ្ញុំចាំបាននៅកន្លែងទួលស្លែង ហ្នឹង គាត់ហ្នឹងរាងខ្មៅស្រអែមខ្ពស់មិនខ្ពស់ ទាបមិនទាប ស្គមមិនស្គម ធាត់មិនធាត់ល្មម អាយុហ្នឹង ប្រហែលជាសាមសិបជាង សាមសិបឆ្នាំប៉ុណ្ណឹងឯង ។ ហ្នឹងអ្នកសួរចម្លើយខ្ញុំ។

**ស៖** ប្រសិនបើ លោកបង្ហាញរូបភាពអ្នកសួរចម្លើយតើលោកអាចស្គាល់ដែរឬទេ? ប្រសិនបើមានបង្ហាញរូបភាពឲ្យលោកមើលនោះ?

[១៤:៥៩:៣៤]

**ឆ៖** ខ្ញុំមិនបានចាំ ព្រោះវាយូរហើយ អត់បានចាំទេ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកច្រើន ហើយខ្ញុំអត់មានសំណួរទៀតទេ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហុង គឹមសួន ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមសួរតែមួយសំណួរទេ ។ សូមគោរពលោកប្រធាន និងអង្គជំនុំជម្រះជាទីគោរព ។

**ស៖** លោក លី ហ៊ អម្បាញ់មិញ ឮលោកជម្រាបអង្គសវនាការអំពីការទទួលរងរបួសបែកក្បាល ។ តើការរងរបួសបែកក្បាលនោះ កើតឡើងនៅមន្ទីរ ពេទ្យឆ្កួតតាខ្មៅ ឬមកដល់ទួលស្លែង?

**ឆ៖** រងរបួសក្បាលនោះ គឺនៅមន្ទីរ១៥ ។

**ស៖** នៅពេលដែលគេចាប់លោកនៅមន្ទីរ១៥ ដំបូងមុននឹងបញ្ជូនមកគុក ឬក៏ពេទ្យឆ្កួតមែនទេ?

**ឆ៖** រងរបួសក្បាលនោះនៅ មិនទាន់មកពេទ្យឆ្កួតនិងទួលស្លែងទេ ។ នៅមន្ទីរ១៥ នៅឡើយ ។

**ស៖** តើជានៅពេលណា?

**ឆ៖** ជាវាអត់កំណត់ ជាច្រើនថ្ងៃ ចូលខែដែរ ។

**ស៖** សំណួរខ្ញុំចង់សួរថា មកដល់ទួលស្លែង ជាហើយឬក៏នៅ?

**ឆ៖** មកដល់ទួលស្លែងជាហើយ ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំមានតែប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់-- សូមអញ្ជើញលោកសហព្រះរាជអាជ្ញា មានបញ្ហាអីទៅ?

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ។ ខ្ញុំសូមការអនុញ្ញាតចំពោះការឆ្លើយតបសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ ហើយខ្ញុំសូមផ្តល់ព័ត៌មានមួយចំនួន ហើយខ្ញុំសូមធ្វើការកុំឱ្យសួរ

សំណួរផ្សេងទៀតពីមេធាវីការពារក្តីទាក់ទងទៅលើចំណុចនេះ ទាក់ទងនឹងមន្ទីរ៤៤ និង៤៣ ដែលបានលើកឡើងព្រឹកមិញ។ មន្ទីរ៤៤ ត្រូវបានលើកឡើងដោយមានស្របទៅនឹងឯកសារលេខ ERN 0027 9925 នេះគឺជាលេខ ERN ជាភាសាខ្មែរ ។ យើងដឹងហើយថា នេះ ឯកសារនេះជារបាយការណ៍សកម្មភាពដែលនៅក្នុងនោះលើកឡើងថា នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវគេបញ្ជូនទៅមន្ទីរ៤៤ ។ ប្រសិនបើខ្ញុំជួយអង្គសវនាការបាននោះ គឺខ្ញុំសូមលើកយក ERN មួយចំនួន។ ជាដំបូងលេខ ERN ជាភាសាខ្មែរគឺមានលេខ 00145548 ដល់លេខ 00145556 ។ លេខERN នៅក្នុងឯកសារនេះគឺ 00146771 ហើយឯកសារភាសាបារាំង គឺលេខERN 00147713 ដល់ 00147715 ។ ឯកសារនេះ គឺឯកសារដែលបានប្រមូលដោយសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៦ ដែលវាជាផ្នែកមួយនៃសំណុំ រឿង ។ គឺចម្លើយរបស់បុគ្គលម្នាក់ដែលបានលើកឡើងថា គាត់ជាអ្នកយាមនៅតាខ្មៅ ដែលយើងហៅមន្ទីរតាខ្មៅពេទ្យឆ្កួតនោះថាជាមន្ទីរ៤៤ ។ ហើយខ្ញុំសូមបញ្ជាក់បន្ថែមទៀតគឺ ខ្ញុំសូមឲ្យអង្គសវនាការពិនិត្យមើលលេខ ERN00081277 ដល់លេខ 00081488 នេះជាឯកសារលេខERN ជាភាសាអង់គ្លេស គឺយើងដកស្រង់ចេញមកពីឯកសារកងពល៧០៣របស់ខ្មែរក្រហម។ ហើយបានលើកឡើងថា មន្ទីរ៤៤ គឺជា ផ្នែកមួយនៃកងពល៧០៣ ។ ហើយមន្ទីរ៤៤ នេះគឺពេទ្យតាខ្មៅ ។

[១៥:០៤:៥៦]

ហើយនៅក្នុងនោះក៏បានរៀបរាប់ផងដែរ អំពីមន្ទីរ៤៣ ហើយមានទីតាំង មន្ទីរ៤៣ មានទីតាំងនៅផ្នែកខាងលិចវត្តលង្កា ក្នុងទីក្រុងភ្នំពេញ ហើយបានលើកឡើងថាមន្ទីរនេះជាមន្ទីរអប់រំ ។ ហើយខ្ញុំសុំអរគុណមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ដែលបានផ្តល់លេខយោងដំបូងចំពោះឯកសារនេះ ហើយខ្ញុំសង្ឃឹមថា ព័ត៌មានទាំងអស់នេះនឹងមានគុណប្រយោជន៍សម្រាប់អង្គសវនាការទាំងមូល ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញាអន្តរជាតិដែលបានផ្តល់ព័ត៌មាននេះ ។

ជាកិច្ចបន្ត សូមប្រគល់វេទិកានេះជូនទៅមេធាវីការពារក្តី បើមានសំណួរអ្វីដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះសូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ លោកប្រធាន សូមគោរពលោកជំទាវចៅក្រម លោកចៅក្រម លោកចៅក្រមជាតិ

និងអន្តរជាតិទាំងអស់ ។ បើសិនជានេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានថា ខ្ញុំមិនចង់សួរទៅលើសាក្សីរូបនេះទេ ប៉ុន្តែ ខ្ញុំសុំអនុញ្ញាតពីលោកប្រធានសុំធ្វើការចាប់អារម្មណ៍ ឬក៏ជាការកត់សម្គាល់ខ្លះ ។ បើលោកប្រធានអនុញ្ញាត ខ្ញុំនឹងធ្វើការកត់សម្គាល់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមធ្វើការកត់សម្គាល់ដូចតទៅ៖ ឃើញថា មកដល់ស-២១ លោក លី ហ៊ា គាត់ថាគាត់អត់បានថតរូបទេ ហើយក៏អត់មានដាក់លេខសម្គាល់ដែរ ប៉ុន្តែ សាក្សីទាំងពីដើមរហូតមកដល់ពេលនេះ លើកលែងតែលោក លី ហ៊ា មួយ ។ ខ្ញុំគត់សម្គាល់ឃើញថា សាក្សីទាំងអស់មកដល់សុទ្ធតែបានថតរូប ហើយដាក់លេខ នេះជាការកត់សម្គាល់ទីមួយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមអភ័យទោសចំពោះការរំខានកាត់ដល់មេធាវីការពារ ប៉ុន្តែនាងខ្ញុំគ្រាន់តែសូមបញ្ជាក់បន្តិចថា កូនក្តីនាងខ្ញុំបានឆ្លើយថា គាត់មិនចាំ គាត់ពុំមែនឆ្លើយថា គាត់មិនបានថតរូបនៅមន្ទីរស-២១ និងមិនមានលេខនៅក្នុងមន្ទីរស-២១ ទេ គឺគាត់បញ្ជាក់ថាគាត់មិនចាំ ។

សូមអរគុណលោកប្រធាន ។

[១៥:០៧:៤៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៀត ។

មានបញ្ហាអីទេ លោកសហព្រះរាជអាជ្ញា?

**លោក រ៉ូប៊ឺត ពេទីត៖**

សូមអភ័យទោសដល់មេធាវីការពារ សុំការណែនាំពីអង្គជំនុំជម្រះ ប្រសិនបើមានការចាំបាច់នៅក្នុងដំណាក់កាលដែលផ្តល់សក្ខីកម្មដោយដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សីដែលគាត់នៅទីនេះ គឺថានៅពេលដែលយើងរង់ចាំសាក្សីផ្សេងៗទៀត តើសមស្របទេដើម្បីឲ្យ-- សូមឲ្យភាគីធ្វើការសន្និដ្ឋានទៅលើប្រធានបទផ្សេងៗ ។ ដូច្នេះហើយ បើសិនជាមេធាវីការពារ ឬក៏ភាគីផ្សេងទៀត គាត់ចង់ផ្តល់សេចក្តីបញ្ជាក់ ឬក៏មានសេចក្តីបំភ្លឺអំពីភស្តុតាងណាមួយនោះ ខ្ញុំសូមឲ្យធ្វើឲ្យការបញ្ជាក់ហ្នឹង នៅពេលដែល

យើងបញ្ចប់សវនាការលើភស្តុតាងនោះ គឺថាអាចនឹងជាពេលវេលាដែលប្រើប្រាស់ត្រឹមត្រូវ ។ អ៊ីចឹងហើយគឺថាបើសិនជាមេធាវីមិនមាន មេធាវីការពារមិនមានសំណួរទេ មិនគប្បីធ្វើសេចក្តីសន្និដ្ឋាននៅពេលនេះទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់នេះ ឥឡូវនេះយើងដូរនីតិវិធី ទៅរកនីតិវិធីដើមវិញ ទីមួយគឺជនជាប់ចោទ តើមានការកត់សម្គាល់អ្វីខ្លះទៅចំពោះចម្លើយដែលផ្តល់ឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ នេះ?

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ដំបូង ខ្ញុំសុំអនុញ្ញាតលោកប្រធានឲ្យព្រះរាជអាជ្ញាផ្តល់ឯកសារដែលគាត់សូត្រអំមិញអំពីមន្ទីរ៤៣ និងមន្ទីរ៤៤ ឲ្យខ្ញុំបានស្គាល់ផង ។ ខ្ញុំអត់ដែលឃើញនៅឡើយទេ ។ តទៅទៀត ខ្ញុំសូមអត្ថាធិប្បាយអំពីឯកសារដែលគេយកចេញពីមន្ទីរស-២១ តើឯកសារហ្នឹងវាស្អីខ្លះ? ឯកសារដែលយកចេញពីមន្ទីរស-២១ ឯកសារដំបូងមានលេខថា 00279915 ឯកសារនេះជាកំណត់សម្គាល់របស់ពួក អ៊ឹង ប៊ុច ដែលជាប្រធានគណៈកម្មាធិការសារមន្ទីរទួលស្លែងដំបូង ។ គេសរសេរថា អ៊ា ហ៊ ជាឡាតាំងហើយ ជាខ្មែរទៀត លេខ E-40 ស្លដែកនៅមន្ទីរ១៣ កោះខែល ។ នេះជាចំណាររបស់ អ៊ឹង ប៊ុច ។

[១៥:១១:០៨]

ឯកសារដែលមាននៅធ្លាក់មកដល់ស-២១ ពីមន្ទីរ១៥ មកមានដូចតទៅ៖ ដំបូងមិត្ត អ៊ា ហ៊ គាត់ចូលមន្ទីរ១៥ទេ រួចគាត់រត់ចេញពីមន្ទីរ១៥ ទៅមន្ទីរស្លដែករបស់គាត់វិញ ។ ដល់ទៅដល់មន្ទីរស្លដែកមិត្តស្នួង គាត់ចាប់ ។ មិត្តស្នួង ប្រធានមន្ទីរស្លដែក ។ មិត្តស្នួង គាត់ចាប់ គាត់សរសេរសំបុត្រមួយចុះថ្ងៃ៧ វិច្ឆិកា ១៩៧៥ បញ្ជូនមិត្ត លី ហ៊ (សុំទោស) មិត្ត អ៊ា ហ៊ មកមន្ទីរ១៥វិញ ។ ខ្លឹមសារលោកប្រធានបានឲ្យក្រឡាបញ្ជីអានរួចហើយ ។ ចំណែក ចំណារនៅកៀនជាយរឹមទំព័រនេះ ចារថា “ជននេះធ្វើបដិវត្តន៍ជាមួយនឹងអា សារ៉េត នាំគេរត់ចេញពីសាលាអប់រំកាលពីក្នុងខែ៩ ឆ្នាំ១៩៧៥ ។ ស៊ីញ៉េគឺស៊ីញ៉េមិត្តតេង ។ មិត្តតេង នេះឈ្មោះដើម ម៉ឹង សំណាង ប៉ូលិសចាស់មុនរដ្ឋប្រហារ១៨ មេសា (សុំទោស) ១៨ មីនា ១៩៧០ ។ នេះឯកសារទីមួយមានលេខ ERN0279926 ។ នេះជារឿងរ៉ាវកើតឡើង-- ឯកសារនេះដំបូងវានៅឯមន្ទីរ១៥ៗណោះទេ ។

ដល់ថ្ងៃ១០ វិច្ឆិកា ឆ្នាំ១៩៧៥ មិត្តតេង បញ្ជាឲ្យមិត្តជាម សួរចម្លើយ ។ សួរចម្លើយនេះ គឺសួរនៅមន្ទីរ១៥ ឆ្នាំ១៩៧៥ ខែវិច្ឆិកា ថ្ងៃទី១០ ម៉ោង៧ យប់ហ្នឹង ។ ជារបៀបសួរចម្លើយរបស់មន្ទីរ១៥ គេសរសេរអ៊ីចឹង ។ នេះឯកសាររបស់មន្ទីរ១៥ ។

តទៅទៀត សួរចម្លើយលើកទីពីរ ក៏មិត្តជាម សួរដដែលដែរ ។ ឆ្នាំ១៩៧៥ ខែវិច្ឆិកា ថ្ងៃទី២២ ម៉ោងប្រាំបួន-- ម៉ោងដប់ប្រាំបួន ។ នេះជាឯកសារសួរចម្លើយលើកទីពីរ ។ នៅចុងបញ្ចប់មានស្នាមមេដៃមួយស្នាមផ្ដិតមេដៃ អ៊ា ហ៊ី ។ ដូច្នេះ ប្រាដកតែម្ដងស្នាមផ្ដិតមេដៃនេះរបស់មិត្ត អ៊ា ហ៊ី ។ ដូច្នេះ ការសួរចម្លើយទាំងពីរនេះ សួរនៅមន្ទីរ១៥ ។ តើស-២១ សួរនៅពេលណា? អ្នកណាសួរ?

ខ្ញុំសូមបំភ្លឺជូនអង្គសវនាការដូចតទៅ៖ អ្នកសួរចម្លើយនៅស-២១ មានពីរនាក់ មិនដឹងអ្នកណាសួរមុន អ្នកណាសួរក្រោយទេ ។ ក៏ប៉ុន្តែ អក្សរដំបូង គឺនៅក្នុង ERN លេខ 00279916 ជាអក្សរសួរចម្លើយរបស់បង ម៉ម ណៃ ។ ខ្ញុំស្គាល់អក្សរនេះច្បាស់ ។ គាត់មកបញ្ចប់ឃ្លាគាត់នៅត្រង់ខែ១១ ឆ្នាំ៧៥ ពេលធ្វើការងារវាល្ងចរត់ពីម១៥ សន្និដ្ឋានទុកចោលគាត់លែងសរសេរ ដល់គាត់លែងសរសេរ គាត់មកចារពីខាងលើស្នើដាក់គុក ។ នេះអក្សរបង ម៉ម ណៃ ទាំងអស់ ឯចំណែក អក្សរដែលថែមក្នុងសេចក្ដីសន្និដ្ឋាននេះ ខ្ញុំមិនទាន់ប៉ានសន្និដ្ឋានថា អក្សរអ្នកនៅឡើយទេ ។ ក៏ប៉ុន្តែ អក្សរដែលថា ដោះលែង ថ្ងៃ៨ ខែ៣\៧៦ ជាអក្សរមិត្តហ៊ៗ តើដោះលែងពិត ដោះលែងក្លែងក្លាយ? ខ្ញុំនឹងជម្រាបជូនអង្គសវនាការតទៅទៀត ។

[១៥:១៥:៤២]

ឯចំណែក អក្សរដែលសួរចម្លើយមិត្ត អ៊ា ហ៊ី ពីលេខ 00279918 ទៅដល់ ERN00279926 (សុំទោស) ទៅដល់ ERN00279925 ជាអក្សរអ្នកសួរចម្លើយក្មេងម្នាក់ទៀតឈ្មោះមិត្ត ហាក់ៗ ។ មិត្តហាក់ ហ្នឹងក្មេងទេ អាយុប្រហែល២៣ឆ្នាំ ឯចំណែកបង ម៉ម ណៃ ជំនាន់នោះអាយុ៤៤ ហើយ បងខ្ញុំ១០ឆ្នាំ ។ បង ម៉ម ណៃ អង្គសវនាការស្គាល់ហើយ ខ្ពស់ កើតស្រែង ឯចំណែកមិត្តហាក់ គេយុវជនគេក្មេងសស្អាត ។ នេះខ្ញុំសូមបញ្ជាក់ជូនឯកសារដែរយកចេញពីមន្ទីរស-២១ ប៉ុណ្ណឹង ។ ក្រៅពីនោះ ជាឯកសារពាក្យបណ្ដឹងរបស់លោក លី ហ៊ី ។ ក្រោយពីបញ្ជាក់ដំណើរការនៃការសួរចម្លើយហូរហែឯកសារប៉ុន្មាន ដែលយកចេញពីមន្ទីរស-២១ រួចហើយ ខ្ញុំសូមបញ្ជាក់ជូនលោកប្រធានថា ខ្ញុំជឿជឿទាំងស្រុង ហើយសូមសម្ដែងមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ និងសូមរំលែកទុក្ខដោយស្មោះអស់ពីដួងចិត្តអំពីទុក្ខវេទនាដែលលោក លី ហ៊ី បានទទួលរងនូវជំនាន់នោះ ត្រូវគេវ៉ៃក្បាល ហើយមានស្លាក

ស្នាមរហូតដល់ឥឡូវ ។ នេះខ្ញុំទទួល ទទួលស្គាល់ ហើយជឿៗពិត ។

ទន្ទឹមនេះដែរ ខ្ញុំសុំនិយាយតទៅទៀតតាមឯកសារទាំងអស់ ខ្ញុំបញ្ជាក់ថាមិត្ត អ៊ា ហ៊ី ស្លាប់បាត់ទៅហើយ ឯកសារទាំងអស់នេះជាភស្តុតាង ហើយកំណត់នៅក្នុងបញ្ជីគោលរបស់មន្ទីរស-២១ មន្ទីរកម្ទេចនោះ ដែលយើងហៅថាមន្ទីរកម្ទេចនេះ ដែលការិយាល័យសហព្រះរាជអាជ្ញារៀបចំជូនហ្នឹងមាន ៣៧០ទំព័រនោះ ។ ឈ្មោះមិត្ត អ៊ា ហ៊ី នៅត្រង់ទំព័រ៥៩ លើ៣៧០ ឈ្មោះគាត់នៅត្រង់លេខរៀង ១៩៧២ ។ ដូច្នេះ មិត្ត អ៊ា ហ៊ី ស្លាប់ទៅហើយ ។ ឯកសារនេះ ដែលពេលសរសេរដោះលែងនេះ វាស្ថិតនៅក្នុងក្របខ័ណ្ឌមួយដែលណាតប្រើពាក្យដោះលែងក្លែងក្លាយធ្វើឧបាយកល ។ ឧបាយកលនេះខ្ញុំបានរាយការណ៍ជូនអង្គសវនាការហើយ ណាត ប្រើពាក្យដោះលែងក្លែងក្លាយ ជាឧបាយកលនេះលើមនុស្សចំនួន៦១នាក់ ៦២ទាំងមិត្ត អ៊ា ហ៊ី នេះផង ។ ៦១នាក់ គឺនៅក្នុងបញ្ជីលេខD-57 index 003 នេះ ៤៩នាក់ ។ នៅក្នុងបញ្ជីរបស់បង ម៉ម ណៃ កំណត់ហេតុរបស់ ម៉ម ណៃ មាន១៤នាក់ ។ ខ្ញុំអាចសូត្រទំព័របាន នៅក្នុងបញ្ជីរបស់បង ម៉ម ណៃ គឺលេខ 00077986 មានម្នាក់ ដល់លេខ 00077988 អ៊ំ 978 អំមិញ976 ។ ខ្ញុំសុំទោស អំមិញ976 ទេ ឥឡូវមកចូលដល់978 មានប្រាំនាក់ 979 មានប្រាំនាក់ទៀត ។ ទាំងអស់ដប់មួយនាក់នៅនុ៎ង ។ បូកនឹងឯកសារលេខ E5/2.8 ផងដប់មួយនាក់ ឥឡូវដប់ពីរ នាក់ទាំងមិត្ត អ៊ា ហ៊ី ។ ស្ថិតនៅក្នុងចំណោមដែលដោះលែងក្លែងក្លាយ ។

[១៥:២០:០៦]

ការដោះលែងនេះ ក្លែងក្លាយនេះ ធ្វើឡើងនៅថ្ងៃ០៨ ខែ០៣ ឆ្នាំ១៩៧៦ ។ ដូច្នេះ តំណាលគ្នាហ្នឹងឯកសារដែល ណាត បញ្ជាឲ្យ មិត្តហ៊ី យកមិត្តស្អី សុំទោស ខ្ញុំសូត្រលេខនេះទៅចុះ គឺ E5/2.8 យកទៅកម្ទេចថ្ងៃជាមួយគ្នា ។ ដូច្នេះ មិត្ត អ៊ា ហ៊ី ស្លាប់បាត់ហើយ ។

ហើយទីពីរទៀត ដើម្បីបញ្ជាក់ថា កាលដែលសន្និដ្ឋានយ៉ាងនេះ ខ្ញុំសូមលើកការសង្កេតជូន ។ សង្កេតជូនទីមួយ អក្សរ ។ ខ្ញុំជឿថា អក្សរនូវពាក្យបណ្ដឹងនេះទាំងប៉ុន្មាន ពាក្យបណ្ដឹងរបស់លោក លី ហ៊ី ទាំងប៉ុន្មាន គឺលោក លី ហ៊ី សរសេរទេ ។ តាំងពី 00279954 រហូតដល់លេខ 00-- សុំទោស រហូតដល់លេខ 00279959 នេះមួយឈុត ។ ហើយមួយឈុតទៀត 00280015 ដល់ 00280017 នេះមួយឈុត ពីរឈុតនេះ ខ្ញុំជឿជាក់ថា ជាអក្សរដៃរបស់លោក លី ហ៊ីៗ ។ បើប្រៀបធៀបទៅនឹងអក្សរដែលសរសេរនៅលេខ 00279927 ដែលខ្ញុំសន្និដ្ឋានថា លទ្ធភាព ៥០ភាគរយជាអក្សររបស់មិត្ត អ៊ា ហ៊ី ឃើញអក្សរទាំងពីរនេះ ខុសគ្នា ។ ដូច្នេះ ខ្ញុំលើកហេតុផលនេះ ដើម្បីចាប់ជូនជាការចាប់

អារម្មណ៍ថា មិត្ត អ៊ា ហ៊ា ផ្សេង លោក លី ហ៊ា ផ្សេង នេះអក្សរ ។

ទីពីរ ខ្ញុំសូមបញ្ជាក់ជូនអង្គសវនាការអំពីការសង្កេតរបស់ខ្ញុំទៅលើឆ្នាំកំណើត ។ វិភាគទៅលើចម្លើយដែលមិត្ត ចៀម គាត់សួរចម្លើយខ្មោចមិត្ត អ៊ា ហ៊ា ។ គាត់សួរនៅថ្ងៃ១០ វិច្ឆិកា ១៩៧៥ ពេលមិត្ត អ៊ា ហ៊ា ឆ្លើយប្រាប់មិត្ត ចៀម ថា គាត់អាយុ២១ ឆ្នាំ បើយកបញ្ហានេះមកគិត ១៩៧៥ ដក២១ឆ្នាំ បានន័យថា លោក មិត្តៗ អ៊ា ហ៊ា កើតនៅឆ្នាំ១៩៥១ ។ ឯចំណែក លោក អ៊ា ហ៊ា វិញ អង្គភាពជនរងគ្រោះបោះត្រាទទួលពាក្យបណ្ដឹងរបស់លោក នៅថ្ងៃ១ ខែកញ្ញា ឆ្នាំ២០០៨ ពេលនោះ លោកជម្រាបអង្គភាពជនរងគ្រោះថា លោកមានអាយុ៥៧ឆ្នាំហើយ ។ ដូច្នេះ គិតតាមតួរលេខ គឺលោកត្រូវកើតឆ្នាំ ១៩៥១ ដូច្នេះ ម្នាក់កើតនៅឆ្នាំ១៩៥១ ហើយម្នាក់កើតនៅឆ្នាំ១៩៥៤ វាជាបញ្ហាខុសគ្នាខាងអាយុ ខាងឆ្នាំកំណើត ។ នេះខ្ញុំសូមជូនជាការសង្កេតរបស់ខ្ញុំផ្ទាល់ជូនអង្គសវនាការ ។

ហើយម្យ៉ាងទៀត ឯកសារស-២១ ទាំងប៉ុន្មាន លោក លី ហ៊ា អត់ឆ្លើយជាមួយលោកចៅក្រមជូនឲ្យស្មោះត្រង់ទេ ។ ម៉េចជាបានជាអាងឯកសារនេះទៅក្នុងពាក្យបណ្ដឹងរបស់លោក? តើរឿងអីបានជាលោកឆ្លើយធ្វើរដិបរដុបអ៊ីចឹង? ខ្ញុំអត់យល់ ។ ខ្ញុំសង្កេតឃើញអ៊ីចឹង តើឯកសារហ្នឹងពីណា? ក៏លោក លី ហ៊ា អត់ដឹងឆ្លើយជម្រាបអង្គសវនាការឲ្យច្បាស់ ។ នេះជាការកត់សម្គាល់មួយទៀតរបស់ខ្ញុំ ។

[១៥:២៤:៤៣]

ហើយកញ្ញា ស្រ៊ីនណា សួរអំមិញហើយ ។ ស្នាមមេដៃដែលផ្តិតនៅទំព័រ ERN 00279930 វាមានលក្ខណៈច្បាស់ អំណោយដល់ការពិនិត្យរបស់យើងតទៅទៀត ។ នេះខ្ញុំសូមបញ្ជាក់ជូនលោកប្រធាន ហើយនិងអង្គសវនាការប៉ុណ្ណេះ ។

លោកប្រធានជាទីគោរព! សរុបមកវិញ្ញាណក្ខន្ធមិត្ត អ៊ា ហ៊ា ស្លាប់ទៅ ខ្ញុំអត់បំពានវិញ្ញាណក្ខន្ធគេទេ គេស្លាប់ទៅហើយ ខ្ញុំទទួល ។ ឯចំណែក ទុក្ខវេទនារបស់លោក លី ហ៊ា ក៏ខ្ញុំអត់បដិសេធដែរ ខ្ញុំទទួលសូមរំលែកទុក្ខ ។ សូមចប់ ។

*(ចៅក្រមពិភាក្សា)*

**ប្រធានអង្គជំនុំ៖**

អំម្បាញ់មិញនេះ មេធាវីការពារក្ដីបានស្នើសុំធ្វើការកត់សម្គាល់នូវចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី លី ហ៊ា ដោយមិនធ្វើការតាំងសំណួរជាក់លាក់ទេ ហើយការដែលធ្វើដូច្នេះនោះ គឺមានការជំទាស់ពីខាងសហព្រះរាជអាជ្ញាអំពីនីតិវិធីនៃការកត់សម្គាល់ដូច្នេះ ។ លោកសហព្រះរាជអាជ្ញា បានឲ្យ

លើកឡើងថា ការធ្វើដូច្នេះ គួរតែធ្វើនូវដំណាក់កាលចុងក្រោយនៃការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការសួរដេញដោល ។ អង្គជំនុំជម្រះពិភាក្សាគ្នាទៅយល់ឃើញថា ការលើកឡើងរបស់សហព្រះរាជអាជ្ញានេះមានការត្រឹមត្រូវសមស្រប ។ ដូច្នេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីការពារក្ដីធ្វើការកត់សម្គាល់អំពីចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទៀតទេ ។ ប្រសិនបើមានសំណួរអាចសួរបាន បើគ្មានសំណួរទេ អង្គជំនុំជម្រះនឹងបន្តនីតិវិធីបន្តទៅទៀត ។

**លោក ការ សាវុត្ថ៖**

សូមគោរពតុលាការ! ខ្ញុំអម្បាញ់មិញនេះ ខ្ញុំគ្រាន់តែសូមស្នើសុំទៅតុលាការថា ខ្ញុំមិនបាច់សួរហើយខ្ញុំសូមធ្វើការកត់សម្គាល់ ។ តើលោកប្រធានអនុញ្ញាត ឬមិនអនុញ្ញាត? បើលោកប្រធានមិនអនុញ្ញាតទេ ខ្ញុំនឹងសួរភ្លាម តាមម៉ោងដែលលោកបានកំណត់ឲ្យខ្ញុំ ហើយបើសិនជាខ្ញុំមិននិយាយក៏នូវមេធាវីអន្តរជាតិជាសហភាតារបស់ខ្ញុំ នៅទីនេះ គេត្រូវសួរបន្តដែរ ។ ហើយខ្ញុំអត់បំផ្លាញម៉ោងរបស់តុលាការដែលថាកំពុងតែមមាញឹកបំផ្លាញម៉ោងឲ្យទៅជាវែងអន្លាយ គឺខ្ញុំអត់គោលបំណងហ្នឹងទេ ហើយបើសិនជាថា ឥឡូវឲ្យខ្ញុំសួរទៅវិញ ក៏ខ្ញុំសួរបាន ។

[១៥:៣៣:៤៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវ សំណើរបស់លោកសុំធ្វើការកត់សម្គាល់ដែលមានការជំទាស់ អង្គជំនុំជម្រះពិចារណាទៅឃើញថា ការជំទាស់នេះ ជាការត្រឹមត្រូវ ។ អ៊ីចឹង លោកមិនអាចធ្វើការកត់សម្គាល់បានទេ លើចម្លើយរបស់ លី ហ៊ា ។ ចំពោះថា តើលោកមានសំណួរសួរ ឬអត់នោះ ជាសិទ្ធិរបស់លោកដែលត្រូវចំណាយនៅក្នុងម៉ោងដែលលោកត្រូវធ្វើ ។ ហើយម៉ោងនេះ អង្គជំនុំជម្រះនឹងគិតចាប់ពីម៉ោងនេះទៅ ដែលពេលវេលាទុកសម្រាប់លោក ។ ពីព្រោះអំមិញចាត់ទុកថា វាមានការជំទាស់លោកមិនបានសួរទេ ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមគោរពតុលាការ! ខ្ញុំបាទសុំសួរទៅលោក លី ហ៊ា ។ នៅថ្ងៃទី១០ ខែ១១ ឆ្នាំ១៩៧៥ តើលោកនៅទីណា?

[១៥:៣៥:១៧]

**ឆ៖** ឆ្នាំ១៩៧៥ យើងខ្ញុំនៅតំបន់២៥ នៅវត្តដើមពោធិ៍ ។

**ស៖** ថ្ងៃទី១០ ខែ១១ ឆ្នាំ១៩៧៥ លោកថា លោកនៅដើមពោធិ៍ ហើយនៅក្នុងឯកសារនេះ គឺនៅថ្ងៃទី១០ ខែ១១ ឆ្នាំ១៩៧៥ លោកបានបញ្ជាក់ ដែលឯកសារលោកបានបញ្ជាក់នៅក្នុងនេះ ឯកសារ ERN 00279929 ថាថ្ងៃទី១០ ខែវិច្ឆិកា ១៩៧៥ ពេលដែលអង្គការចាត់តាំងខ្ញុំឲ្យធាក់រហាត់ទឹក ។ អ៊ីចឹង ថ្ងៃហ្នឹងអង្គការបានចាត់តាំងលោកឲ្យធាក់រហាត់ទឹក ចុះម៉េចលោកថា លោកនៅដើមពោធិ៍វិញ សូមលោកបញ្ជាក់មើល?

**ឆ៖** កន្លែងហ្នឹង ខ្ញុំក៏មិនចាំមិនបានច្បាស់ដែរ ពីព្រោះវានៅក្នុងឆ្នាំ១៩៧៥ហ្នឹង វាមាននៅដើមពោធិហ្នឹងផង ហើយនិងគេឲ្យទៅធាក់រហាត់ទឹកហ្នឹងផង ។ ហើយខ្ញុំចាំថ្ងៃខែនោះ វាចាំមិនបាន ។

**ស៖** បានជាខ្ញុំសួរលោកថា ថ្ងៃ១០ ខែ១១ ឆ្នាំ១៩៧៥ហ្នឹង តើលោកនៅឯណា? បានជាខ្ញុំសួរដូច្នេះ ពីព្រោះនៅថ្ងៃ១០ ខែ១១ ឆ្នាំ១៩៧៥ ធំមាន លី ហ៊ី ឬក៏មានម្នាក់ទៀត អ៊ា ហ៊ី គេចាប់ចូលស-២១ នៅថ្ងៃនោះដែរ ។ អ៊ីចឹងសូមលោកបញ្ជាក់មើល តើលោកមានស្គាល់ឈ្មោះ អ៊ា ហ៊ី ម្នាក់ទៀតទេ ដែលគេចាប់ចូល ស-២១ នៅថ្ងៃនោះដែរអ៎ែ?

**ឆ៖** ខ្ញុំចាំអត់ច្បាស់ ចាំអត់ច្បាស់ ដែលពីឆ្នាំ១៩៧៥ព្រោះខ្ញុំមិនដឹង ចាំពីឆ្នាំ១៩៧៥ ដែលខ្ញុំនៅគឺនៅដើមពោធិ បែកពីភ្នំពេញហើយទៅនេះ អាហ្នឹងខ្ញុំចាំ ។ ជម្លៀសអ្នកភ្នំពេញទៅ ទៅនៅវត្តដើមពោធិ អង្គការគេឲ្យនៅយាមអ្នកជម្លៀសហ្នឹង អ្នកជម្លៀសទៅហ្នឹង ។ ត្រង់ឆ្នាំ១៩៧៥ ខ្ញុំនៅកន្លែងណាៗ ខ្ញុំអត់ចាំទេ ។

**ស៖** សូមអរគុណ សូមលោកបញ្ជាក់ម្តងទៀត ។ ខ្ញុំសួរឲ្យលោកបញ្ជាក់ទេ នៅស-២១ លោកបានបញ្ជាក់ជូនតុលាការព្រឹកមិញថា នៅស-២១ គេឲ្យបាយលោកហូប និងសម្ល ជូនសម្លដើមចេក ជួនសម្លត្រកួន ។ អ៊ីចឹងលោកបញ្ជាក់ម្តងទៀត គេឲ្យបាយលោកមែន ឬក៏ឲ្យបបរ?

**ឆ៖** គេឲ្យបាយខ្ញុំហូបមែន ។

**ស៖** សូមអរគុណ ។ លោកបញ្ជាក់ជូនតុលាការព្រឹកមិញ ហើយថា ខ្នោះដែលដាក់ជើងលោកហ្នឹង លោកថាពីដប់ ទៅដប់ប្រាំអ្នក ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** បានជាខ្ញុំសួរលោក ពីព្រោះអ្នកមុនៗឆ្លើយថា ខ្នោះហ្នឹងដាក់អស់ត្រឹមដប់នាក់ផុតហើយ មិនអាចដាក់លើសពីដប់នាក់ បានខ្ញុំសួរបញ្ជាក់ហ្នឹង ។ សូមអរគុណតុលាការ សូមអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ សូមអញ្ជើញ ។

[១៥:៣៩:៤២]

**សួរដោយលោកស្រី ម៉ារីប៉ូល ការីហ្សូរ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរ ខ្ញុំនឹងសួរសំណួរ ហើយខ្ញុំនឹងធ្វើកំណត់សម្គាល់ ។ នេះគឺមិនមែនជាការបញ្ជាក់ពីសារភាពនោះទេ គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩នោះ គឺឯកសារទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមានជាភាសាអង់គ្លេស ជាភាសាបារាំងមកដល់ដៃយើង ប៉ុន្តែតាមពិតមកដល់ពេលនេះ យើងមិនមានឯកសារនោះទេ ។ ខ្ញុំសូមឲ្យគោរពទៅតាមសំណើនេះ ។ អ៊ីចឹងគឺថាយើងមានការលំបាកក្នុងករណីនេះ ។ ខ្ញុំឥឡូវនេះ ខ្ញុំនឹងសួរសំណួរទៅសួរទៅលោក លី ហ៊ ។

**ស៖** សូមជម្រាបសួរលោក លី ហ៊ តើលោកនៅចាំទេ នៅក្នុងកាលៈទេសៈដែលថា យើងសម្រេចដើម្បីនឹងធ្វើការងារ ដើម្បីនឹងការជំនុំជម្រះលោក កាំង ហ្គេកអ៊ាវ នោះ លោកដឹងទេ?

**ឆ៖** ខ្ញុំចង់ឲ្យបញ្ជាក់ម្តងទៀត តើចង់សួរពីរឿងអ្វី?

**ស៖** គឺសុំ យើងអាច--

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ្នកបកប្រែបានប្រាប់ថា លោកស្រីមេធាវីមិនបាននិយាយជិតម៉ៃក្រូហ្វូន ដូច្នេះ គេស្តាប់មិនឮមិនអាចបកបាន ។

**សួរដោយលោកស្រី ម៉ារីប៉ូល ការីហ្សូរ៖**

សូមអរគុណលោកស្រី ខ្ញុំនឹងសួរឡើងវិញ ។

**ស៖** ហើយខ្ញុំសួរទៅលោក លី ហ៊ ថា ថាតើលោកនៅចាំទេ នៅកាលៈទេសៈណា ដែលលោកសម្រេចចិត្តចូលរួមនៅក្នុងការជំនុំជម្រះលោក កាំង ហ្គេកអ៊ាវ ។ នេះឯងជាសំណួរមួយសួរ ថាតើគាត់ដឹងដោយរបៀបណាអំពីការជំនុំជម្រះនេះ? ថាតើគាត់សម្រេចចិត្តដូចម្តេចថា នឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ?

**ឆ៖** ខ្ញុំបាទតាំងចិត្តថា ព្រោះខ្ញុំបានរងគ្រោះនៅសម័យ៣ឆ្នាំជាងហ្នឹង នៅកន្លែងហ្នឹងពិតមែនបានមកកាត់ទោសលោក ឌុច ខ្ញុំបានចូលរួមហ្នឹង ។

[១៥:៤៣:១៦]

**ស៖** ព្រឹកនេះ លោកបានបញ្ជាក់ថា លោកបានជួបតំណាងរបស់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃមួយនោះ ។ ហើយខ្ញុំយោងទៅរកលេខនោះ E2/61/1 KH00279934 រហូតទៅដល់95 នៅខាងចុង ។ ហើយអ៊ីចឹង គឺថាឯកសារហ្នឹងរបស់ ហើយអង្គការ *ឌីស៊ីខេម* បានបញ្ជូនឯកសារហ្នឹងទៅថ្ងៃខែ១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានន័យថា ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ គឺមិនបានទាក់ទងជាមួយខាង *ឌីស៊ីខេម* ទេ តើមែនឬទេ?

**ឆ៖** ក្រដាសស្នាមទាំងអស់ហ្នឹង ទាំងរូបខ្ញុំក៏ដោយ មិនបានទៅជួបនឹងអង្គការ *ឌីស៊ីខេម* ទេ ។

**ស៖** ប្រហែលលោកមិនបានទៅ *ឌីស៊ីខេម* ខ្លួនឯងទេ ប៉ុន្តែលោកបានជួបតំណាងជាមួយអង្គការហ្នឹងតើមែនឬទេ? តើអាចធ្វើបានទេ អាចប្រាប់យើងថា ប្រហែលពេលណា ដែលលោកបានជួប គេជាមួយអ្នកតំណាងហ្នឹងជាលើកដំបូង?

**ឆ៖** ខ្ញុំអត់បានជួបទេ ។ ជួបតែអង្គការ មជ្ឈមណ្ឌល--អង្គការ *ឌីស៊ីខេម* ខ្ញុំអត់បានទៅជួបទេ ។

**ស៖** លោកមិនដែលបានចាំអ្នកតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែព្រឹកមិញនេះ ឬក៏ល្ងាចនេះ លោកបាននិយាយថា ការជួបនោះ គឺបានមែន ។ ប៉ុន្តែ លោកមិនបានបញ្ជាក់ពីការបរិច្ឆេទដែលថា មានការជួបនោះទេ ។

**ឆ៖** ខ្ញុំបានជួបតែអង្គការមជ្ឈមណ្ឌលនេះ ខ្ញុំជួបមែន ។ គាត់បានហៅខ្ញុំទៅ ។

**ស៖** ពិតមែនហើយ ប្រហែលខ្ញុំប្រើពាក្យមួយ ដែលលោកមិនយល់ ដូចជាលោកហ្នឹង គឺខ្ញុំនិយាយថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងហៅអង្គការដដែលហ្នឹង តើលោកអាចប្រាប់យើងបានទេ ថានៅអំឡុងពេលណា ដែលលោកបានជួបអ្នកតំណាងពីអង្គការហ្នឹងជាលើកដំបូង?

**ឆ៖** ខ្ញុំចាំថ្ងៃខែអត់បានច្បាស់ ។

**ស៖** ប្រហែល គ្រាន់តែបញ្ជាក់ ខ្ញុំមិនសួរនូវកាលបរិច្ឆេទច្បាស់លាស់ គ្រាន់តែប្រហែលជានៅក្នុងពេលណា ក្នុងឆ្នាំណា?

**ឆ៖** ក្នុងឆ្នាំហ្នឹង ប៉ុន្មានខែមុននេះ ប៉ុន្តែអត់មានមុនចូលឆ្នាំទេ ក្រោយចូលឆ្នាំ ។

**ស៖** ខ្ញុំមានសំណួរមួយទៀត លោក លី ហ៊ ព្រឹកមិញនេះ លោកនិយាយថា លោកមិនបានដឹងដែលកន្លែងណាដែលលោកបានទទួលឯកសារនោះទេ ដែលហៅថា ជីវប្រវត្តិរូបរបស់ លី ហ៊ ដែល ERN0029 រហូតទៅដល់ E262.2 ហ្នឹង ។ អ៊ីចឹងគឺថាអាចនឹងជាអ្នកតំណាងរបស់មជ្ឈមណ្ឌល

ឯកសារកម្ពុជាជាអ្នកបង្ហាញលោកទេ នូវឯកសារហ្នឹង?

**ឆ៖** ខ្ញុំចង់ឲ្យបញ្ជាក់ឲ្យខ្ញុំស្តាប់បាន ឲ្យបានម្តងទៀត?

**ស៖** ព្រឹកមិញនេះ លោកបានចង្អុលបង្ហាញថា លោកមិនបានដឹងថា តើឯកសារដែលមានចំណងជើងថា "ជីវប្រវត្តិរបស់ អ៊ា ហ៊ា" យកមកពីណាទេ ។ អ៊ីចឹងសំណួរហ្នឹងសួរថា តើអាចទៅរួចទេដែលថា អាចនឹងជាពេលមួយដែលគេផ្តល់អ្នកតំណាង មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកផ្តល់ឲ្យលោក?

[១៥:៥០:១១]

**ឆ៖** តាមដែលឯកសារដែលនេះហ្នឹង ផ្តល់មកឲ្យខ្ញុំ គឺជាឯកសារពិតប្រាកដរបស់ខ្ញុំមែន ។

**ស៖** ដូច្នេះ អ្នកណាជាអ្នកឲ្យឯកសារនេះមកលោក បើនិយាយឲ្យចំទៅនោះ?

**ឆ៖** អង្គការមជ្ឈមណ្ឌលកម្ពុជា ។

**ស៖** តើអ្នកដែលឲ្យឯកសារនោះ មកលោកនោះ បាននិយាយប្រាប់លោកពីអ្វីទេ នៅពេលដែលគេជួបលោកនោះ? បើសិនជាគេបាននិយាយ តើគេនិយាយប្រាប់អំពីអ្វី?

**ឆ៖** គេគ្រាន់តែនិយាយ គ្រាន់តែហុចឯកសារនេះមកឲ្យខ្ញុំ ថាតើឯកសារនេះតើពិតប្រាកដជារបស់ខ្ញុំពិតមែនឬទេ? ក៏ខ្ញុំ ក៏ឆ្លើយថា ពិតជារបស់ខ្ញុំ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ដើម្បីសួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំពិនិត្យឃើញថា បន្ទាប់ពីមានការពន្យល់ពីជនជាប់ចោទ យើងមានឯកសារថ្មី ដែលយើងត្រូវត្រឡប់ទៅពិនិត្យមើល ។ ដូច្នេះ បើតាមខ្ញុំយល់ពីជនជាប់ចោទ គឺថាគាត់ទទួលស្គាល់ពីឯកសារហ្នឹង ដែលត្រូវដាក់ជូនមកតុលាការដើម្បីគាំទ្រមកពាក្យសុំរបស់ដើមបណ្តឹងរដ្ឋ-ប្បវេណី គឺដាក់ពិតជាឯកសារចេញមកពីស-២១ ហើយគាត់បាននិយាយពីចំណុចមួយចំនួនដែលគាត់

ទទួលស្គាល់ថា អ្នកណាជាអ្នករៀបចំឯកសារហ្នឹង ។ ដូច្នេះហើយ នៅតាមទស្សនៈរបស់គាត់ហ្នឹង គឺថាគាត់មិនមានជំទាស់ តវ៉ាចំពោះអង្គហេតុដែលថា លី ហ៊ី ត្រូវបានឃុំខ្លួននៅស-២១ ទេ ។ ប៉ុន្តែៗ អ៊ា ហ៊ី ត្រូវបានឃុំខ្លួននៅស-២១ ប៉ុន្តែគាត់ចង្អុលបង្ហាញថា អ៊ា ហ៊ី នោះត្រូវបានគេសម្លាប់ទៅហើយ ហើយលើសពីហ្នឹងទៅទៀត ឈ្មោះរបស់គាត់បានបញ្ជាក់នៅក្នុងបញ្ជីកម្មេចដែលសហព្រះរាជអាជ្ញាបានផ្តល់ជូនមកនោះ ។ ដូច្នេះ ខ្ញុំពិនិត្យឃើញថា នោះគឺថា ត្រូវឲ្យមានការបំភ្លឺឲ្យច្បាស់ដោយអង្គជំនុំជម្រះ ប្រហែលសហព្រះរាជអាជ្ញា លោកអាចបន្ថែមបាននៅក្នុងបញ្ហានេះ ។

**លោក រ៉ូប៊ីត ពើទីត៖**

សូមអរគុណលោកចៅក្រម ។ នេះជាអ្វី ជាស្ថានភាពដែលមិនធម្មតាមួយ ដើម្បីឲ្យៗជនជាប់ចោទយោង ឲ្យចៅក្រមពិនិត្យទៅមើលឯកសារ ។ អ៊ីចឹង ខ្ញុំសូមអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីឲ្យផ្តល់នូវៗចម្លើយដ៏វែងពិស្តារមួយ ។ ប៉ុន្តែ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ថា នៅក្នុងការបកប្រែ ឬក៏ការបកប្រែទៅជាអង់គ្លេសនោះ លេខយោង គឺថាមិនបានច្បាស់ទេ ខ្ញុំមិនអាចនឹងធ្វើការវាយតម្លៃអំពីការបញ្ជាក់របស់ជនជាប់ចោទបានទេ ។ ខ្ញុំនឹងឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើម្បីបញ្ជាក់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើជនជាប់ចោទ អាចនឹងបញ្ជាក់ពីលេខយោង ដែលខ្លួនបញ្ជាក់ជាថ្មីម្តងទៀតនៅពេលដែលលោកបានប្រាប់ពីខាងដើមម្តងហើយនោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំគិតថា លេខយោងចម្បងនោះ គឺបញ្ជីអ្នកទោសដែលបានកែប្រែរួចរាល់ គឺលេខ ERN 003 29681 ហើយប្រសិនបើអស់លោក លោកស្រីមើលទៅលើតារាងខាងឆ្វេងដៃ លេខ១៩៦៨ គឺនិយាយអំពីបុរសអាយុ២១ឆ្នាំ ឈ្មោះ អ៊ា ហ៊ី ដែលបុគ្គលនេះ នៅពេលចាប់ខ្លួន គាត់មានតួនាទីជាសមាជិកផ្នែករំលាយដែក កោះខែល មន្ទីរ១៣ ហើយចូលថ្ងៃចូលស-២១ ដប់ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៥ ។ ហើយប្រសិនបើអនុញ្ញាត ខ្ញុំសូមបន្តលើសំណើរបស់លោកចៅក្រមឡាវ៉ែន ដែលសុំឲ្យមានការបំភ្លឺ ហើយសុំឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ថាតើមេធាវីទទួលយកថាឯកសារ ឬព័ត៌មាននៅក្នុងឯកសារនេះ គឺវាជាឯកសារពិត ហើយពាក់ព័ន្ធទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយើងត្រូវ-- ដែលយើងព្យាយាមធ្វើការបញ្ជាក់ស្ទើរតែពេញមួយថ្ងៃនេះ ហើយជាប់ចោទ គាត់បានទទួលស្គាល់ថា វាឯកសារដែលបានបង្ហាញពីក្នុងសវនាការរបស់យើង គឺ

ឯកសារពីស-២១ ក្នុងចំណោមឯកសាររបស់ ម៉ម ណៃ និង ហ៊ ថាតើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ទៅលើចំណុចនេះដែរឬទេ?

[១៥:៥៦:៥៨]

**លោក អាឡាំង វ៉ែនណឹ៖**

ខ្ញុំទទួលស្គាល់ ហើយទាក់ទងទៅនឹងអ្វីដែលជនជាប់ចោទបានលើកឡើង ខ្ញុំសូមធ្វើការបំភ្លឺដោយសារនៅភាសាអង់គ្លេសមិនច្បាស់ទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថាតើឯកសារនៅក្នុងបញ្ជី ដែលលោកស្រីបានលើកឡើងនោះ យើងទទួលយកដែរឬទេ? ថាតើគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី កូនក្តីរបស់ ខ្ញុំដែរឬទេ? ខ្ញុំមិនអាចបញ្ជាក់ទៅលើចំណុចនេះបានទេ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ជំហររបស់យើងនោះ គឺបញ្ជីរបស់យើងដែលយើងមាន និងឯកសាររបស់យើងនេះដកស្រង់ចេញមកពីស-២១ ។

សំណួរដែលខ្ញុំបានសួរ គឺដូចដែលជនជាប់ចោទគាត់បានលើកឡើងអ៊ីចឹង គឺទាក់ទងទៅនឹងឯកសារយោងនៅក្នុងឯកសាររបស់ ម៉ម ណៃ ។

*(ចៅក្រមពិភាក្សា)*

[១៦:០០:១២]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ សហព្រះរាជអាជ្ញា ខ្ញុំចង់សួរលោកឲ្យលោកបំភ្លឺថា លេខយោងដែលខ្ញុំទើបតែអានអម្បាញ់មិញនោះ ដែលខ្ញុំនិយាយអំពីលេខយោងបញ្ជីអ្នកទោស ដែលពិនិត្យនិងកែប្រែរួចរាល់នោះ គឺជាបញ្ជីដែលទើបតែចងក្រងអំពីអ្នកទោសនៅស-២១ ដែរឬទេ? ហើយបញ្ជីនេះត្រូវបានកែប្រែ និងសើរើពីបញ្ជីមុន ។ ជាពិសេសបញ្ជីនោះ ត្រូវបានពិនិត្យដោយជនជាប់ចោទផងដែរ ។ ហើយតាមអ្វីដែលសហព្រះរាជអាជ្ញាបានដឹង ថាតើបញ្ជីអ្នកទោសស-២១ គឺវាមានលក្ខណៈគួរឲ្យជឿបាននៅពេលនេះដែរឬទេ?

**លោក រ៉ូប៊ឺត ពេទីត៖**

សូមអរគុណលោកស្រីចៅក្រម ។ ហើយបញ្ជីនេះ គឺបានបញ្ជាក់ត្រឹមត្រូវ យើងមិននិយាយថាបញ្ជីនេះវារៀបរាប់ឈ្មោះអ្នកទោសទាំងអស់នោះទេ ចំពោះអ្នកទោសនៅស-២១ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ការដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ លី ហ៊ា ឃើញថាដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណ ចំពោះលោក លី ហ៊ា ដែលបានចំណាយពេលវេលាហើយមកចូលរួមតាមការកោះហៅរបស់អង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏បានយល់ផងដែរថា ការដែលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះហ្នឹង គឺពិតជាមានការលំបាកជាច្រើន ចំពោះរូបលោកដែលត្រូវប្រឈមនឹងការឆ្លើយនូវសំណួរផ្សេងៗពីគ្រប់ភាគីនោះ ។ ហើយសូមអរគុណ ។ ហើយអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ។ អ៊ីចឹងសូមភាគីទាំងអស់បានជ្រាប និងសូមអញ្ជើញចូលរួម ។

ហើយមន្ត្រី តុលាការសម្របសម្រួលដល់លោក លី ហ៊ា ដើម្បីឲ្យគាត់បានត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ជាមួយនិងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។

ហើយអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃស្អែក ព្រឹកថ្ងៃស្អែកវេលា ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី]*